**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាខ្ចីបរិភោគ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ម៉ុន លីតីន**

**ក. ម៉ា សុធារ៉ា**

សាស្ត្រាចារ្យណែនាំ

អ្នកស្រី **ប៉ូលី បញ្ញា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ុខ លីនីខ** និង **ម៉ា សុធារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី២២ ឆ្នាំសិក្សា ២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសម្ដែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

**លោកឪពុក និងអ្នកម្ដាយ** ដែលផ្ដល់កំណើតដល់រូបកូន ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ណែនាំ ហើយថែមទាំងជួយទំនុកបម្រុងសព្វគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ស្មារតី និងផ្ដល់ឱកាសដ៏មានតម្លៃឱ្យកូនទទួលបានការអប់រំតាំងពីថ្នាក់បឋម រហូតដល់កូនបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានដោយជោគជ័យគួរជាទីមោទនៈ។

យើងខ្ញុំសូមថ្លែងអំណរអគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ធា** និងសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់នូវកម្លាំងកាយចិត្ត ក្នុងការដឹកនាំបង្ហាត់បង្រៀន ក៏ដូចជាផ្ដល់នូវចំណេះដឹង និងដំបូន្មានល្អៗដល់យើងខ្ញុំទាំងពីររូប។ ដោយសារតែគុណូបការៈរបស់លោកនេះហើយទើបធ្វើឲ្យយើងខ្ញុំបានទទួលយកចំណេះដឹងនេះរហូតដល់អាចបញ្ចប់ការសិក្សានេះបានដោយជោគជ័យ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកស្រីសាស្ត្រាចារ្យ **ម៉ូលី ចញ្ញា** ដែលជាសាស្ត្រាចារ្យណែនាំ ដែលលោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្ដល់នូវដំបូន្មាន កែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានជោគជ័យគួរជាទីមោទនភាព។

ជាកិច្ចបញ្ចប់ យើងខ្ញុំជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានជួបតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានភាពសុខដុមរមនាក្នុងជីវិតជាសហព័ទ្ធរបស់ខ្លួន និងជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពីលោក-លោកស្រីសាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យយើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **"កិច្ចសន្យាខ្ចីបរិភោគ"** ។

ប្រធានបទមួយនេះ គឺកើតចេញពីចម្ងល់ និងការចង់ដឹងឱ្យកាន់តែស៊ីជម្រៅរបស់យើងខ្ញុំទៅលើកិច្ចសន្យាខ្ចីបរិភោគ។ សារណាបញ្ចប់ការសិក្សាមួយនេះផ្ដោតសំខាន់ទៅលើសញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ ព្រមទាំងជាមួយលក្ខខណ្ឌនៃការបង្កើត និងមូលហេតុនៃការទាមទារដើម្បីបង្កើតសិទ្ធិនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលធ្វើយ៉ាងណា ដើម្បីធានាដល់នូវឧត្តមប្រយោជន៍នៃសិទ្ធិរបស់គូភាគីនៃកិច្ចសន្យា ក៏ដូចជាការអនុវត្តកិច្ចសន្យាខ្ចីបរិភោគ។ លើសពីនេះទៅទៀតសារណាមួយនេះអាចលេចចេញជារូបរាងឡើងដោយសារមានការជួយជ្រោមជ្រែងណែនាំ តម្រង់ទិសពីសំណាក់ លោកស្រីសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ដែលបានចំណាយពេលដ៏មានតម្លៃ ក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។

ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងសារណានេះ ក៏សង្ឃឹមថាឯកសារនេះនឹងអាចក្លាយជាប្រយោជន៍ និងជាវិភាគទាន ព្រមទាំងផ្ដល់ជាចំណេះដឹងបន្ថែមសម្រាប់ជាគន្លឹះ និងជាជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្តបាន។

តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែចំណេះដឹង និងបទពិសោធន៍ក្នុងការស្រាវជ្រាវនៅមានកម្រិតនៅឡើយសារណានេះច្បាស់ជាមាននូវចំណុចខ្វះខាត និងកំហុសជាក់ជាពុំខាន។ ហេតុដូចនេះហើយ មតិយោបល់ និង ការិះគន់ ដើម្បីកែលម្អនូវចំណុចខ្វះខាតទាំងអស់នេះ គឺពិតជាមានសារៈសំខាន់ណាស់ ហើយនាងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយ និងសូមស្វាគមន៍នូវការមតិយោបល់រិះគន់ ដើម្បីស្ថាបនាទាំងអស់ដោយសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ**

**ផ្នែកទី១៖ ប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ** ........ ៣

កថាខណ្ឌទី១៖ ការសិក្សាអំពីប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគមុនឆ្នាំ១៩៩៣ ........ ៣

កថាខណ្ឌទី២៖ ការសិក្សាអំពីប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគក្រោយឆ្នាំ១៩៩៣.... ៥

**ផ្នែកទី២៖ ខ្លឹមសារនៃកិច្ចសន្យាខ្ចីបរិភោគ** ........ ៦

កថាខណ្ឌទី១៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីចាស់ ........ ៦

កថាខណ្ឌទី២៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រឹត្យច្បាប់លេខ៣៨៧ ........ ៧

កថាខណ្ឌទី៣៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ........ ៧

**ផ្នែកទី៣៖ ការកំណត់កម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគ** ........ ៧

កថាខណ្ឌទី១៖ ករណីកម្មវត្ថុជាវត្ថុ ........ ៧

កថាខណ្ឌទី២៖ ករណីកម្មវត្ថុជាប្រាក់ ........ ៨

**ជំពូកទី២**

**ការបង្កើតកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧**

**ផ្នែកទី១៖ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់** ........ ១០

កថាខណ្ឌទី១៖ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........ ១០

១. ការព្រមព្រៀងបង្កើតការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........ ១១

២. កម្មវត្ថុ និងមូលហេតុនៃការបង្កើតការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........ ១១

២.១ កម្មវត្ថុនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........ ១២

២.២ មូលហេតុនៃការបង្កើតការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........ ១២

៣. សមត្ថភាពភាគីនៃការបង្កើតការខ្ចីបរិភាគដោយមានភ្ជាប់ការប្រាក់ ........ ១២

៣.១ ករណីភាគីទាំងសងខាងជារូបវន្តបុគ្គល ........ ១៣

៣.២ ករណីភាគីទាំងសងខាងជានីតិបុគ្គល ........ ១៦

៣.៣ ករណីភាគីជានីតិបុគ្គល និងរូបវន្តបុគ្គល ........ ១៦

កថាខណ្ឌទី២៖ ប្រភេទកម្មវត្ថុចំពោះការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់................................. ១៧
១. ករណីកម្មវត្ថុជាវត្ថុនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ................................ ១៧
២. ករណីកម្មវត្ថុជាប្រាក់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........................... ១៨
២.១ ការប្រាក់.............................................................................................................. ១៨
២.២ អត្រាការប្រាក់ ...................................................................................................... ១៩
២.២.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ........................................................ ២០
២.២.២ អត្រាការប្រាក់ក្នុងកិច្ចសន្យា ........................................................................ ២០
២.២.៣ ការកម្រិតការប្រាក់........................................................................................ ២១
២.៣ ពេលវេលាសងនៃការបង់ការប្រាក់ និងការប្រាក់សមាសកំណត់ដោយច្បាប់ ............... ២២
២.៣.១ ពេលវេលាសងនៃការបង់ការប្រាក់.............................................................. ២២
២.៣.២ ការប្រាក់សមាសកំណត់ដោយច្បាប់ ............................................................ ២២
**ផ្នែកទី២៖ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់**............................ ២៣
កថាខណ្ឌទី១៖ លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់........ ២៣
១. ការព្រមព្រៀងបង្កើតការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់................................................ ២៣
២. កម្មវត្ថុ និងមូលហេតុនៃការបង្កើតការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់ ............................. ២៤
៣. សមត្ថភាពភាគីនៃការបង្កើតការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់.................................... ២៥
៣.១ ករណីភាគីទាំងសងខាងជារូបវន្តបុគ្គល ................................................................ ២៥
៣.២ ករណីភាគីទាំងសងខាងជានីតិបុគ្គល.................................................................... ២៥
៣.៣ ករណីភាគីជានីតិបុគ្គល និងរូបវន្តបុគ្គល............................................................... ២៦
កថាខណ្ឌទី២៖ ប្រភេទនៃកម្មវត្ថុចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់ ............................... ២៦
១. ករណីកម្មវត្ថុជាវត្ថុចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់ ........................................... ២៦
២. ករណីកម្មវត្ថុជាប្រាក់ចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់ ....................................... ២៧

## ជំពូកទី៣

## ការអនុវត្តនៃកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**ផ្នែកទី១៖ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ** ................................. ២៨
កថាខណ្ឌទី១៖ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីអ្នកឲ្យខ្ចី ............................................................ ២៨
១. សិទ្ធិរបស់ភាគីអ្នកឲ្យខ្ចី............................................................................................ ២៨

១.១ ករណីកម្មវត្ថុជាវត្ថុ........................................................................................... ២៨
១.២ ករណីកម្មវត្ថុជាប្រាក់........................................................................................ ២៨
២. កាតព្វកិច្ចរបស់ភាគីអ្នកឲ្យខ្ចី ........................................................................................ ២៩
២.១ កាតព្វកិច្ចចំពោះកម្មវត្ថុជាវត្ថុ.............................................................................. ២៩
២.២ កាតព្វកិច្ចចំពោះកម្មវត្ថុជាប្រាក់............................................................................ ២៩
កថាខណ្ឌទី២៖ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីអ្នកខ្ចី ........................................................... ៣០
១. សិទ្ធិរបស់ភាគីអ្នកខ្ចី ........................................................................................ ៣០
១.១ ករណីកម្មវត្ថុជាវត្ថុ........................................................................................... ៣០
១.២ ករណីកម្មវត្ថុជាប្រាក់........................................................................................ ៣០
២. កាតព្វកិច្ចរបស់ភាគីអ្នកខ្ចី ........................................................................................ ៣១
២.១ កាតព្វកិច្ចចំពោះកម្មវត្ថុជាវត្ថុ.............................................................................. ៣១
២.២ កាតព្វកិច្ចចំពោះកម្មវត្ថុជាប្រាក់............................................................................ ៣២
**ផ្នែកទី២៖ ការរំលាយ និងការលុបចោលកិច្ចសន្យាខ្ចីបរិភោគ**............................................ ៣៣
កថាខណ្ឌទី១៖ មូលហេតុនៃការរំលាយកិច្ចសន្យាខ្ចីបរិភោគ ................................................. ៣៣
១. មូលហេតុនៃការរំលាយរបស់ភាគីអ្នកឲ្យខ្ចី.............................................................. ៣៣
២. មូលហេតុនៃការរំលាយរបស់ភាគីអ្នកខ្ចី................................................................ ៣៤
កថាខណ្ឌទី២៖ មូលហេតុនៃការលុបចោលកិច្ចសន្យាខ្ចីបរិភោគ.............................................. ៣៤
១. មូលហេតុនៃការលុបចោលរបស់ភាគីអ្នកឲ្យខ្ចី......................................................... ៣៥
២. មូលហេតុនៃការលុបចោលរបស់ភាគីអ្នកឲ្យខ្ចី ........................................................ ៣៦
**ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទនៃកិច្ចសន្យាខ្ចីបរិភោគ** ....................................... ៣៧
កថាខណ្ឌទី១៖ នីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........................................ ៣៧
១. ការចរចារ ........................................................................................................ ៣៧
២. សន្ធានកម្មៈកិច្ចសម្រុះសម្រួលតាមរយៈអាជ្ញាធរដែនដី ................................................ ៣៨
៣. មជ្ឈត្តការ ...................................................................................................... ៣៩
កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទតាមរយៈស្ថាប័នតុលាការ ................................... ៤១
១. តុលាការខេត្តក្រុង ............................................................................................ ៤១
២. សាលាឧទ្ធរណ៍.................................................................................................. ៤៤

៣. តុលាការកំពូល ........................................................................................ ៤៤
**សេចក្ដីសន្និដ្ឋាន** ........................................................................................ ៤៥
**អនុសាសន៍** ........................................................................................ ៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងការរស់នៅប្រចាំថ្ងៃ កិច្ចសន្យាបានដើរតួយ៉ាងសំខាន់ក្នុងការជួយឱ្យកិច្ចការជំនួញមានស្ថិរភាព និងមានការជឿទុកចិត្តគ្នាទៅវិញទៅមក។ ដូច្នេះហើយ ទើបនៅក្នុងសង្គមតែងតែប្រើប្រាស់កិច្ចសន្យាសំរាប់ជីវភាពប្រចាំថ្ងៃ ដោយពួកគេបានបង្កើតកិច្ចសន្យាជាច្រើនដូចជា កិច្ចសន្យាលក់ទិញ ភតិសន្យា ជាពិសេសនោះគឺ កិច្ចសន្យាខ្ចីបរិភោគជាដើម។ ជាក់ស្តែងបើយើងក្រឡេកទៅមើលសង្គមយើងសព្វថ្ងៃនេះបុគ្គលគ្រប់រូបរមែងតែងតែខិតខំប្រឹងប្រែងបង្កើននូវមុខរបររកស៊ីប្រចាំថ្ងៃអោយកាន់តែរីកចម្រើន ឬបង្កើតនូវមុខជំនួញបន្ថែមទៀត ដើម្បីអោយជីវភាពកាន់តែប្រសើរឡើងថែមទៀត។ យើងអាចដឹងហើយថាមិនថាជំនួញតូចក្តី ឬធំក្តីទេរមែងតែងមានការជួបនូវវិបត្តិខាងផ្នែកសេដ្ឋកិច្ច ភាពកង្វះខាតលើការវិនិយោគទុន ខ្វះខាតដើមទុន សំរាប់ការធ្វើបង្វិលទូទាត់ ឬកង្វះខាតផ្នែកសម្ភារៈផ្សេងៗ ដែលជាហេតុបណ្តាលអោយមានការខ្ចីប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីយកមកបំពេញនូវសេចក្តីត្រូវការរបស់ខ្លួនរៀងៗខ្លួន។ តាមរយៈការខ្ចីប្រាស្រ័យទាក់ទងគ្នារវាងអ្នកខ្ចីប្រាក់ និងម្ចាស់បំណុលតែងតែមានទំនាស់ទាស់ទែងគ្នា ដែលបណ្តាលមកពីការខ្វះខាតនៃការយល់ដឹងអំពីការខ្ចីប្រាក់បរិភោគ ទើបធ្វើអោយកើតមានជម្លោះ រហូតឈានដល់ការប្តឹងផ្តល់គ្នាទៅវិញទៅមក ។ អាស្រ័យហេតុនេះហើយ ដើម្បីជៀសវាងរាល់បញ្ហាទាំងអស់នេះ ភាគីទាំងសងខាងគួរណាស់តែស្វែងយល់អោយបានច្បាស់លាស់ អំពីរបៀបនៃការបង្កើត ការអនុវត្តកាតព្វកិច្ចទៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។ ម៉្យាងវិញទៀត កិច្ចសន្យាប្រភេទនេះគឺកំពុងតែមានការប្រើប្រាស់ច្រើននាពេលបច្ចុប្បន្ននេះ ជាពិសេសទាក់ទងទៅនឹងវិស័យពាណិជ្ជកម្ម ក្រោមទម្រង់ជាកិច្ចសន្យាផ្តល់ឥណទានតាមរយៈធនាគារ ឬការចងការប្រាក់រវាងឯកជន និងឯកជន ឬមួយវិញទៀតជាការខ្ចីវត្ថុ ដែលអាចផ្ទេរកម្មសិទ្ធិបាន ដូចជាការខ្ចីស្រូវ អង្ករ ឬសាច់ យកទៅបរិភោគជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអ្វីទៅហៅថា ការខ្ចីបរិភោគ? នៅក្នុងការបង្កើតកិច្ចសន្យាខ្ចីបរិភោគត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ដើម្បីឱ្យកិច្ចសន្យានេះមានអានុភាពស្របទៅតាមផ្លូវច្បាប់? តើការអនុវត្តកិច្ចសន្យាខ្ចីបរិភោគនៅព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺចង់ផ្តោតសំខាន់ទៅលើការស្វែងយល់អំពីការអនុវត្តសិទ្ធិ ក៏ដូចជាកាតព្វកិច្ចរវាងអ្នកអោយខ្ចី និងអ្នកខ្ចី នៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះ។ លើសពីនេះទៅ

ទៀត នៅពេលដែលយើងទាំងអស់គ្នាបានយល់ដឹងពីកិច្ចសន្យាខ្ចីបរិភោគបានច្បាស់លាស់ហើយ នោះយើងមិនត្រូវបានខាតបង់ផលប្រយោជន៍ ឬត្រូវជនខិលខូចបោកប្រាស់បានឡើយ។

## ៤. វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាទៅលើប្រធានបទស្ដីពីកិច្ចសន្យាខ្ចីបរិភោគមួយនេះ គឺមានទំនាក់ទំនងទៅលើសិទ្ធិបុគ្គលឯកជន ដែលមានចែងនៅក្នុងមាត្រា ៥៧៨ ដល់មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដែលចូលជាធរមាន។ ចំពោះការស្រាវជ្រាវនេះមានពេលវេលាកំណត់ ដូចនេះយើងផ្តោតសំខាន់តែទៅលើលក្ខខណ្ឌនៃការបង្កើត ក៏ដូចជាការអនុវត្តសិទ្ធិ និងករណីយកិច្ចរវាងភាគីអ្នកខ្ចី និងអ្នកអោយខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់ទៅលើការស្រាវជ្រាវប្រធានបទខាងលើ គឺចង់ផ្តល់ចំណេះដឹងបន្ថែមដល់អ្នកអានអោយបានយល់ដឹងកាន់តែស៊ីជម្រៅ អំពីកិច្ចសន្យាខ្ចីបរិភោគនេះ។ មួយវិញទៀត គឺចង់ចងក្រងរក្សាទុកជាឯកសារសំរាប់សិស្សជំនាន់ក្រោយបានយកទៅសិក្សាស្វែងយល់បន្ថែម។ លើសពីនេះទៅទៀត ចង់អោយបុគ្គលគ្រប់ៗរូបដឹងថា ដើម្បីទទួលបានកិច្ចសន្យាខ្ចីបរិភោគមួយដែលមានលក្ខណៈពេញលេញស្របទៅតាមច្បាប់ត្រឹមត្រូវ គឺយើងត្រូវតែគោរពទៅតាមលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាទូទៅជាមុនសិន មុននឹងឈានដល់ការគោរពតាមគោលការណ៍របស់កិច្ចសន្យាខ្ចីបរិភោគ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដោយផ្អែកតាមរយៈលទ្ធផលនៃការស្រាវជ្រាវសារណានេះ យើងនឹងសិក្សាបែងចែកជា ៣ ជំពូកគឺៈ

- **ជំពូកទី១ៈ សញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ**
- **ជំពូកទី២ៈ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧**
- **ជំពូកទី៣ៈ ការអនុវត្តកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧**

ដូចនេះយើងខ្ញុំ សូមធ្វើការសិក្សាទៅលើជំពូកនីមួយៗទាំង ៣ ខាងលើនេះ ដោយបង្ហាញជូនទាំងស្រុងនៅក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដូចខាងក្រោមនេះតទៅៈ

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាគឺជាសកម្មភាពរបស់បុគ្គលពីរនាក់ ឬច្រើននាក់ក្នុងការធ្វើសេចក្តីព្រមព្រៀងគ្នា ដើម្បីដាក់លក្ខខណ្ឌអ្វីមួយ ដើម្បីបង្កើត កែប្រែ និងរំលត់កាតព្វកិច្ច។ កិច្ចសន្យាត្រូវបានបែងចែក ច្រើនប្រភេទដូចជាកិច្ចសន្យាលក់ទិញ កិច្ចសន្យាបញ្ញាំ កិច្ចសន្យាក្រុមហ៊ុន ហ៊ីប៉ូតែកជាដើម តែមានកិច្ចសន្យាមួយដែលមានការចាប់អារម្មណ៍ច្រើនពីសំណាក់គូភាគីដែលធ្លាប់តែធ្វើកិច្ចសន្យាជាប្រចាំនោះគឺ កិច្ចសន្យាខ្ចីបរិភោគ។

នាពេលបច្ចុប្បន្ននេះ នៅក្នុងជីវភាពរស់នៅរបស់ប្រជាជនយើងសព្វថ្ងៃ តែងមានការខ្ចីប្រាស្រ័យទាក់ទងគ្នាដើម្បីយកទៅបំពេញតំរូវការរៀងៗខ្លួន ហើយសកម្មភាពទាំងអស់នេះមានតាំងពីយូរលង់ណាស់មកហើយ។ ចំពោះកម្មវត្ថុនៃការខ្ចីបរិភោគរបស់យើង ក៏មានការបែងចែកទៅតាមប្រភេទ និងលក្ខខណ្ឌរបស់វាដែរ។ ដើម្បីជាជំនួយឈានទៅរកការបកស្រាយកិច្ចសន្យាខ្ចីបរិភោគអោយបានក្បោះក្បាយ យើងគួរតែស្វែងយល់អំពីប្រវត្តិខ្លះៗ និងអត្ថន័យនៃកិច្ចសន្យាខ្ចីបរិភោគជាមុនសិន។

## ផ្នែកទី១៖ ប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កម្ចីបរិភោគ ឬភាសាទូទៅដែលនិយមប្រើប្រាស់នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃដែលគេហៅថាការខ្ចីបុលនោះ វាគឺជាសកម្មភាពមួយដែលកើតមានឡើងតាំងពីបុរាណកាល តាំងពីយូរយារណាស់មកហើយក្នុងគ្រប់សង្គមមនុស្ស វាកើតមានដំណាលគ្នាជាមួយសង្គមមនុស្សនៅពេលចាប់ផ្តើមចេះផលិតរបស់របរ និងធ្វើការដូរ។ ជាទូទៅនៅក្នុងសង្គមតម្រូវការរបស់បុគ្គលម្នាក់ៗ និងវត្ថុបំណងមានច្រើនយ៉ាងសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ ដូចនេះទំនាក់ទំនងនៃកម្ចីបរិភោគកើតឡើងដោយមិនអាចចាត់ថ្នាក់បាន។

### កថាខណ្ឌទី១៖ ការសិក្សាអំពីប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាបរិភោគមុនឆ្នាំ១៩៩៣

នៅចន្លោះឆ្នាំ១៨៣៦ ដល់ឆ្នាំ១៩៥៣ កម្ពុជាបានស្ថិតក្រោមអាណានិគមរបស់បារាំង។ អនុសញ្ញាឆ្នាំ១៨៨៤ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំងបានផ្ទេរ ឬប្រគល់អំណាចផ្នែករដ្ឋបាលរបស់រដ្ឋអោយទៅបារាំង។ នៅពេលនោះប្រជាពលរដ្ឋខ្មែរស្ទើរតែទាំងអស់បានជួបនូវវិបត្តិមួយ គឺដើរមិនទាន់របបមូលធនព្រោះថាមុនបារាំងចូលមកប្រជាជនយើងរស់នៅលក្ខណៈបែបប្រពៃណី ធ្វើការដោះដូរតែប្រចាំថ្ងៃតែប៉ុណ្ណោះដែលមិនមែនជាលក្ខណៈបែបមូលធននិយមទេ។ នៅពេលដែលបារាំងចាប់ផ្តើមប្រមូលពន្ធ ចាប់ផ្តើមបង្កើតទីផ្សារ ដែលជាហេតុពិបាកក្នុងការរស់នៅ ដែលធ្វើឱ្យប្រជាជនភាគច្រើនបានបង្ខំចិត្តទៅខ្ចីបុល។ ពេលនោះមានកុងស៊ីបញ្ចាំជាច្រើន ហើយកុងស៊ីបញ្ចាំនៅសម័យនោះភាគច្រើនជាជនជាតិចិន។ នៅពេលប្រជាជនខ្មែរទៅខ្ចីប្រាក់ គឺការប្រាក់ក្នុង ១រដូវស្ថិតក្នុងរង្វង់ពី ១០០% ទៅ ១៥០% គឺអត្រាការប្រាក់ខ្ពស់ខ្លាំងណាស់ដែលពេលនោះដីធ្លីភាគច្រើនរបស់ខ្មែរបានក្លាយជារបស់ចិន មានន័យថាដីខ្មែរបានជាប់កុងស៊ីអស់ហើយ។

នៅពេលដែលឃើញស្ថានភាពបែបនេះបារាំងបានចេញច្បាប់មួយ គឺកំណត់យកអត្រាការប្រាក់មិនលើសពី ៣០% ក្នុង១រដូវ។ ប៉ុន្តែយន្តការនេះមានតែនៅលើក្រដាសតែប៉ុណ្ណោះ រីឯការអនុវត្តជាក់ស្តែងមិនមែនបែបនឹងនោះទេ ព្រោះថានៅពេលប្រជាជនទៅខ្ចីប្រាក់នៅក្នុងកុងស៊ីម្ចាស់កុងស៊ីថាមិនមានប្រាក់ទេ ប៉ុន្តែបើទៅខ្ចីតាមទ្វារក្រោយគឺមានតែការប្រាក់គឺដដែល ១០០% ទៅ ១៥០%។ ហេតុដូចនេះហើយទើបធ្វើឱ្យសម័យនោះការរស់នៅគឺស្ថិតក្នុងស្ថានភាពពិបាក។[1]

ក្នុងឆ្នាំ១៩២០ ក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានប្រកាសឱ្យប្រើប្រាស់។ ក្នុងនោះក៏បានចែងអំពីកិច្ចសន្យាខ្ចីបរិភោគដែរ ប៉ុន្តែការកំណត់នៅសម័យនោះមិនសូវទូលំទូលាយដូចបច្ចុប្បន្នទេ។ ពោលគឺគេបានចែងថាជាការជួលទុន ឬចងការចំពោះអត្រាការប្រាក់ គឺគូភាគីមិនអាចព្រមព្រៀងគ្នាយកការប្រាក់ឱ្យហួសពី ៨% ក្នុងមួយឆ្នាំនោះឡើយ។[2] អ្វីដែលប្លែកពីការខ្ចីប្រាក់នៅសម័យបច្ចុប្បន្ននោះ គឺបើម្ចាស់បំណុលយកការប្រាក់ហួសពីអត្រាការប្រាក់ដែលច្បាប់កំណត់ ម្ចាស់នោះត្រូវមានទោសតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។[3] បច្ចុប្បន្នការខ្ចីប្រាក់ខុសពីអត្រាការប្រាក់ ដែលច្បាប់កំណត់មិនមានទោសក្នុងរឿងព្រហ្មទណ្ឌឡើយ។ មួយវិញទៀត គឺការឱ្យខ្ចីបរិភោគវត្ថុដែលក្នុងនោះមិនបានកំណត់អត្រាការប្រាក់ទេ គ្រាន់តែមានបែងចែកថាអ្នកខ្ចីត្រូវរកវត្ថុដែលមានធនមានគុណភាព និងមានចំនួនដូចគ្នាសងតែប៉ុណ្ណោះ។[4] ចំពោះការខ្ចីវត្ថុ គឺមិនមានយកនូវការប្រាក់ទេ។[5]

អំឡុងពេលទទួលបានឯករាជ្យពេញលេញ ឆ្នាំ១៩៥៣-១៩៧៥ ក្រោមស្នាព្រះហស្តបូជនីយ៍កិច្ចរបស់ព្រះបាទនរោត្តមសីហនុ ប្រទេសកម្ពុជានៅតែបន្តប្រើប្រាស់បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០នេះដដែល។ កាលនៅសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាលបានព្យាយាមបង្កើតប្រព័ន្ធឥណទានជនបទតាមរយៈការបង្កើត **"រាជមន្ទីរសហករយើង"**ការបង្កើតសហករណ៍ផ្តល់ទុន និងការបង្កើតសហករណ៍ឧបភោគបរិភោគជាដើម។ ទាំងនេះជាប្រព័ន្ធដែលគ្រប់គ្រងដោយរដ្ឋ។ រដ្ឋបានលូកដៃចូលយ៉ាងជ្រៅទៅធ្វើអន្តរាគមន៍ទៅក្នុងការគ្រប់គ្រងនេះ។ ក្រោយពីបានដំណើរការមួយរយៈពេលមកប្រព័ន្ធដើរទៅមុខមិនរួចហើយនៅទីបំផុតក៏បរាជ័យមិនអាចដំណើរការធ្វើហិរញ្ញប្បទានបាន។[6]

---

[1]ដកស្រង់ពីកិច្ចសម្ភាសន៍កម្មវិធីច្បាប់(កិច្ចសន្យាខ្ចីបរិភោគ)នៅស្ថានីយ៍ទូរទស្សន៍បាយ័នរវាងលោកអេង រិទ្ធី និងមេធាវី អ៊ាងសុភ័ក្រ

[2] មាត្រា ១១៨៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០

[3] មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០

[4] មាត្រា ១២០៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០

[5] មាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០

[6] ដកស្រង់ពី សុន្ទកថាឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយអំពីសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជានៅខេត្តសៀមរាប នាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៥។

ក្នុងសម័យកាលឆ្នាំ ១៩៧៥-១៩៧៩ កម្មសិទ្ធិឯកជនទាំងឡាយត្រូវបានហាមឃាត់។ ស្បៀងអាហារ សម្ភារៈទ្រព្យសម្បត្តិផ្សេងៗត្រូវបានបញ្ចូលជាទ្រព្យសម្បត្តិសមូហភាព រូបិយប័ណ្ណត្រូវបានលុបបំបាត់ចោល។ ការជួញដូរ ឬពាណិជ្ជកម្មក្នុងស្រុកត្រូវបានធ្វើតាមរយៈការដោះដូររបស់គ្នាតែប៉ុណ្ណោះ ស្រូវត្រូវបានវាល់ជាកំប៉ុង ហើយបានក្លាយជាការដោះដូរជាធម្មតាសំខាន់បំផុតទោះបីជាអញ្ចឹងក៏ដោយក៏ប្រជាជនខ្លះ ដោះដូរមាស គ្រឿងអលង្ការ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដទៃទៀតដែរ។ ប៉ុន្តែសកម្មភាពបែបនេះមានតិចតួចណាស់ វាស្ទើរតែមិនមានព្រោះថានៅសម័យនោះ គឺការរស់នៅស្ថិតក្នុងគោលការណ៍ ហូបរួម ដេករួម ធ្វើការរួម។ ដូចច្នេះយើងអាចសន្និដ្ឋានបានថានៅសម័យនោះមិនសូវមានសកម្មភាពខ្ចីបុលកើតឡើងទេ។

បន្ទាប់ពីពួកកុម្មុយនិស្តខ្មែរក្រហមត្រូវបានផ្តួលរលំនៅខែមករាឆ្នាំ១៩៧៩ គឺសង្កេតឃើញថាមានការដោះដូរគ្នារវាងអង្ករជាមួយនឹងវត្ថុមានតម្លៃ ជាពិសេសមាស ដើម្បីដោះស្រាយគ្រោះទុរ្ភិក្ស និងខ្ចីគ្នាទៅវិញទៅមក។ នៅក្នុងឆ្នាំ១៩៨០ ប្រព័ន្ធធនាគារថ្មីមួយត្រូវបានបង្កើតឡើងជាប្រព័ន្ធធនគាមួយថ្នាក់។ ប្រព័ន្ធឥណទានត្រូវបានគ្រប់គ្រងដោយរដ្ឋ។ បរិមាណទុន និងអត្រាការការប្រាក់ត្រូវកំណត់ដោយរដ្ឋ ដើម្បីជៀសវាងពីការកេងប្រវ័ញ្ចពីអ្នកខ្ចី។ នៅទីបំផុតប្រព័ន្ធនេះដំណើរការដោយមិនមានប្រសិទ្ធិភាព តម្លាភាព និងសីលធម៌។ អ្នកខ្ចីបានចេះតែបាន អ្នកខ្ចីមិនបាននៅតែមិនបានខ្ចី ទីបំផុតអ្នកខ្ចីកេងប្រវ័ញ្ចពីរដ្ឋទៅវិញ។ បំណុលជាច្រើនក្លាយជាបំណុលអាក្រក់ទាមទារវិញមិនបាន ដែលធ្វើអោយរដ្ឋបាត់បង់ទុនជាច្រើន ក្នុងក្រឹត្យច្បាប់សម័យសាធារណរដ្ឋមានិតកម្ពុជា ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាបានចែងអំពីការខ្ចីដោយមានការប្រាក់ដែលក្នុងសម័យនោះអត្រាការប្រាក់គឺមិនឱ្យលើសពី ៥% ក្នុងមួយឆ្នាំ។ ចំពោះកិច្ចសន្យាដែលមិនកំណត់ថ្លៃសង និងមិនកំណត់ការប្រាក់ទេនោះ សន្មតថាគូភាគីព្រមព្រៀងចុះកិច្ចសន្យាសំរាប់រយៈពេល១ឆ្នាំដោយគ្មានការប្រាក់។[7]

## កថាខណ្ឌទី២៖ ការសិក្សាអំពីប្រវត្តិទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគក្រោយឆ្នាំ ១៩៩៣

នៅក្នុងឆ្នាំ ១៩៩៣ កម្ពុជាក្លាយជាព្រះរាជាណាចក្រកម្ពុជាមួយ ហើយបានបង្កើតរដ្ឋាភិបាលថ្មីមួយជាមួយនឹងការប្រកាសរដ្ឋធម្មនុញ្ញថ្មី។ ប៉ុន្តែច្បាប់ផ្សេងភាគច្រើនអនុវត្តតាមច្បាប់ចាស់ គឺច្បាប់នៅសម័យសាធារណរដ្ឋ។ នៅឆ្នាំ២០០៧ ក្រោមការជួយរបស់ប្រទេសជប៉ុនយើងចាប់ផ្តើមមានក្រមរដ្ឋប្បវេណីច្បាស់លាស់មួយ ដែលអនុវត្តរហូតដល់សព្វថ្ងៃ ស្របពេលជាមួយនឹងការវិវត្តខាងផ្នែកបច្ចេកវិទ្យា សេដ្ឋកិច្ចកម្ពុជាបានលូតទៅមុខជាលំដាប់។ នៅអំឡុងឆ្នាំ២០០៨ ប្រព័ន្ធធនាគារនៅកម្ពុជាត្រូវបានពង្រឹងតាមរយៈការរៀបចំ

---

[7] មាត្រា ៥៨ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

ប្រកាសសម្រាប់អនុវត្តច្បាប់មួយចំនួន និងបានធ្វើការកែសម្រួលនូវប្រកាសមួយចំនួនដូចជា ប្រកាសស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ និងប្រកាសដទៃទៀតឱ្យសមស្របជាមួយការអនុវត្តទៅស្តង់ដារអន្តរជាតិ ដើម្បីឱ្យការអនុវត្តមានភាពរលូន និងសមស្របតាមយន្តការទីផ្សារ។[8]

នាពេលបច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាបានអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។[9] មួយវិញទៀតនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍មួយចំនួនដូចជា ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដោយក្នុងនោះខិតខំសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចជាមធ្យមឱ្យបាន ៧%។

ជាក់ស្តែងនៅពេលបច្ចុប្បន្ននេះ មានអ្នកវិនិយោគជាតិ និងអន្តរជាតិជាច្រើនបានមកបណ្តាក់ទុនរកស៊ីនៅកម្ពុជាដែលធ្វើឱ្យវិស័យវិនិយោគ និងវិស័យឥណទានរីកដុះដាលយ៉ាងច្រើន។

ស្ថិតិស្តីអំពីចំនួនធនាគារដែលបានធ្វើការចុះបញ្ជីមកទល់ខែធ្នូ ឆ្នាំ២០០៨ នាពេលបច្ចុប្បន្ននេះមានធនាគារជាច្រើន ដែលកំពុងតែដំណើរការយ៉ាងសកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែមានការរីកចម្រើននៃវិស័យធនាគារទាំងនេះហើយ ដែលជាកត្តាជួយចូលរួមកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋខ្មែរបានមួយកម្រិតដែរ។

## ផ្នែកទី២៖ ខ្លឹមសារនៃកិច្ចសន្យាខ្ចីបរិភោគ

ចំពោះនិយមន័យនៃកិច្ចសន្យាខ្ចីបរិភោគ ត្រូវបានចែង និងកែសម្រួលទៅតាមសម័យកាលនីមួយៗ។

### កថាខណ្ឌទី១៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារក្រមរដ្ឋប្បវេណីចាស់

កិច្ចសន្យាខ្ចីបរិភោគ គឺជាការប្រគល់វត្ថុឱ្យប្រើប្រាស់ហើយវិចវិលបាត់អស់ទៅ កិច្ចសន្យានេះគឺជាកិច្ចសន្យាតម្រូវឱ្យអ្នកបរិភោគប្រគល់ត្រឡប់មកវិញនូវវត្ថុ ដែលមានប្រភេទដូចគ្នាគ្រប់ចំនួន មានគុណភាពស្មើទៅនឹងវត្ថុដែលបានខ្ចីនោះ។[10] **ឧទាហរណ៍៖** ការខ្ចីអង្ករអ្នកជិតខាងយកមកបរិភោគ រួចហើយសងអង្ករផ្សេងវិញ ឬការខ្ចីប្រាក់ចាយហើយសងវិញជាដើម។

ចំពោះការខ្ចីប្រាក់ពីធនាគារត្រូវបានចាត់ទុកថាជាកិច្ចសន្យាខ្ចីបរិភោគ។ ចំពោះការខ្ចីបរិភោគដែលតម្រូវឱ្យប្រគល់វត្ថុដែលមានប្រភេទដូចគ្នា គ្រប់ចំនួន ស្មើគុណភាព ដោយគ្មានបង់ការប្រាក់នោះ ក្រមរដ្ឋប្បវេណីកំណត់

---

[8] ព្រឹត្តិបត្រប្រចាំត្រីមាសរបស់ធនាគារនៃកម្ពុជា លេខ២៧ ត្រីមាសទី១ ឆ្នាំ២០០៩ ទំព័រទី៤ ចេញផ្សាយប្រកាសលេខ ធ១-០២-១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

[9] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[10] សៀវភៅណែនាំសិក្សា ច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន) ឆ្នាំ២០០០

ថា ជាកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ ក៏ប៉ុន្តែចំពោះកិច្ចសន្យាដែលមានភ្ជាប់នូវការប្រាក់ដូចជា ការខ្ចីប្រាក់ពីធនាគារជាដើម។ យើងយល់ថាមានលទ្ធភាពអាចបកស្រាយបានថាជាកិច្ចសន្យាត្រឹមការព្រមព្រៀង។

**កថាខណ្ឌទី២៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រឹត្យច្បាប់លេខ៣៨**

កម្ចីបរិភោគ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាងប្រគល់នូវបរិមាណនៃវត្ថុពិតប្រាកដ ដល់ភាគីម្ខាងទៀត។ ចំនួនបរិមាណនៃវត្ថុត្រូវបានប្រើប្រាស់ដោយអ្នកខ្ចីដែលនឹងត្រូវសងទៅអ្នកឱ្យខ្ចីនូវប្រភេទ បរិមាណ និងគុណភាព នៃវត្ថុទៅឱ្យអ្នកខ្ចី។[11] **ឧទាហរណ៍៖** លោក ក បានខ្ចីអង្ករផ្កាម្លិះពី លោក ខ ចំនួន ៣០គីឡូក្រាម ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ភាគីទាំងពីរបានព្រមព្រៀងគ្នាថា ត្រូវប្រគល់សងវិញនៅ ១០ថ្ងៃ ក្រោយនៃការខ្ចីនោះ ហើយអង្ករនោះត្រូវតែជាអង្ករផ្កាម្លិះ។ ដូច្នេះនៅពេលដល់ពេលកំណត់លោក ក មានកាតព្វកិច្ចត្រូវប្រគល់អង្ករផ្កាម្លិះ ៣០គីឡូក្រាម មកឱ្យលោក ខ វិញ។

**កថាខណ្ឌទី៣៖ កិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧**

ពាក្យ ការខ្ចីបរិភោគ សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ឬស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេល នោះបានកន្លងផុតអ្នកខ្ចីមានករណីយកិច្ចសងទៅអ្នកឱ្យខ្ចីនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។[12] មានន័យថាក្នុងករណីដែលអ្នកឱ្យខ្ចី បានឱ្យអ្នកខ្ចី ខ្ចីប្រាក់ ឬ ស្រូវ អ្នកខ្ចីនោះមានសិទ្ធិសេរីភាពនូវក្នុងការប្រើប្រាស់ ចាត់ចែង អាស្រ័យផល ទៅលើប្រាក់ ឬស្រូវនោះបាន។ រីឯអ្នកខ្ចីនោះ ត្រូវមានករណីយកិច្ចសងទៅអ្នកឱ្យខ្ចីវិញ នូវប្រាក់ដែលមានចំនួនស្មើគ្នា ឬស្រូវដែលមានបរិមាណដូចគ្នា ប្រភេទដូចគ្នា ក្រោយពីភាគីទាំងពីរបានព្រមព្រៀងគ្នាកំណត់អំឡុងពេលសង។ ចំពោះកិច្ចសន្យាខ្ចីបរិភោគ វាមានពីរប្រភេទគឺ កិច្ចសន្យាភ្ជាប់ការប្រាក់ និងកិច្ចសន្យាគ្មានភ្ជាប់ការប្រាក់ ហើយចំពោះកិច្ចសន្យាដែលភ្ជាប់ការប្រាក់គឺជាវិធីដ៏សំខាន់មួយសម្រាប់សកម្មភាពសេដ្ឋកិច្ច។

## ផ្នែកទី៣៖ ការកំណត់កម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគ

**កថាខណ្ឌទី១៖ ករណីកម្មវត្ថុជាវត្ថុ**

វត្ថុដែលត្រូវខ្ចីបរិភោគ ត្រូវតែជាវត្ថុមួយដែលជាក់លាក់ដែលអាចធ្វើឱ្យកិច្ចសន្យាខ្ចីបរិភោគបានធ្វើការសម្គាល់ ឬក៏អាចកំណត់ជាក់លាក់នូវរូបរាង បរិមាណ និងគុណភាព។ ពាក្យថាវត្ថុនៅក្នុងន័យនេះអាចជាអចលនវត្ថុ និងចលនវត្ថុ។ វត្ថុក្នុងកិច្ចសន្យាមានពីរប្រភេទដូចខាងក្រោម៖

[11] មាត្រា៩៨ ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨
[12] មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ចលនវត្ថុ៖ គឺជាវត្ថុដែលអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧទាហរណ៍៖ ម៉ូតូ ឡាន សៀវភៅ តុ ទូរកៅអី....។
- អចលនវត្ថុ៖ គឺជាវត្ថុដែលមានស្ថានភាពជាប់នឹងកន្លែងតែមួយ កម្រើកមិនកើត ឬមិនអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧទាហរណ៍៖ ដី សំណង់ អាគារ...។

វត្ថុនៅក្នុងកិច្ចសន្យា គឺត្រូវតែជាវត្ថុមួយជាក់លាក់ (អាចកំណត់បាន) ដែលធ្វើទៅកើត និងស្របច្បាប់ របៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ។ ចំពោះកម្មវត្ថុដែលជាក់លាក់ គឺជាវត្ថុដែលត្រូវកំណត់ ឬអាចកំណត់បាន មានន័យថាភាគីក្នុងកិច្ចសន្យាមានលទ្ធភាពវាស់ ឬស្ទង់នូវទំហំកាតព្វកិច្ចរបស់ខ្លួនបាន។

វត្ថុដែលអាចធ្វើទៅកើតគឺជាកម្មវត្ថុនៃកិច្ចសន្យាដែលមនុស្សទូទៅអាចធ្វើកើត ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យានោះធ្វើមិនកើតទេ គឺបណ្តាលឱ្យកិច្ចសន្យាមោឃភាព។ ភាពមិនអាចធ្វើទៅកើតដែលធ្វើឱ្យកិច្ចសន្យារងនូវការមោឃភាព គេត្រូវពិនិត្យមើលទៅលើ ភាពអាចធ្វើកើត ឬមិនអាចធ្វើកើត ថាវាមានលក្ខណៈដាច់ខាតដែរ ឬទេ? បើវាមានលក្ខណៈដាច់ខាតនោះកិច្ចសន្យានឹងត្រូវមោឃភាព។ ផ្ទុយទៅវិញបើមានលក្ខណៈមិនដាច់ខាតទេកិច្ចសន្យានោះមានសុពលភាព។

កម្មវត្ថុស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ បានន័យថាកម្មវត្ថុនៃកិច្ចសន្យាដែលស្របច្បាប់មិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ទាល់តែកម្មវត្ថុនៃកិច្ចសន្យាស្ថិតក្នុងពាណិជ្ជកម្ម។ កម្មវត្ថុដែលមិនស្របច្បាប់មានដូចជា៖

- វត្ថុទាំងឡាយណាដែលជាទ្រព្យសម្បត្តិរបស់សាធារណៈរដ្ឋ
- កិរិយារបស់ភាគីដែលជាការប្រព្រឹត្តអំពើអ្វីមួយដែលច្បាប់បានហាមឃាត់។

វត្ថុមួយចំនួនទៀតដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ដូចជា អាវុធ គ្រឿងញៀន គ្រឿងផ្ទុះជាដើម មិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាទេ។ សរីរាង្គមនុស្ស ក៏មិនអាចក្លាយជាកម្មវត្ថុនៃកិច្ចសន្យាបានដែរ តែបើករណីដែលកិច្ចសន្យានោះធ្វើអំណោយដោយស្ម័គ្រចិត្តរបស់ភាគីនោះគឺអាចធ្វើបាន។

**កថាខណ្ឌទី២៖ ករណីកម្មវត្ថុជាប្រាក់**

ប្រាក់ សំដៅទៅលើរូបិយវត្ថុដែលមានតម្លៃហើយអាចចរចារបាន។ ប្រាក់ គឺជាផលិតផលមួយយ៉ាងសំខាន់នៅក្នុងទីផ្សារសេដ្ឋកិច្ច ដើម្បីបង្កើតលក្ខណៈងាយស្រួលដល់ដំណើរការដោះដូរទំនិញ ឬសេវាកម្ម។

រូបិយវត្ថុជាវត្ថុមួយដែលត្រូវបានគេប្រើប្រាស់ជាមធ្យោបាយដើម្បីដោះដូរទំនិញ ឬសេវាកម្ម និងទូទាត់បំណុលផ្សេងៗទៀត។ រូបិយវត្ថុ ក៏ជាអ្វីៗដែលត្រូវបានគេទទួលស្គាល់ក្នុងការទូទាត់ជាមួយទំនិញ ឬសេវាកម្ម និងទូទាត់បំណុលផ្សេងៗទៀត។ រាល់គ្រប់រូបិយវត្ថុបរទេសត្រូវគិតទៅតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិ។ **ឧទាហរណ៍៖** ប្រាក់ដុល្លារ ប្រាក់យេន ប្រាក់រៀល...។ ករណីកម្មវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យាជាប្រាក់ ករណី

កិច្ចសន្យាដែលជាកម្មវត្ថុតាវកាលិកជាស្នាដៃរបស់មនុស្ស តំលៃនៃការងារមិនចាំបាច់កំណត់មុនក៏បាន ដូចជាមាត្រា៧២ នៃក្រឹត្យច្បាប់លេខ៣៨ គឺកិច្ចសន្យា សហគ្រាស ជាកិច្ចសន្យាដែលបុគ្គលម្នាក់ៗទទួលបន្ទុកការងារអ្វីមួយឱ្យបុគ្គលម្នាក់ទៀតដោយយកតំលៃសមស្របនឹងទំហំការងារនោះ។ ក្នុងមាត្រា៧២ នេះបញ្ជាក់ថ្លៃការងារអាចនឹងមិនកំណត់ក្នុងកិច្ចសន្យាបាន ព្រោះមាត្រានៃក្រឹត្យច្បាប់នេះបញ្ជាក់ថា ប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យាទេ តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំហំនៃកន្លែងធ្វើការនោះ។

បើទោះបីជារូបិយវត្ថុ ឬតម្លៃវត្ថុមានការប្រែប្រួលនៅមុនពេលសងក៏ដោយលើកលែងតែក្នុងករណីដែលមានការព្រមព្រៀង ពិសេសអ្នកខ្ចីត្រូវសងចំនួនទឹកប្រាក់ដូចគ្នានឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់។ នៅចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើងរហូតដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់ចុះយ៉ាងខ្លាំងដែលនឹងធ្វើឱ្យឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន។

# ជំពូកទី២
# ការបង្កើតកិច្ចសន្យាខ្ចីបរិភោគតាម
# ខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី២

# ការបង្កើតកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ។[13] កិច្ចសន្យាខ្ចីបរិភោគ គឺជាកិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ (កិច្ចសន្យាដែលបង្កើតអានុភាពដោយប្រគល់វត្ថុ)។ ក៏ប៉ុន្តែក្រៅពីកិច្ចសន្យាប្រភេទនេះ នៅក្នុងប្រទេសជាច្រើន គេបានទទួលស្គាល់ថា កិច្ចសន្យាខ្ចីបរិភោគដែលបង្កើតឡើងដោយកិច្ចព្រមព្រៀង (កិច្ចសន្យាខ្ចីបរិភោគដោយការព្រមព្រៀង ឬការសន្យាជាមុននូវការខ្ចីបរិភោគ)។ ជាទូទៅកិច្ចសន្យាប្រភេទនេះ គឺនិយមប្រើយ៉ាងទូលំទូលាយដើម្បីបំពេញកិច្ចការសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។ ដូច្នោះហើយបានជានៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងពីកិច្ចសន្យាខ្ចីបរិភោគដែលអាចបង្កើតដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ។

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបែងចែកជា ២ ប្រភេទគឺៈ

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់
- កិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់

## ផ្នែកទី១ៈ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺជាកិច្ចសន្យាខ្ចីបរិភោគដែលយកតម្លៃថ្នូរ បានន័យថាភាគីអាចបង្កើតកិច្ចសន្យាដោយយកការប្រាក់ចំពោះការខ្ចីបរិភោគដែលការប្រាក់នេះតម្រូវឱ្យតែធ្វើជាលាយលក្ខណ៍អក្សរជាដាច់ខាត និងត្រូវមាននូវការចុះហត្ថលេខារបស់ភាគីទើបការខ្ចីបរិភោគនេះមានអានុភាពចំពោះសិទ្ធិលើបំណុលនៃការប្រាក់។

### កថាខណ្ឌទី១ៈ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

ដោយយោងតាមខ្លឹមសារនៃមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី គឺមានន័យថាការបង្កើតកិច្ចសន្យាខ្ចីបរិភោគត្រូវធ្វើឡើងដោយបុគ្គលពីរនាក់ដែលមានសមត្ថភាពតាមផ្លូវច្បាប់ធ្វើការព្រមព្រៀងគ្នា និងមានកម្មវត្ថុមួយជាក់លាក់ ក្នុងការបង្កើតកិច្ចសន្យាមួយដែលមានជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាទាំងឡាយអាចយកជាការបានលុះត្រាតែកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះ ដែលអាចកើតចេញពីការព្រមព្រៀងនៃគូភាគីក៏ដូចជាចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា និងចំពោះកម្មវត្ថុមួយដែលជាក់លាក់ ដែលអាចកើតឡើងស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ល្អ។

[13] មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ១. ការព្រមព្រៀងបង្កើតការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

ជាគោលការណ៍នៅក្នុងប្រទេសកម្ពុជា គឺជ្រើសរើសយកគោលការណ៍នៃឆន្ទៈជាគោល។ ដូច្នោះហើយក្នុងប្រតិបត្តិការនៃកិច្ចសន្យាខ្ចីបរិភោគ គឺត្រូវការគោលការណ៍នៃឆន្ទៈជាសំខាន់ និងជាកត្តាចាំបាច់បំផុតស្របតាមមាត្រា ៣ (គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន) នៃក្រមរដ្ឋប្បវេណី។ មួយវិញទៀតការព្រមព្រៀង គឺជាធាតុផ្សំមួយដ៏សំខាន់របស់កិច្ចសន្យា។ ប្រសិនបើការព្រមព្រៀងនេះគ្រាន់តែជាការបង្ហាញឆន្ទៈខាងក្នុងនោះទេ វាមិនមានអានុភាពគតិយុត្តិទេ។ ប៉ុន្តែប្រសិនបើវាត្រូវបានសំដែងចេញតាមរយៈឆន្ទៈខាងក្រៅដូចជាការចុះហត្ថលេខា ឬការផ្តិតមេដៃនោះទើបវាបង្កើតឱ្យមានអានុភាពគតិយុត្តិ។ ការសំដែងឆន្ទៈច្បាស់លាស់នេះច្រើនសំដែងឡើងតាមរយៈពាក្យសំដី ឬការសរសេរជាលាយលក្ខណ៍អក្សរ។

កាលណាមានការព្រមព្រៀង នាំឱ្យកិច្ចសន្យាមានអានុភាពដោយពុំចាំបាច់ធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែដើម្បីមានភាពច្បាស់លាស់នៃកិច្ចសន្យា ភាគីគួរណាស់តែធ្វើជាលាយលក្ខណ៍អក្សរ។

ជាទូទៅចំពោះកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ដាច់ខាត ត្រូវបង្កើតឡើងដោយមានសរសេរជាលាយលក្ខណ៍អក្សរទើបកិច្ចសន្យាខ្ចីបរិភោគមានអានុភាព ព្រោះការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ត្រូវបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ហេតុនេះហើយ បើគ្មានលិខិតជាលាយលក្ខណ៍អក្សរទេនោះពុំមានអានុភាពនៃការប្រាក់ឡើយ។ លើសពីនេះទៅទៀតកិច្ចសន្យាខ្ចីបរិភោគ ត្រូវបង្កើតឡើងដោយមានការព្រមព្រៀងរបស់ភាគីទាំងសងខាង ហើយភាគីក៏អាចបង្កើតកិច្ចសន្យាដែលមាន កម្មវត្ថុសងជាការប្រាក់បានដែរតាមរយៈការព្រមព្រៀងបង្កើតនូវសិទ្ធិលើបំណុល។ ហើយដើម្បីឱ្យសិទ្ធិលើបំណុល ដែលមានភ្ជាប់ការប្រាក់មានអានុភាពបាន លុះត្រាតែការព្រមព្រៀងនោះត្រូវធ្វើជាទម្រង់លាយលក្ខណ៏អក្សរដោយភាគីត្រូវផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាក្នុងកិច្ចសន្យា។

កិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ គឺអ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចប្រគល់វត្ថុឱ្យទៅអ្នកខ្ចី ហើយវត្ថុដែលប្រគល់នោះត្រូវតែជាវត្ថុដែលគ្មានវិការៈ (វត្ថុដែលមានសភាពល្អធម្មតា)។ ដោយឡែកប្រសិនបើវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ឱ្យអ្នកខ្ចីជាវត្ថុដែលមានវិការៈកំបាំងហើយអ្នកខ្ចីពុំបានដឹងអំពីវិការៈទេ នោះអ្នកខ្ចីអាចទាមទារឱ្យអ្នកឱ្យខ្ចីប្តូរមកនូវវត្ថុដែលគ្មានវិការៈមកឱ្យខ្លួនវិញបាន។

### ២. កម្មវត្ថុ និងមូលហេតុនៃការបង្កើតការខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់

តាមគោលការណ៍សេរីភាពនៅក្នុងការធ្វើកិច្ចសន្យាភាគីអាចកំណត់ថាអានុភាពនៃកិច្ចសន្យាអាចនឹងកើតឡើងនៅពេលដែលធ្វើកិច្ចសន្យាជាលិខិតលាយលក្ខណ៍អក្សរ ឬនៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះបាន។

### ២.១ កម្មវត្ថុនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះ ចំពោះការខ្ចីសាច់ អង្ករ គ្រាប់ធញ្ញជាតិ ដែលមានលក្ខណៈតិចតួចគេមិនសូវសរសេរជាលិខិតលាយលក្ខណ៍អក្សរប៉ុន្មានទេ គឺមានតែការខ្ចីណាដែលធំដុំ ដែលមានភ្ជាប់ការប្រាក់តែប៉ុណ្ណោះនិងតម្រូវចាំបាច់ ដើម្បីធ្វើជាភស្តុតាងនៅពេលមានវិវាទកើតឡើង។ កម្មវត្ថុក្នុងកិច្ចសន្យា គឺសំដៅទៅលើប្រតិបត្តិការគតិយុត្តិដែលភាគីទាំងឡាយចង់ធ្វើដោយក្នុងកម្មវត្ថុនោះបង្ហាញថា ជាកម្មវត្ថុដែលបានកំណត់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។ ចំពោះកម្មវត្ថុដែលអាចបង្កើតឡើងកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ប្រាក់គឺជារបស់មួយដែលគូរភាគីត្រូវតែផ្តល់ឱ្យគូរសន្យារបស់ខ្លួន គឺតាមរយៈការប្រគល់វត្ថុ ឬប្រាក់ចំពោះការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់នេះឯង។

### ២.២ មូលហេតុនៃការបង្កើតការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

ចំពោះប្រតិបត្តិការខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់នេះ តែងកើតមានឡើងជាប្រចាំផងដែរ មិនថាជាសង្គមណាៗនោះទេ ពីព្រោះវាជាទំនាក់ទំនងរវាងប្រជាពលរដ្ឋដែលរស់នៅជាប្រចាំ។ រីឯអ្នកមានទ្រព្យស្តុកស្តម្ភ និងអ្នកដែលត្រូវការប្រតិបត្តិការក្នុងជំនួញជួញដូររបស់ខ្លួន និងអ្នកដែលត្រូវប្រើប្រាស់នូវថវិការនោះសំរាប់តម្រូវការជាក់ស្តែងសម្រាប់ជីវភាពរបស់ខ្លួនជាប្រចាំតែងត្រូវមានការដោះដូរ ហើយតែងមាននូវការខ្ចីប្រាក់ទៅវិញទៅមក ដែលជាមធ្យោបាយទូទាត់ទំនិញប្រចាំថ្ងៃសំរាប់ការរស់នៅ ។

ជាទូទៅនៅពេលណាដែលមានការបង្កើតការខ្ចីបរិភោគដែលភ្ជាប់ការប្រាក់ ពោលគឺម្ចាស់បំណុលតែងចង់បាននូវផលប្រយោជន៍នៃការខ្ចីប្រាក់នោះ។ រីឯការប្រាក់ គឺជាផលប្រយោជន៍ដែលកើតឡើងមានក្នុងអំឡុងពេល សុពលភាពក្នុងអំឡុងពេលប្រើប្រាស់ប្រាក់ដើម។ ចំណែកឯការប្រាក់នេះដែរ ដើម្បីទទួលបានភាពច្បាស់លាស់ យើងគួរគម្បីធ្វើឡើងជាលាយលក្ខណ៍អក្សរ។ **ឧទាហរណ៍៖** បុរស ក បានខ្ចីប្រាក់ពី បុរស ខ ចំនួន ១០,០០០ដុល្លារ ដោយកំណត់អត្រាការប្រាក់១០%ក្នុងមួយឆ្នាំ។ ដូចនេះបុរស ខ អាចទទួលបានផលប្រយោជន៍ពីការប្រាក់ ១០០$ ក្នុងមួយខែ នៃការខ្ចីប្រាក់របស់ បុរស ក ។ នេះបានបញ្ជាក់ពីផលប្រយោជន៍នៃការប្រើប្រាស់ប្រាក់ដើមក្នុងអំឡុងពេល សុពលភាពនៃកិច្ចសន្យា។

### ៣. សមត្ថភាពភាគីនៃការបង្កើតខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

សមត្ថភាព គឺសំដៅដល់សមត្ថភាពនៅក្នុងការអនុវត្តសិទ្ធិ និងអនុវត្តតាមកាតព្វកិច្ចក្រោមច្បាប់។ ចំពោះសមត្ថភាពត្រូវបានកំណត់ដោយកត្តាមួយចំនួន ដែលពឹងផ្អែកលើក្រមរដ្ឋប្បវេណីនៃប្រទេសនីមួយៗ (ដូចជាអាយុស្របតាមច្បាប់) ឬដោយលក្ខខណ្ឌផ្ទាល់ខ្លួន (មិនមានបញ្ញា ឬរាងកាយមិនអាចទទួលបាននូវសិទ្ធិ ឬគោរពតាមកាតព្វកិច្ច)។ យើងបានដឹងហើយថា សិទ្ធិរបស់រូបវន្តបុគ្គលមានចាប់តាំងពីពេលចាប់

កំណើតមកម្ល៉េះ ដូចជា សិទ្ធិរស់រានមានជីវិត សេរីភាពនៅក្នុងការដើរហើរ ឬសិទ្ធិទទួលបានគាំពារតាមផ្លូវច្បាប់ ជាដើម។

រីឯអានុភាពតាមផ្លូវច្បាប់មួយដែលច្បាប់ទទួលស្គាល់លើការសម្រេចចិត្ត និងការសំដែងឆន្ទៈ។

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួន។ ចំពោះបុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ ប៉ុន្តែបុគ្គលគ្រប់រូបមិនមែនសុទ្ធតែអាចធ្វើកិច្ចការជំនួញ ដែលមានសុពលភាពដោយឯករាជ្យគ្រប់ពេលនោះទេ។

### ៣.១ ករណីតាគីទាំងសងខាងជារូបវន្តបុគ្គល

រូបវន្តបុគ្គល សំដៅទៅលើមនុស្សមានសាច់ ឈាម អាចមើលឃើញ អាចប៉ះបាន និងរស់រានមានជីវិត សំដៅដល់បុគ្គលម្នាក់ៗតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។[14] ដើម្បីអាចឱ្យរូបវន្តបុគ្គលធ្វើសកម្មភាពដែលច្បាប់ទទួលស្គាល់បាន គឺរូបវន្តបុគ្គលត្រូវមានសមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាពជាមុនសិនទើបអាចអនុវត្តនូវសកម្មភាពរបស់ខ្លួនបានដោយសេរី។ មួយវិញទៀតរូបវន្តបុគ្គល គឺជាតួអង្គឯកមួយរូប ដែលធ្វើសកម្មភាពគតិយុត្តិបង្កើតបានជាសិទ្ធិ និងកាតព្វកិច្ច។

សមត្ថភាពទទួលបានសិទ្ធិ គឺជាឋានៈដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។[15] ប្រធាននៃសិទ្ធិ និងប្រធាននៃកាតព្វកិច្ច គឺជាការបើកផ្លូវឱ្យរូបវន្តបុគ្គលធ្វើសកម្មភាពទំនាក់ទំនងផ្នែកឯកជនបានគ្រប់យ៉ាងឱ្យតែមិនបំពានច្បាប់។ អ្វីដែលយើងត្រូវចាំនោះគឺ រូបវន្តបុគ្គលទទួលបានសមត្ថភាពទទួលសិទ្ធិតាមផ្លូវច្បាប់នេះនៅពេលចាប់កំណើត ហើយត្រូវបានបាត់បង់សមត្ថភាពទទួលសិទ្ធិនេះទៅវិញនៅពេលរូបវន្តបុគ្គលនោះទទួលមរណភាព។ យោងទៅតាមមាត្រា ៨ ពេលចាប់ផ្ដើម និងបញ្ចប់សមត្ថភាពទទួលសិទ្ធិនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងយ៉ាងច្បាស់ថា រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាទទួលបានសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះនៅពេលមរណភាព។[16]

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចឱ្យរូបវន្តបុគ្គលយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបាន។ ចំពោះអ្វីដែលយើងត្រូវយល់អំពី សមត្ថភាពខាងឆន្ទៈ គឺការលុបចោលនូវសកម្មភាពដែលធ្វើការបង្ហាញចេញមកដោយគ្មានសមត្ថភាពឆន្ទៈ គឺសម្រាប់ការពារកុំឱ្យមានការខូចខាតដោយកិច្ចការជួញដូរ ទិញលក់របស់រូបវន្តបុគ្គលដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ។ បើទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏ជននេះអាចលុបចោលសកម្មភាពដែលខ្លួន

[14] សន្ទានុក្រមផ្នែករដ្ឋប្បវេណី ២០០៧ លេខ ១២៧ទំព័រ១៩

[15] មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ២០១៥

[16] មាត្រា៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងក្នុងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ពាក្យ “សកម្មភាព” ដែលនិយាយពីខាងលើ គឺជាសកម្មភាពធ្វើកិច្ចសន្យា និងសកម្មភាពឯកតោភាគី។ សកម្មភាពកិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។ ហើយសកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។

សមត្ថភាពក្នុងការធ្វើសកម្មភាព គឺសំដៅទៅលើរូបវន្តបុគ្គល ដែលមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើសកម្មភាពគតិយុត្តិ។ បើយោងតាមក្រមរដ្ឋប្បវេណី មាត្រា១៦ អត្ថន័យជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព បានចែងថាជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើ អនីតិជន ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ និងជនស្ថិតក្រោមហិតូបត្ថម្ភ។ បើពិនិត្យអំពីអត្ថន័យជន ដែលត្រូវបានកម្រិតសមត្ថភាពនេះបានឱ្យឃើញថា ក្រៅពីរូបវន្តបុគ្គលដែលជាអនីតិជន ជនក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ គឺជារូបវន្តបុគ្គលគ្រប់រូបមានសមត្ថភាពអាចធ្វើសកម្មភាពពេញលេញតាមផ្លូវច្បាប់។

អនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ។ [17] ចំពោះអនីតិជន ប្រសិនបើមិនមានការយល់ព្រមពីអ្នកអាណាព្យាបាលទេ នោះអនីតិជននោះមិនអាចធ្វើសកម្មភាពអ្វីបានទេ។ [18] អនីតិជនត្រូវបានកម្រិតសមត្ថភាពផងដែរ រាល់សកម្មភាពដែលអនីតិជនបានធ្វើចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានសិទ្ធិអាណាព្យាបាល ពោលគឺជាគោលការណ៍អនីតិជនមិនមានសមត្ថភាពចុះកិច្ចសន្យាទេ។ ប៉ុន្តែមានករណីលើកលែងផងដែរ ដែលអាចអនុញ្ញាតឱ្យអនីតិជនធ្វើសកម្មភាពនោះបាន ពោលគឺទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់អាណាព្យាបាល សំរាប់អនីតិជនមិនអាចលុបចោលសកម្មភាព តែត្រូវកំណត់ថា តើសកម្មភាពបែបណាខ្លះដែលចាត់ទុកជាសកម្មភាពប្រចាំថ្ងៃ? ដែលអនីតិជនអាចធ្វើសកម្មភាពបាន ដែលនៅក្នុងបទប្បញ្ញត្តិច្បាប់មិនបានកំណត់ឱ្យបានច្បាស់លាស់នោះទេ។ អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង ក្នុងទំហំនៃគោលបំណងដែលបានកំណត់។ [19] ម៉្យាងវិញទៀតអនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់

[17] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[19] មាត្រា ១៩ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ។[20] **ឧទាហរណ៍៖** ករណីដែលឱ្យឪពុកម្តាយបានអោយលុយកូនចំនួន ១០០$ សំរាប់ការចាយវាយផ្ទាល់ខ្លួន ដូចនេះអនីតិជនអាចយកលុយនោះទៅធ្វើការចាយវាយប្រើប្រាស់ទិញទំនិញបាន។

ចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ សំដៅទៅលើជនដែលមានសមត្ថភាពតិចតួចពេកនៅក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី។ [21] ជាពិសេសការខ្ចីទ្រព្យ ឬការធានានៅក្នុងចំណុចនេះគឺបានក្តោបទាំងកិច្ចសន្យាខ្ចីបរិភោគផងដែរ ព្រោះទ្រព្យនេះគឺអាចនិយាយបានថាទាំងជាចលនទ្រព្យ និងអចលនទ្រព្យក៏កម្មវត្ថុបានចូលទៅក្នុងចលនវត្ថុនោះទាំងអស់ដែរ[22] ។ ហេតុដូចនេះហើយ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ គឺគ្មានសមត្ថភាពចុះនូវកិច្ចសន្យាខ្ចីបរិភោគទេ ប៉ុន្តែច្បាប់ក៏មានបញ្ញត្តិករណីលើកលែងផងដែរចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ ពោលគឺអាចធ្វើសកម្មភាពមួយចំនួនដោយមិនចាំបាច់មានការអនុញ្ញាតពីហិតូបត្ថម្ភកៈនោះទេ ហើយក៏មិនអនុញ្ញាតឱ្យលុបចោលសកម្មភាពវិញទេ។ រីឯសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃនោះមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ។ លើសពីនេះទៅទៀតយើងត្រូវដឹងថាកម្មវត្ថុនៃការខ្ចីបរិភោគកម្រិតណា ដែលអាចចាត់ទុកជាតម្រូវការប្រចាំថ្ងៃ ឬត្រឹមតែកម្រិតនៃការប្រើប្រាស់ធម្មតារបស់បុគ្គលនោះប៉ុណ្ណោះ ដែលអ្នកមានសិទ្ធិលុបចោលមិនអាចលុបបាននូវសកម្មភាពនោះបានទេ។ ហិតូបត្ថម្ភកៈអាចផ្តល់ដល់ការយល់ព្រមទៅជននៅក្រោមហិតូបត្ថម្ភចំពោះសកម្មភាព ដែលមានបញ្ញត្តិមាត្រា៣០ ប៉ុន្តែមិនមានសិទ្ធិតំណាងឱ្យសាមីខ្លួនទេដែលខុសពីអ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាលទូទៅ។ បានន័យថាហិតូបត្ថម្ភកៈ មិនអាចចុះកិច្ចសន្យាក្នុងនាមជាអ្នកតំណាងឱ្យជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភបានទេ។

ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅនេះ ជាមនុស្សស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានបញ្ហាផ្នែកស្មារតី។[23] ជនដែលទទួលបានការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថាជាជននៅក្រោមអាណាព្យាបាលទូទៅ និងត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ។[24] យោងទៅតាមបញ្ញត្តិខាងលើគឺជនដែលមានបញ្ហាស្មារតីជានិរន្តរ៍នោះពុំមានសមត្ថភាពចុះកិច្ចសន្យានោះទេ។

---

[20] មាត្រា ១៩ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[21] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ២១-១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[24] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជាគោលការណ៍ច្បាប់បានបញ្ញត្តិថា មានតែនីតិជនដែលមានសមត្ថភាពចុះកិច្ចសន្យា តែទោះជាយ៉ាងណាក៏មានករណីអញ្ញត្តត្រកម្មដែលបានអនុញ្ញាតឱ្យអនីតិជនចុះកិច្ចសន្យាផងដែរ។

### ៣.២ ករណីភាគីទាំងសងខាងជានីតិបុគ្គល

ផ្អែកទៅតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី នីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយមានភាពពេញលេញជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។ នៅក្នុងន័យនេះ នីតិបុគ្គលអាចជាមនុស្សមួយក្រុមប្រមូលផ្តុំ (សាជីវកម្ម) ឬបណ្តុំនៃទ្រព្យសម្បត្តិ (មូលនិធិ) ដែលត្រូវបានច្បាប់ប្រគល់ឱ្យនូវឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។ ក្នុងន័យនេះគឺ ពួកគេអាចជាភាគីនៃកិច្ចសន្យាមានកម្មសិទ្ធិ ឬទទួលខុសត្រូវចំពោះមុខច្បាប់បានក្នុងនាមសាជីវកម្ម ឬមូលនិធិនោះផ្ទាល់ដែលជានីតិបុគ្គល។

នីតិបុគ្គលគឺជាបណ្តុំនៃរូបវន្តបុគ្គល ជាអង្គការ ឬស្ថាប័នដែលមានបុគ្គលភាពគតិយុត្តិហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ នីតិបុគ្គលជាបុគ្គលពុំមានសាច់ឈាមដូចរូបវន្តបុគ្គលនោះទេ ហេតុដូចនេះប្រសិនបើនីតិបុគ្គលនោះចង់ធ្វើសកម្មភាពរស់ខ្លួន លុះត្រាតែមានអ្នកតំណាងទើបអាចចុះកិច្ចសន្យាបាន។

បុគ្គលភាពគតិយុត្តិរបស់នីតិបុគ្គលជាសមត្ថភាពតាមផ្លូវច្បាប់ ហើយច្បាប់បានទទួលស្គាល់បានន័យថាកាលណាមានបុគ្គលភាពគតិយុត្តិនោះនីតិបុគ្គលមានសមត្ថភាពដូចគ្នានឹងនីតិជនផងដែរ ហើយសមត្ថភាពទាំងនោះមានដូចជា ការធ្វើបណ្តឹង ការចុះកិច្ចសន្យា។ ចំណែកឯលក្ខណៈនៃនីតិបុគ្គលក៏មិនមានភាពខុសគ្នាទៅនឹងរូបវន្តបុគ្គលប៉ុន្មាននោះទេមានដូចជា ៖

- មានសញ្ជាតិ
- នាមករណ៍ សំដៅទៅលើឈ្មោះនៃនីតិបុគ្គលនោះ
- ចុះបញ្ជី ដើម្បីមានបុគ្គលភាពគតិយុត្តិ លុះត្រាតែមានចុះបញ្ជីនៅក្រសួងពាក់ព័ន្ធ នៃនីតិបុគ្គលនោះ
- លំនៅដ្ឋាន៖ សំរាប់នីតិបុគ្គលអាចហៅថា ទីស្នាក់ការសំរាប់លំនៅដ្ឋានរបស់នីតិបុគ្គលជាកន្លែងសំរាប់ធ្វើទំនាក់ទំនងនៃសកម្មភាពដែលពាក់ព័ន្ធទៅនឹងនីតិបុគ្គលនោះ។ លក្ខណៈដែលបានលើកយកមកធ្វើការបង្ហាញខាងលើនេះ ជាអ្វីដែលមាននូវសារៈសំខាន់សំរាប់កិច្ចសន្យា ព្រោះជាប់មានទំនាក់ទំនងជាមួយសមត្ថភាពទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដែលភាគីជានីតិបុគ្គលត្រូវបំពេញ។

### ៣.៣ ករណីភាគីជារូបវន្តបុគ្គល និងនីតិបុគ្គល

ចំពោះរូបវន្តបុគ្គល យើងងាយនឹងកំណត់បានព្រោះជាមនុស្សមានរូបរាងសុទ្ធសាធតែម្តង។

ចំណែកឯនីតិបុគ្គលប្រៀបដូចជាមនុស្សជាម្ចាស់សិទ្ធិ បានន័យថាអាចចុះកិច្ចសន្យា អាចជាកូនបំណុលបំពេញកាតព្វកិច្ច។ ប៉ុន្តែនីតិបុគ្គលពិបាកកំណត់ឱ្យជាក់ច្បាស់ ដោយមូលហេតុខាងទិដ្ឋភាពនៃការសន្មតខាងបុគ្គលភាពរបស់វា។

នៅពេលមានតម្រូវការសាច់ប្រាក់បន្ទាន់ ដើម្បីទម្លាយភាពទ័លក្រក្នុងជីវភាពរស់នៅប្រចាំថ្ងៃបានមួយគ្រាៗ មនុស្សភាគច្រើនតែងរត់រកប្រព័ន្ធឥណទានក្រៅផ្លូវការ រួមមានបណ្ដាក់ ឆក់ និងចងការប្រាក់ជាដើម។ ដោយការចងការពីអ្នកមានទ្រព្យច្រើននៅក្នុងស្រុកភូមិ តំបន់ដែលគេបានរស់នៅ។ ចំពោះការខ្ចីពីហិរញ្ញវត្ថុផ្លូវការ រួមមានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលត្រូវការពេលវេលាយូរ ហើយតម្រូវឱ្យមាននូវលិខិតស្នាមច្បាស់លាស់។ **ឧទាហរណ៍៖** ប្រជាកសិករមិនអាចទទួលបានទិន្នផលពីការដាំដុះស្រូវតាមការរំពឹងទុក ដោយសារពឹងផ្អែកច្រើនទៅលើអាកាសធាតុ ហើយកសិករ និងរោងម៉ាស៊ីនកិនស្រូវប្រឈមនឹងការរកទីផ្សារ និងការចំណាយថ្លៃដើមខ្ពស់ក្នុងការផលិតស្រូវ-អង្ករ។ នេះហើយដែលជាហេតុពួកគេបានទៅរកមីក្រូហិរញ្ញវត្ថុ ដោយយកកម្ចីឥណទានដែលមានការប្រាក់ទាបបំផុត ដើម្បីយកមកទ្រទ្រង់នូវជីវភាពរបស់ពួកគេបន្តទៀត ក៏ដូចជាទៅបង្កើនការដាំដុះបន្តទៅទៀត។ ម្យ៉ាងទៀតកសិករភាគច្រើនតែងតែរកប្រភពទុនផ្សេង ដើម្បីទិញសម្ភារៈកសិកម្មដូចជា ចំណាយលើពូជ ជី ជាដើម នៅពេលដល់ពេលដាំដុះម្ដង ដែលភាគច្រើនពឹងទៅលើកម្ចីក្រៅផ្លូវការ។ រីឯជាក់ស្ដែងដូចនៅប្រទេសកម្ពុជាយើងមាននូវធនាគាររបស់រដ្ឋ ដែលផ្ដល់នូវប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបបំផុត ដើម្បីឱ្យប្រជាជនមានលទ្ធភាពយកទៅបង្កើនមុខរបរ ដើម្បីចិញ្ចឹមជីវិតបានមួយកម្រិតទៀតទៅតាមតម្រូវការដែលចង់បាន។

## កថាខណ្ឌទី២៖ ប្រភេទកម្មវត្ថុចំពោះការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

កម្មវត្ថុអាចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់មានដូចខាងក្រោម ៖

### ១. ករណីកម្មវត្ថុជាវត្ថុនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាមួយដែលភាគីនៃកិច្ចសន្យាមានកាតព្វកិច្ចផ្ដល់ឱ្យគ្នាទៅវិញទៅមក ហើយចំពោះវត្ថុដែលប្រគល់ឱ្យអ្នកខ្ចីនោះ អ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចក្នុងការធានាទទួលខុសត្រូវលើវត្ថុនោះ។ រីឯកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាវត្ថុ បើយើងមើលតាមទិដ្ឋភាពជាក់ស្ដែងមិនសូវជាមានប៉ុន្មានទេ ព្រោះថាវត្ថុដែលបានខ្ចីមិនត្រូវការគិតតម្លៃតបស្នងវិញជាសាច់ប្រាក់ ត្រឹមតែថាយកទៅបរិភោគក្នុងគ្រាមួយលំបាកទ័លក្រតែប៉ុណ្ណោះ ប្រសិនបើអ្នកខ្ចីមានចិត្ត ឬមនោសញ្ចេតនាប្រគល់នូវប្រាក់បន្តិចបន្តួច ឬផ្ដល់ជាផលដំណាំវិញក៏បាន។ **ឧទាហរណ៍៖** លោក ក បានស្នើសុំខ្ចីគោយន្តពី លោក ខ ដែលត្រូវជាអ្នកជិតខាងនឹងគ្នា ដើម្បីយកទៅភ្ជួររាស់ដីចំការដើម្បីដាំពោតបន្ថែមទៀត។ លោក ខ បានយល់ព្រមដោយគិតថាជាអ្នកភូមិជាមួយគ្នាដោយមិនត្រូវការនូវសាច់ប្រាក់ពីការខ្ចីគោយន្តនោះទេ។ ប៉ុន្តែក្រោយពីប្រមូលផលនៃពោតរួច លោក ក បានប្រគល់ ពោតមួយចំនួនទៅឱ្យលោក ខ ដោយគិតថាជាតម្លៃថ្នូរ និងទឹកចិត្តបន្តិចបន្តួច។

ផ្ទុយទៅវិញចំពោះភាគីអ្នកឱ្យខ្ចី បានយកវត្ថុរបស់ជនដទៃទៀត (តតិយជន) មកដាក់ខ្ចីទៅឱ្យអ្នកខ្ចីនោះអ្នកឱ្យខ្ចីត្រូវធានានូវលក្ខខណ្ឌមួយចំនួន ដែលបង្ហាញថាអ្នកឱ្យខ្ចីមានកំហុស ឬគ្មានកំហុសចំពោះករណី

ដែលយកវត្ថុជាកម្មវត្ថុនៃកិច្ចសន្យាមកឱ្យអ្នកខ្ចី។ លើសពីនេះទៅទៀតការខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន គឺមានករណីកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅអ្នកខ្ចី ឬត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន។ ប៉ុន្តែអ្នកខ្ចីមិនអាចធ្វើការទាមទារនូវវត្ថុជំនួសបានទេក្នុងករណីដែលអ្នកខ្ចីបានបរិភោគវត្ថុដែលជាកម្មវត្ថុនៃការខ្ចីរួចនោះ។[25] បើអ្នកឱ្យខ្ចីមិនអាចប្រគល់វត្ថុនោះបានទេ ឬមិនអាចរកវត្ថុផ្សេងទៀតមកជំនួសបានទេ អ្នកខ្ចីមានសិទ្ធិរំលាយកិច្ចសន្យាខ្ចីបរិភោគនោះបាន ទោះបីជាអ្នកខ្ចីនោះសុចរិត ឬទុច្ចរិតក៏ដោយ។[26] ទន្ទឹមនឹងនេះផងដែរ ប្រសិនបើ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុខ្ចីដោយមិនបានដឹងថាអ្នកឱ្យខ្ចីមិនមានកម្មសិទ្ធិទេអាចទាមទារសំណងនៃការខូចខាតពីអ្នកឱ្យខ្ចីបាន។[27] មិនតែប៉ុណ្ណោះក្នុងករណីនេះ បើអ្នកខ្ចីបានសងវត្ថុដែលត្រូវបានប្រគល់ឱ្យ ឬសងតម្លៃនៃវត្ថុនោះឱ្យទៅម្ចាស់កម្មសិទ្ធនោះ អ្នកខ្ចីត្រូវបានរួចផុតពីករណីកិច្ចសងចំពោះអ្នកឱ្យខ្ចី។[28]

### ២.ករណីកម្មវត្ថុជាប្រាក់ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

ចំពោះការខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ គឺជាការខ្ចីបរិភោគមួយប្រភេទដែលគូភាគីបានព្រមព្រៀងគ្នាបង្កើតនូវសិទ្ធិលើបំណុល ដែលជាការប្រាក់ក្រៅពីប្រាក់ដើម ដោយតម្រូវឱ្យធ្វើជាលិខិតលាយលក្ខណ៍អក្សរ និងហត្ថលេខារបស់អ្នកខ្ចី។[29]

យើងខ្ញុំសូមធ្វើការសិក្សាបែងចែកជា ៣ចំនុចគឺ គោលគំនិតនៃការប្រាក់ អត្រាការប្រាក់ និងប្រភេទនៃការប្រាក់។

#### ២.១ ការប្រាក់

ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬវត្ថុផ្សេងទៀតដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ ឬវត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលបានខ្ចី មកគុណជាមួយនឹងអត្រាការប្រាក់ដែលត្រូវបានកំណត់។[30] វត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហៅថាប្រាក់ដើម។ ការប្រាក់ជាផលស៊ីវិល។ ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀងបាន។ ប៉ុន្តែចំពោះ

[25] មាត្រា៥៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[26] មាត្រា៥៨៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27] មាត្រា៥៨៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[28] មាត្រា៥៨៨ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា ៥៨៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ប្រសិនបើពុំបានធ្វើលិខិតជាលាយលក្ខណ៍អក្សរ ដោយមានការចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ។

ការប្រាក់ជាបន្ទុកមួយដ៏ធ្ងន់សម្រាប់កូនបំណុល ហេតុនេះហើយប្រសិនបើកិច្ចព្រមព្រៀងនោះមិនបានធ្វើដោយលិខិតជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ជាគោលការណ៍សិទ្ធិលើបំណុលចំពោះការប្រាក់មិនត្រូវកើតឡើងឡើយ។ ក៏ប៉ុន្តែក្នុងជីវភាពរៀងរាល់ថ្ងៃអាចមានការសន្យាបង់ការប្រាក់ដោយផ្ទាល់មាត់។ ក្នុងករណីនេះដើម្បីការពារកុំឱ្យមានវិវាទកើតឡើង ដែលអ្នកខ្ចីទាមទារឱ្យសងវិញនូវការប្រាក់ដែលខ្លួនបានបង់ដោយស្ម័គ្រចិត្តរួចហើយ។ ចំណែកប្រភេទនៃការប្រាក់មានបីប្រភេទ គឺការប្រាក់ធម្មតា ការប្រាក់យឺតយ៉ាវ និងការប្រាក់សមាស។ **ឧទាហរណ៍៖** អ្នកស្រី ក បានខ្ចីប្រាក់ពីលោក ខ ចំនួន២០០ដុល្លារ ជាមួយនឹងការប្រាក់ ៤ភាគរយក្នុងមួយខែ។ ដូចនេះនៅពេលដែលបង់ការប្រាក់គឺត្រូវយក ២០០ គុណ 0,0៤ = ៨0 ដុល្លារ។

- **ការប្រាក់ធម្មតា៖** ការប្រាក់ធម្មតា ជាប្រតិបត្តិការទូទៅចំពោះការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ដោយភាគីនៃកិច្ចសន្យាអាចយកការប្រាក់បានតាមការព្រមព្រៀងរបស់ភាគី ដោយមិនឱ្យលើសពីអត្រាការប្រាក់ដែលបានកំណត់ឡើយ។
- **ការប្រាក់យឺតយ៉ាវ៖** ការប្រាក់យឺតយ៉ាវ គឺជាចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវសងទៅម្ចាស់បំណុលក្នុងករណីកូនបំណុលមិនអនុវត្តកាតព្វកិច្ចតាមកាលបរិច្ឆេទកំណត់ មានន័យថា ដល់កាលបរិច្ឆេទនៃការអនុវត្តកាតព្វកិច្ចហើយ តែកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច ហើយកាលបរិច្ឆេទនៃការសងនោះបានកន្លងផុត។ ពេលដែលកន្លងផុតនេះ គឺជាការប្រាក់យឺតយ៉ាវ។
- **ការប្រាក់សមាស៖** ការប្រាក់សមាស គឺជាការប្រាក់ដោយបូកបញ្ចូលនឹងប្រាក់ដើម ហើយការប្រាក់សមាសនោះក្លាយទៅជាប្រាក់ដើម បន្ទាប់មកត្រូវគិតការប្រាក់សារជាថ្មី។ នៅក្នុងលក្ខខណ្ឌដែលត្រូវគិតការប្រាក់សមាសបាន លុះត្រាតែកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរយៈពេលមួយឆ្នាំ ម្ចាស់បំណុលដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ ហើយអំឡុងពេលសមរម្យបានកន្លងផុតទៅ និងម្ចាស់បំណុលបង្ហាញឆន្ទៈបូកបញ្ចូល។[31]

### ២.២ អត្រាការប្រាក់

កាលណាគេនិយាយពីអត្រាការប្រាក់ គឺគេបានបែងចែកជា២ គឺអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា។

[31] មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.២.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ គឺសំដៅទៅលើអត្រាការប្រាក់ ដែលមានចែងកំណត់ទុកមុននៅក្នុងច្បាប់។ ក្នុងករណីដែលភាគីមិនបានព្រមព្រៀងគ្នា អំពីអត្រាការប្រាក់នៅក្នុងកិច្ចសន្យាទេ គឺគេត្រូវយកអត្រាការប្រាក់ ដែលបានកំណត់ដោយច្បាប់យកមកអនុវត្តនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់។

អត្រាការប្រាក់ដែលកំណត់ដោយច្បាប់នេះ គឺ ៥% នៅក្នុងមួយឆ្នាំ។[32]

⁂ មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី គេអាចកំនត់អត្រាការប្រាក់ផ្សេងពីនេះ ដោយច្បាប់ពិសេសបាន។ តាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ១៩៩៦ បានកំណត់អំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជាមានតួនាទីកំណត់អត្រាការប្រាក់។[33] ដូចនេះអត្រាការប្រាក់ដែលត្រូវយកមកអនុវត្តនៅក្នុងវិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានកំណត់ដោយបទបញ្ញត្តិពិសេសរបស់ធនាគារជាតិនៃកម្ពុជា។

### ២.២.២ អត្រាការប្រាក់ក្នុងកិច្ចសន្យា

ការកំណត់អត្រាការប្រាក់ដោយច្បាប់ក្នុងកិច្ចសន្យា គឺវាមានផលប៉ះពាល់ខ្លាំងណាស់ចំពោះការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចដោយសារមូលហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឱ្យគូភាគីអាចធ្វើការកំណត់នូវអត្រាការប្រាក់តាមការព្រមព្រៀងរបស់ភាគីបាន ដោយមិនចាំបាច់ធ្វើការអនុវត្តតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ (៥%) ព្រោះថានៅក្នុងកិច្ចសន្យាខ្ចីបរិភោគមានហានិភ័យខ្ពស់ណាស់ចំពោះអ្នកខ្ចីដោយមានប្រាក់ឱ្យគេខ្ចីហើយទទួលបានការប្រាក់ទាប តែត្រូវប្រឈមមុខនិងការខាតបង់យ៉ាងខ្លាំងក្នុងការឱ្យប្រាក់ ឬវត្ថុរបស់ខ្លួនទៅឱ្យអ្នកខ្ចីប្រើប្រាស់ដោយសេរី តែអ្វីដែលជាថ្នូរចំពោះការប្រើប្រាស់នោះគ្រាន់តែជាការប្រាក់បន្តិចបន្តួច។ ម៉្យាងវិញទៀត តើអ្នកណាហ៊ានប្រថុយយកប្រាក់របស់ខ្លួនទៅឱ្យគេខ្ចីនោះ បើការខ្ចីនោះតម្លៃថ្នូរមកវិញនូវការប្រាក់ទាបបំផុតនោះ។

តាមមាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី បានអនុញ្ញាតឱ្យគូរភាគីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់អាចធ្វើការព្រមព្រៀងគ្នាដោយសេរីនៅក្នុងការកំណត់នូវអត្រាការប្រាក់របស់ខ្លួននៅក្នុងកិច្ចសន្យាបាន។ ទោះបីជាការព្រមព្រៀងនោះមានការកំណត់នូវអត្រាការប្រាក់ហួសពីអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ក៏ដោយ ក៏ការព្រមព្រៀងនោះមានអានុភាពដែរ តែត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។

---

[32] មាត្រា៥៩ ក្រមច្បាប់លេខ ៣៨ និងមាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[33] មាត្រា ៧ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ១៩៩៦

### ២.២.៣ ការកម្រិតការប្រាក់

អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរិមា ដែលអាចកំណត់បានដោយស្របច្បាប់ ឬកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀត ហើយគូរភាគីមិនអាចធ្វើការព្រមព្រៀងគ្នាឱ្យលើសពីការកម្រិតបានឡើយ។

តាមច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ មាត្រា ១៧ អត្រាការប្រាក់ដែលត្រូវបានកម្រិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០% ទៅ ៣០% ក្នុង១ឆ្នាំ។ តាមប្រកាសរបស់ក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលបានកម្រិត ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ អត្រាការប្រាក់ដែលត្រូវបានកម្រិតពី ១៨% នៅក្នុង ១ឆ្នាំ។

ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីការប្រាក់ដែលត្រូវបានកម្រិត កិច្ចសន្យារបស់ភាគីដែលកម្រិតលើសពីអត្រាការប្រាក់ដែលបានកំណត់ត្រូវទុកជាមោឃៈ រីឯអ្នកខ្ចីមានករណីយកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបានគណនាតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។ នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលបានកម្រិត ហើយត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះជាការកាត់បំណុលទៅលើប្រាក់ដើម។[34]

នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើមចំពោះផ្នែកដែលលើសពីកម្រិតហើយតែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅអ្នកខ្ចីដោយភ្ជាប់ជាមួយនូវប្រាក់សំណងនៃការខូចខាត ដោយគណនាទៅតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ។

- **ការកំណត់ចំនួនប្រាក់ដើមជាក់ស្តែង៖** ក្នុងករណីដែលការប្រាក់បានដកសំរាប់ពេលសងនាពេលអនាគតចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ជាក់ស្តែងទៅឱ្យអ្នកខ្ចីត្រូវចាត់ទុកថាជាចំនួននៃប្រាក់ដើម។
- **ចាត់ទុកជាការប្រាក់៖** ករណីដែលអ្នកឱ្យខ្ចីបានទទួលក្រៅពីប្រាក់ដើមទាក់ទង និងកិច្ចសន្យាខ្ចីបរិភោគ ទោះជាបានទទួលក្នុងនាមជាប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និងកម្រៃផ្សេងទៀតក៏ដោយត្រូវចាត់ទុកជាការប្រាក់ទាំងអស់។ ប៉ុន្តែមិនអាចគិតជាការប្រាក់ទេ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និងការសងបានទេ។

[34] មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សរុបមកវិញ អត្រាការប្រាក់ដែលត្រូវបានកម្រិតនោះជាទំហំនៃអត្រាការប្រាក់មួយយ៉ាងខ្ពស់សំដៅទៅលើករណីដែលភាគីអ្នកឱ្យខ្ចីបានឆ្លៀតកេងយកចំណេញហួសហេតុពីការព្រមព្រៀងក្នុងអំឡុងពេលដែលអ្នកខ្ចីមានវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរនោះ និងជាការគណនានូវផលប្រយោជន៍សមភាពរវាងភាគីនៃកិច្ចសន្យាផងដែរ។

### ២.៣ ពេលវេលាសងនៃការបង់ការប្រាក់ និងការប្រាក់សមាសដែលកំណត់ដោយច្បាប់

#### ២.៣.១ ពេលវេលានៃការបង់ការប្រាក់

ជាគោលការណ៍ការប្រាក់ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា ១ឆ្នាំបានកន្លងផុតគិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ។ នេះមិនមែនជាបញ្ញត្តិដោយបង្ខំទេ មានន័យថាគូរភាគីអាចធ្វើការព្រមព្រៀងគ្នាផ្សេងបាន។ ភាគីអាចព្រមព្រៀងគ្នាបង់រៀងរាល់ខែ ឬកន្លះឆ្នាំម្តងជាដើម។ ប៉ុន្តែបើត្រូវសងវត្ថុនោះនៅមុនពេល១ឆ្នាំនោះ ការយកការប្រាក់ត្រូវគិតនៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ។

#### ២.៣.២ ការប្រាក់សមាសដែលកំណត់ដោយច្បាប់

ការប្រាក់សមាស សំដៅទៅលើការបន្ថែមការប្រាក់ទៅលើការប្រាក់ដែលមិនទាន់បានសង។ ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ចាប់រយៈពេលចាប់ពី ១ឆ្នាំឡើងទៅហើយទោះបីជាអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឱ្យខ្ចីអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន។[35]

ការប្រាក់សមាស គឺជាការប្រាក់ដែលគេអាចយកទៅបូកបង្គរជាមួយប្រាក់ដើមបាន។ **ឧទាហរណ៍៖** អ្នកខ្ចីប្រាក់យូរហើយតែមិនបានសង ម្ចាស់បំណុលទាមទារឱ្យយកការប្រាក់ទៅបូកបញ្ចូលជាមួយប្រាក់ដើម ដូចនេះការប្រាក់នេះក្លាយជាប្រាក់ដើម។

ប៉ុន្តែមានលក្ខខណ្ឌ ដើម្បីឱ្យម្ចាស់បំណុលអាចទាមទារការប្រាក់សមាសបាន៖

១. លុះត្រាតែ កូនបំណុលមិនបានអនុវត្តកាតព្វកិច្ចសងលើសពីមួយឆ្នាំ

២. ម្ចាស់បំណុលបានកំណត់រយៈពេលសមរម្យ (**ឧទាហរណ៍៖** បើយឺត១ឆ្នាំហើយម្ចាស់បំណុលនឹងធ្វើលិខិតទៅកូនបំណុល ថាត្រូវតែសងទៅម្ចាស់បំណុលក្នុងរយៈពេល៣សប្តាហ៍)

៣. អំឡុងពេលសមរម្យ ៣ សប្តាហ៍នោះបានកន្លងផុតទៅ

៤. ម្ចាស់បំណុលបានបង្ហាញនូវឆន្ទៈបូកបញ្ចូលការប្រាក់ទៅជាប្រាក់ដើម មានន័យថាម្ចាស់បំណុលទាមទារពីកូនបំណុល ដែលមិនបានសងការប្រាក់ក្នុងរយៈពេល១ឆ្នាំហើយ នោះម្ចាស់បំណុលទាមទារឱ្យយកការប្រាក់នោះទៅបូកនឹងប្រាក់ដើម។ ការប្រាក់បែបនេះហៅថាការប្រាក់សមាសដោយយកការប្រាក់បូកប្រាក់ដើម បន្ទាប់មកបានគិតការប្រាក់ទៀត។

[35] មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ផ្នែកទី២៖ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់ ជាការមិនគិតកម្រៃតបស្នងពីកម្មវត្ថុនៃកិច្ចសន្យាវិញនោះទេ ពោលគឺអ្នកឱ្យខ្ចីពុំបានកំណត់ការប្រាក់នោះទេ គ្រាន់តែយកប្រាក់ដើមមកវិញតែប៉ុណ្ណោះ។

កិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់មានភាពខុសគ្នាបន្តិចពីកិច្ចសន្យា ដែលមានភ្ជាប់ការប្រាក់ ពោលគឺប្រសិនបើកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ ហើយបូកទាំងការមិនធ្វើជាលាយលក្ខណ៍អក្សរភាគីនីមួយៗនៃកិច្ចសន្យាអាចដកវិញនៅពេលណាក៏បាន។ [36] មិនតែប៉ុណ្ណោះភាគីអាចបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមិនកំណត់អំឡុងពេលក្នុងការសងបាន។ ក៏ប៉ុន្តែការព្រមព្រៀងវាមានភាពចាំបាច់ក្នុងការកំណត់ពីគុណភាព ចំនួន និងប្រភេទនៃកម្មវត្ថុ ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគនេះ។ វត្ថុដែលបានកំណត់ជាក់លាក់ ដូចជាអចលនវត្ថុមិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគនោះទេ ព្រោះវាមិនអាចជំនួសបាន។

### កថាខណ្ឌទី១៖ លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ប្រាក់អាចមានសុពលភាពបាន លុះត្រាតែមានការព្រមព្រៀងកើតចេញពីគូរភាគីនៃកិច្ចសន្យា និងមាននូវកម្មវត្ថុមួយដែលជាក់លាក់ស្របទៅតាមច្បាប់។ មិនតែប៉ុណ្ណោះគូភាគីគឺត្រូវមានសមត្ថភាពពេញលេញដែលកំណត់ទៅតាមច្បាប់ផងដែរ ទើបកិច្ចសន្យាមួយនេះអាចបង្កើតទៅបាន។

#### ១. ការព្រមព្រៀងបង្កើតការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងភាគីអ្នកឱ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ។[37]

ចំពោះកិច្ចសន្យាខ្ចីបរិភោគមានអានុភាពដោយការព្រមព្រៀងរបស់គូរភាគី បានន័យថាការបង្កើតកិច្ចសន្យាខ្ចីបរិភោគពុំតម្រូវឱ្យបំពេញទម្រង់ណាមួយជាលក្ខខណ្ឌដើម្បីបង្កើតអានុភាពនោះទេ ក្រៅពីការព្រមព្រៀងរបស់គូរភាគី។ ហេតុនេះហើយ ទោះបីជាមានត្រឹមការព្រមព្រៀងដោយផ្ទាល់មាត់រវាងអ្នកឱ្យខ្ចី និងអ្នកខ្ចីក៏ដោយ ក៏កិច្ចសន្យាខ្ចីបរិភោគមានអានុភាពដែរ។[38] ផ្ទុយទៅវិញចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់វិញភាគីអាចធ្វើការព្រមព្រៀងដោយផ្ទាល់មាត់បានដោយមិនបាច់ធ្វើជាលាយលក្ខណ៍អក្សរនោះទេ។ ចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់នេះមិនសូវជួបប្រទះប៉ុន្មានទេ ជាពិសេសគឺក្នុងវិស័យជំនួញនេះតែម្តង។ ប៉ុន្តែភាគច្រើនណាស់ដែលការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះ វារមែងកើតចេញតែពីមនោសញ្ចេតនារវាង

[36] មាត្រា ៥៨០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[37] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អ្នកស្គាល់គ្នា មិត្តភក្តិ គ្រួសារ បងប្អូនតែប៉ុណ្ណោះ។ ប៉ុន្តែក្នុងករណីដែលកិច្ចសន្យាខ្ចីបរិភោគបានធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើអ្នកឱ្យខ្ចីពុំទាន់បានប្រគល់របស់អ្នកខ្ចីជាក់លាក់នោះទេ អ្នកឱ្យខ្ចីអាចបញ្ឈប់ការឱ្យខ្ចីវិញបានដោយពុំចាំបាច់មានមូលហេតុច្បាស់លាស់នោះទេ។[39] **ឧទាហរណ៍៖** លោក ក បានឱ្យលោក ខ ខ្ចីពូជស្រូវផ្កាម្លិះចំនួន៣០ គីឡូក្រាម ដើម្បីយកទៅបង្កបង្កើនផល ហើយភាគីទាំងពីរបានព្រមព្រៀងគ្នាថា ឆ្នាំក្រោយនឹងសងពូជស្រូវដែលមានចំនួន និងប្រភេទដូចគ្នាមកឱ្យលោក ក វិញ។ បញ្ជាក់ផងដែរចំពោះ កិច្ចសន្យាខ្ចីបរិភោគដែលធ្វើឡើងដោយផ្ទាល់មាត់នេះ ភាគី ក អាចបញ្ឈប់ការឱ្យខ្ចីបាន ដោយពុំចាំបាច់មានមូលហេតុច្បាស់លាស់នោះទេ លើកលែងតែវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបានប្រគល់ឱ្យហើយតែប៉ុណ្ណោះ។ ដោយឡែកប្រសិនបើកិច្ចសន្យាបានបង្កើតជាលាយលក្ខណ៍អក្សរនោះ លោក ក មានករណីកិច្ចប្រគល់វត្ថុ ដែលជាកម្មវត្ថុ(ស្រូវផ្កាម្លិះ) មកឱ្យលោក ខ តាមការព្រមព្រៀង។

## ២. កម្មវត្ថុ និងមូលហេតុនៃការបង្កើតការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កម្មវត្ថុ ក៏ជាធាតុផ្សំមួយយ៉ាងសំខាន់ ដើម្បីឱ្យកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់មានលក្ខខណ្ឌសុពលក្នុងការបង្កើតបាន។ យើងដឹងហើយថាកិច្ចសន្យាខ្ចីបរិភោគ គឺជាកិច្ចសន្យាដែលអ្នកឱ្យខ្ចី ត្រូវប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀតឱ្យទៅអ្នកខ្ចី សម្រាប់អំឡុងពេលមួយ ហើយអ្នកខ្ចីត្រូវសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។ បើទោះបីជាកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់សំរាប់ភាគី អ្នកឱ្យគេខ្ចីមិនបានទទួលផលប្រយោជន៍ពីការខ្ចីនោះក៏ដោយក៏អ្នកឱ្យខ្ចីត្រូវប្រគល់នូវកម្មវត្ថុជាប្រាក់ក្តី ឬជាវត្ថុក្តីទៅតាមទឹកចិត្ត មនោសញ្ចេតនាទៅឱ្យអ្នកឱ្យខ្ចីខ្លះៗដែរ។ ជាក់ស្តែងកម្មវត្ថុនៃការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ យើងសង្កេតឃើញភាគច្រើនតែងសំបូរកើតមានឡើងនូវតាមជនបទ ឬសហគមន៍ជនបទដែលប្រកបរបរកសិកម្មធ្វើស្រែចំការ ដែលតែងមានការខ្ចីនូវកម្មវត្ថុជាវត្ថុ ដូចជាការខ្ចីគ្រាប់ពូជដំណាំផ្សេង យកទៅបង្កបង្កើនផល ដោយមិនត្រូវការនូវតម្លៃតបស្នងមកវិញទេ បើគ្រាន់តែត្រឹមយកទៅដាំដុះ ដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ។

មួយវិញទៀតកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ គឺត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ តួយ៉ាងដូចជាការខ្ចីលុយគ្នាទៅវិញទៅមករវាងមិត្តភក្តិ ឬបងប្អូនជាអាទិ៍។ ចំពោះមូលហេតុដែលមានអាចកើតមានឡើងនូវកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះឡើង គឺភាគច្រើនណាស់ដែលកើតចេញពីមនោសញ្ចេតនា ការយោគយល់ អធ្យាស្រ័យ តាមរយៈបងប្អូន។ ចំពោះកិច្ចសន្យានេះដែរត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ នោះអ្នកឱ្យខ្ចីត្រូវមានករណីកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

[39] មាត្រា ៥៨០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នៃការឱ្យខ្ចីតាមការព្រមព្រៀង។ ម៉្យាងវិញទៀតចំពោះការខ្ចីបរិភោគដោយមិនគិតការប្រាក់នេះ ទោះបីមិនបានធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ក៏កិច្ចសន្យានេះមានអានុភាពដែរ ដោយហេតុថាពេលខ្លះគ្រាន់តែមានការខ្ចីយកទៅប្រើការតែមួយរយៈពេលខ្លីតែប៉ុណ្ណោះ។

### ៣. សមត្ថភាពភាគីនៃការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

ចំពោះសមត្ថភាពនៃគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់វិញ មានលក្ខណៈស្រដៀងគ្នាទៅនឹងការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែរ ពោលគឺសមត្ថភាពក្នុងការអនុវត្តនូវសិទ្ធិ និងអនុវត្តកាតព្វកិច្ចត្រូវតែស្ថិតក្រោមច្បាប់។

#### ៣.១ ករណីភាគីទាំងសងខាងជារូបវន្តបុគ្គល

ចំពោះរូបវន្តបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។ [40] ប៉ុន្តែសមត្ថភាពចំពោះរូបវន្តបុគ្គលក្នុងការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះយើងខ្ញុំសុំលើកអំពីរូបវន្តបុគ្គលដែលជាប្រជាពលរដ្ឋដែលរស់នៅតាមជនបទ ដែលធ្វើការប្រកបរបរកសិកម្ម ធ្វើស្រែចំការ ចិញ្ចឹមសត្វ។ល។

ការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ភាគច្រើនធ្វើឡើងដោយមាត់ទទេ ឬគ្មានកិច្ចសន្យាដែលធ្វើជាលាយលក្ខណ៍អក្សរធ្វីនោះទេ។ ភាគច្រើនគឺវាពឹងផ្អែកទៅលើការស្គាល់ ការមានទំនាក់ទំនង និងការទុកចិត្តគ្នារវាងកូនបំណុល និងម្ចាស់បំណុល ដែលអាចបំពេញការខ្វះខាតបានឆាប់រហ័ស។ ជាក់ស្តែងដូចការប្រកបរបរមុខរបរលើការដាំដុះស្រូវ ការដាំស្រូវគឺត្រូវពឹងផ្អែកច្រើនទៅលើបញ្ហាអាកាសធាតុ ក៏ដូចជាបច្ចេកទេសនៃការដាំដុះដើម្បីទទួលបានទិន្នផលខ្ពស់។ តែបើការរំពឹងទាំងនេះមិនសមបំណងទេនោះ ពុំទទួលបានទិន្នផលនោះទេ។ នៅក្នុងស្ថានភាពនេះដែរប្រជាកសិករភាគច្រើនតែងទៅរកកម្ចីពីអ្នកស្គាល់គ្នា ដើម្បីយកមកដោះស្រាយបញ្ហាបានមួយគ្រាសិន។ ចំពោះការខ្ចីនេះដោយយល់ឃើញថា ការខ្ចីពីអ្នកស្គាល់មានភាពងាយស្រួលជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញណាស់។ បើទោះបីជាការខ្ចីពីអ្នកស្គាល់គ្មានទទួលបានការប្រាក់ពីការខ្ចីនោះទេ ក៏ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការរស់នៅប្រចាំថ្ងៃ ពីព្រោះយើងអាចបំពេញនូវតម្រូវការបានភ្លាមៗ។

#### ៣.២ ករណីភាគីទាំងសងខាងជានីតិបុគ្គល

នីតិបុគ្គល ប្រៀបដូចជាមនុស្សជាម្ចាស់សិទ្ធិ បានន័យថាអាចចុះកិច្ចសន្យាអាចជាកូនបំណុលបំពេញកាតព្វកិច្ច។ ចំពោះសមត្ថភាពនៅក្នុងការខ្ចីបរិភោគដែលគ្មានការប្រាក់ ក្នុងលក្ខណៈភាគីទាំងសងខាងជានីតិបុគ្គលវិញ ក៏មិនខុសគ្នាប៉ុន្មានដែរទៅនឹងការខ្ចីបរិភោគដែលភ្ជាប់ការប្រាក់ដែរ គ្រាន់តែមានការយោគយល់ដោយផ្តល់ការខ្ចីនោះឥតការប្រាក់ក្នុងដំណាក់កាលដំបូង ដើម្បីយកទៅផ្គត់ផ្គង់ ឬយកទៅអភិវឌ្ឍន៍នូវមុខរបរ

[40] មាត្រា ៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដើម្បីបង្កើនចំណូលបន្ថែមទៀត។ បើតាមយើងសង្កេតឃើញនៅតាមទីជនបទគឺមាននូវសមាគម៍ ដែលបានយកចិត្តទុកដាក់ជួយបណ្តុះបណ្តាលប្រជាជនតាមជនបទ នៅក្នុងការបណ្តុះបណ្តាលឱ្យទទួលបានកម្រៃបានច្រើនលើសពីការប្រកបរបរសព្វថ្ងៃ។ ដើម្បីជួយប្រែក្លាយគ្រួសារកសិករដែលក្រីក្របំផុតទៅតាមទីជនបទពីកសិករដែលធ្វើស្រែចំការសម្រាប់តែចិញ្ចឹមគ្រួសាររបស់ខ្លួននោះ ឱ្យក្លាយទៅជាការធ្វើកសិពាណិជ្ជកម្មប្រកបទៅដោយជោគជ័យវិញ។ ពោលគឺ តាមរយៈការបង្កើនផលិតភាព និងការដាំដុះដំណាំផ្សេងៗតាមដែលអាចធ្វើទៅបានដូចជាការធ្វើស្រែ ការដាំបន្លែ នេសាទជាដើម។ ប្រសិនបើគ្មានដីធ្វើកសិកម្មទេ បង្រៀនពីវិធីត្បាញរវៃ សិប្បកម្ម ឬអាហារកែច្នៃ។ល។

### ៣.៣ ករណីភាគីទាំងសងខាងជារូបវន្តបុគ្គល និងនីតិបុគ្គល

ចំពោះការខ្ចីបរិភោគដែលគ្មានការប្រាក់ ភាគីដែលជាអ្នកឱ្យខ្ចីគឺមិនបានទទួលផលប្រយោជន៍ពីប្រាក់ដែលបានប្រគល់ទៅឱ្យអ្នកខ្ចីនោះទេ។ ភាគច្រើនមានតែទៅលើសមាគមន៍ដែលមានជំនួយជួយទៅលើអ្នកមានជីវភាពទីទ័លក្រ ដែលគ្មានមុខរបរច្បាស់លាស់ក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ជាក់ស្តែងដូចជាសមាជិករដ្ឋសភា អនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងជាប្រធានសមាគមនិស្សិតម៉ូស្លីមកម្ពុជា បានផ្តល់ប្រាក់កម្ចីឥណទានដោយឥតការប្រាក់ ជូនដល់ប្រជាពលរដ្ឋទីទាល់ក្រចំនួន១២៥គ្រួសារ ដែលរស់នៅតាមបណ្តោយផ្លូវរថភ្លើង និងតំបន់សហគមន៍អ្នកក្រីក្រ នៃខណ្ឌដូនពេញ។ តាមរយៈការផ្តល់ប្រាក់កម្ចីនេះ សមាគមនិស្សិតម៉ូស្លីមកម្ពុជាបានផ្តល់ប្រាក់កម្ចីឥណទានមុខរបរខ្នាតតូច រយៈពេល០១ឆ្នាំ ជូនប្រជាពលរដ្ឋរស់នៅតាមបណ្តោយផ្លូវរថភ្លើង និងនៅតាមតំបន់ជុំវិញក្នុងសហគមន៍អ្នកក្រីក្រខណ្ឌដូនពេញ ដែលប្រាក់កម្ចីនេះទទួលបានពីអង្គការ **MUSLIMEHELFEN** នៃប្រទេសអាល្លឺម៉ង់ ចំនួន១២៥គ្រួសារ ដែលក្នុងមួយគ្រួសារទទួលបានប្រាក់កម្ចីចំនួន ២លានរៀល សរុបជាទឹកប្រាក់ចំនួន២៥០លានរៀល។ ចំពោះការផ្តល់ប្រាក់កម្ចីនេះប្រជាជនអាចយកទៅប្រកបមុខរបររៀងៗខ្លួន ដូចជាធ្វើស្រែចំការ ចិញ្ចឹមសត្វ លក់គ្រឿងទេស។ល។ ដើម្បីទ្រទ្រង់ជីវភាពប្រចាំថ្ងៃឱ្យបានល្អប្រសើរជាងមុន ហើយការប្រកបរបរនេះត្រូវតែជាមុខរបរសុចរិត និងស្របទៅតាមច្បាប់។

## កថាខណ្ឌទី២៖ ប្រភេទនៃកម្មវត្ថុចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កម្មវត្ថុអាចមានក្នុងកិច្ចសន្យាខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់មានដូចខាងក្រោម៖

### ១. ករណីកម្មវត្ថុជាវត្ថុចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់

កម្មវត្ថុ ដែលជាវត្ថុក្នុងការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់មានលក្ខណៈខុសគ្នាបន្តិចបន្តួចពីការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់។ លើសពីនេះទៅទៀតអ្នកឱ្យខ្ចីត្រូវប្រគល់វត្ថុដែលគ្មានវិការៈ ឬគ្មានវិការៈកំបាំងទៅឱ្យអ្នកខ្ចី។ ក្នុងករណីកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះច្រើនតែកើតមាននូវវិការៈកំបាំង

ដែលជាបញ្ហាមួយនាំឱ្យកើតមាននូវវិវាទឈ្លោះប្រកែកគ្នារវាងភាគីអ្នកឱ្យខ្ចី និងភាគីអ្នកខ្ចី។ ករណីដែលការខ្ចីបរិភោគដែលគ្មានភ្ជាប់ការប្រាក់នេះ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈអាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន។[41] ការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះ នៅពេលដែលវត្ថុក្នុងកិច្ចសន្យាមានវិការៈនោះអ្នកឱ្យខ្ចីត្រូវធ្វើការទទួលខុសត្រូវចំពោះការខូចខាត ប៉ុន្តែការទទួលខុសត្រូវនោះមានលក្ខណៈតិចតួចប៉ុណ្ណោះ។ ក្នុងករណីដែលវត្ថុនោះមានវិការៈដោយសារអ្នកខ្ចី អ្នកខ្ចីអាចសងជាប្រាក់ក៏បានតែត្រូវឱ្យមានតម្លៃស្មើនឹងវត្ថុនោះ។ ចំណែកឯអ្នកឱ្យខ្ចីវិញប្រសិនបើដឹងអំពីវិការៈនៃវត្ថុនោះមុនពេលដែលប្រគល់ឱ្យអ្នកខ្ចី នោះអ្នកឱ្យខ្ចីធ្វើការប្តូរនូវវត្ថុថ្មីដែលគ្មានវិការៈជំនួសនឹងត្រូវសងចំពោះការខូចខាតដែលបណ្តាលមកពីកំហុសរបស់ខ្លួន។ **ឧទាហរណ៍៖** លោក ក បានប្រគល់ត្រីចំនួន ៥គីឡូក្រាម ទៅឱ្យលោកខ ដោយការខ្ចីបរិភោគមិនយកការប្រាក់។ ប៉ុន្តែក្នុងចំណោមត្រី១០គីឡូក្រាមនោះ មាន២គីឡូក្រាមហើយដែលស្អុយ មានគុណភាពអន់។ រីឯតម្លៃរបស់វាវិញមានត្រឹមតែ ១/១០ នៃតម្លៃទីផ្សារតែប៉ុណ្ណោះ។ ចំពោះករណីនេះ លោក ខ អាចសងត្រីចំនួន ៨គីឡូក្រាម ដែលមានគុណភាពដូចត្រីដើមដែលគាត់បានទទួល និងតម្លៃ ១/១០ នៃតម្លៃទីផ្សារ។

**២. ករណីកម្មវត្ថុជាប្រាក់ចំពោះការខ្ចីបរិភោគដោយមិនភ្ជាប់ការប្រាក់**

ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ បានន័យថាជាការខ្ចីបរិភោគនោះមិនគិតពីតម្លៃថ្នូរ។ ដូចនេះអ្នកឱ្យខ្ចីមិនទាមទារ ឬតម្រូវឱ្យអ្នកខ្ចីបង់ការប្រាក់ទេ។ ប៉ុន្តែក្នុងករណីប្រសិនបើអ្នកឱ្យខ្ចីដឹងថាវត្ថុដែលប្រគល់នោះជារបស់តតិយជនណាមួយ ហើយអ្នកឱ្យខ្ចីនៅតែមិនប្រាប់អំពីដំណឹងនោះទៅកាន់អ្នកខ្ចីនោះទេ អ្នកឱ្យខ្ចីនឹងត្រូវទទួលខុសត្រូវចំពោះអ្នកឱ្យខ្ចីដូចក្នុងករណីខ្ចីបរិភោគដែលភ្ជាប់ការប្រាក់ដែរ។[42]

[41] មាត្រា ៥៩០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[42] មាត្រា៥៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី៣
# ការអនុវត្តនៃកិច្ចសន្យាខ្ចីបរិភោគតាម
# ខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី៣

# ការអនុវត្តនៃកិច្ចសន្យាខ្ចីបរិភោគតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ផ្នែកទី១៖ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគ គឺមានលក្ខណៈជាកិច្ចសន្យាទ្វេភាគី ដូចនេះហើយ ទើបដៃគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគត្រូវមានសិទ្ធិ និងកាតព្វកិច្ចផ្តល់ឱ្យគ្នានូវផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ កាតព្វកិច្ចជាកិច្ចដែលត្រូវអនុវត្តដាច់ខាត ចំណែកឯសិទ្ធិជាអ្វីដែលភាគីអាចអនុវត្ត ឬមិនអនុវត្តក៏បាន។

### កថាខណ្ឌទី១៖ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីអ្នកឱ្យខ្ចី

#### ១. សិទ្ធិរបស់ភាគីអ្នកឱ្យខ្ចី

##### ១.១ ករណីកម្មវត្ថុជាវត្ថុ

ក្នុងកិច្ចសន្យាខ្ចីបរិភោគ អ្នកឱ្យខ្ចីមានសិទ្ធិទទួលសងរបស់អ្នកខ្ចីនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានឱ្យខ្ចីនៅពេលធ្វើកិច្ចសន្យា។ លើសពីនេះ អ្នកឱ្យខ្ចីមានសិទ្ធិកំណត់ការប្រាក់ ឬមិនកំណត់ការប្រាក់នៅក្នុងកិច្ចសន្យានេះ។ ជាការពិតណាស់ អ្នកឱ្យខ្ចីអាចទាមទារនូវសំណងតាមពេលដែលបានកំណត់ក្នុងកិច្ចសន្យា ឬតាមតុលាការដោយការអនុវត្តដោយបង្ខំ។

##### ១.២ ករណីកម្មវត្ថុជាប្រាក់

អ្នកឱ្យខ្ចីមានសិទ្ធិទាមទារសំណងខូចខាតពីកូនបំណុលបាន តែមិនអាចបាន ១០០% ទេ គឺត្រូវស្ថិតលើតុលាការគិតពីផលប្រយោជន៍ជាមុនសិន។ បើតាមគ្រឹះស្ថានធនាគារនានា គឺគិត ២% ពីការសងមុនពេលកំណត់ បើតិចពេកភាគីអ្នកឱ្យខ្ចីអាចស្នើរសុំទៅតុលាការបាន អាចទាមទារកូនបំណុលឱ្យសងមុនកំណត់បាន បើសិនជាកូនបំណុលយល់ព្រម។ តែបើកូនបំណុលមិនព្រម នោះម្ចាស់បំណុលគ្មានសិទ្ធិអនុវត្តសិទ្ធិនោះទេ។

នៅពេល កិច្ចសន្យាបានបង្កើតឡើងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចីហើយ ស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន។ ការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ចនេះ មានន័យថាជាការបាត់បង់ ឬ ការថយចុះនៅទ្រព្យសម្បត្តិរបស់អ្នកឱ្យខ្ចីដោយសារមូលហេតុណាមួយ ពោលគឺអ្នកឱ្យខ្ចីបានធ្លាក់ខ្លួនក្រក្រោយពេលបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ។[43]

---

[43] មាត្រា ៥៨១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ២. ភាតព្វកិច្ចរបស់ភាគីអ្នកឱ្យខ្ចី

### ២.១ ភាតព្វកិច្ចចំពោះកម្មវត្ថុជាវត្ថុ

អ្នកឱ្យខ្ចី មានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា រីឯអ្នកខ្ចីអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុ (លក់) បានដោយសេរី ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ[44] ត្រូវទទួលខុសត្រូវសំណងខូចខាតចំពោះកម្មវត្ថុដែលមានវិការៈ ប្រសិនបើកិច្ចសន្យាបរិភោគមិនគិតការប្រាក់។ ដោយសារតែ ខ្លួនបានប្រគល់នូវវត្ថុមានវិការៈព្រមទាំងបានដឹង និងមិនបានជូនដំណឹងទៅអ្នកខ្ចីនោះ ក៏ប៉ុន្តែប្រសិនបើអ្នកខ្ចីបានដឹងថាមានវិការៈ ហើយបានជូនដំណឹង ឬមិនបានដឹងតែម្តងថាកម្មវត្ថុដែលខ្លួនបានប្រគល់នោះមានវិការៈ នោះតាមស្មារតីសមាមាត្រនេះអ្នកខ្ចីមិនអាចទាមទារសំណងនៃការខូចខាតបានទេ។

អ្នកឱ្យខ្ចី ត្រូវប្រគល់កម្មវត្ថុដែលជាវត្ថុដែលគ្មានវិការៈ។ ដូច្នោះបើនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើ អ្នកខ្ចីប្រគល់វត្ថុដែលមានវិការៈ អ្នកខ្ចីដែលបានទទួលការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះអាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និងអាចទាមទារសំណងនៃការខូចខាតបាន។ នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់អ្នកខ្ចីដែលបានទទួលវត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈដូចគ្នាវិញបាន។[45]

ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមិនយកការប្រាក់ ប្រសិនបើអ្នកឱ្យខ្ចី បានដឹងវត្ថុដែលត្រូវប្រគល់នោះជារបស់អ្នកដទៃ ប៉ុន្តែអ្នកឱ្យខ្ចីមិនបានជូនដំណឹងដល់អ្នកខ្ចី ក៏ត្រូវទទួលខុសត្រូវដូចដែលមានចែងក្នុងកថាខណ្ឌទី១ ដល់ទី៣ នៃមាត្រា ៥៨៨ ។

### ២.២ ភាតព្វកិច្ចចំពោះកម្មវត្ថុជាប្រាក់

ទន្ទឹមនឹងនេះដែរ ប្រសិនបើអ្នកខ្ចី ដែលបានទទួលការប្រគល់វត្ថុខ្ចី ពុំបានដឹងថា អ្នកឱ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឱ្យអ្នកឱ្យខ្ចីសងសំណងនៃការខូចខាតបាន។ នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឱ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះជាករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី។[46]

[44] មាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា ៥៩០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[46] មាត្រា ៥៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## កថាខណ្ឌទី២៖ សិទ្ធិ និងភាតព្វកិច្ចរបស់ភាគីអ្នកខ្ចី

### ១. សិទ្ធិរបស់ភាគីអ្នកខ្ចី

#### ១.១ ករណីកម្មវត្ថុជាវត្ថុ

អ្នកខ្ចីមានសិទ្ធិទទួលនូវកម្មវត្ថុដែលជាវត្ថុពីអ្នកឱ្យខ្ចី យកមកប្រើប្រាស់ និងអាស្រ័យផលបានតាមការចង់បានរបស់ខ្លួន។ អ្នកខ្ចីមានសិទ្ធិប្រើប្រាស់វត្ថុ ដែលបានផ្តល់ឱ្យរហូតដល់ពេលប្រគល់ ឬ និយាយម្យ៉ាងទៀត គាត់មិនបាច់ប្រគល់វត្ថុ នៅមុនកាលបរិច្ឆេទសងនោះទេ។ ចំណុចនេះត្រូវបានឱ្យឈ្មោះថា "ផលប្រយោជន៍នៃការកំណត់ពេល"។ អ្នកឱ្យខ្ចី មិនត្រូវអនុញ្ញាតឱ្យធ្វើការទាមទាសងវត្ថុ នៅមុនកាលបរិច្ឆេទឡើយ។[47] ម្យ៉ាងទៀត អាចរំលាយកិច្ចសន្យាចោលបាន ប្រសិនបើអ្នកឱ្យខ្ចីពុំអាចអនុវត្តកាតព្វកិច្ចទេ ឬកម្មវត្ថុនៃការប្រគល់មិនមែនជាកម្មសិទ្ធិរបស់ខ្លួន អាចទាមទារនូវសំណងនៃការខូចខាតពីអ្នកឱ្យខ្ចីនូវវត្ថុអ្នកដទៃនោះបាន ប៉ុន្តែលុះត្រាតែខ្លួនពុំបានដឹងហើយកិច្ចសន្យានោះជាខ្ចីបរិភោគ ដែលពុំមានការប្រាក់នឹងអ្នកឱ្យខ្ចីពិតជាបានដឹងតែមិនបានជូនដំណឹងទៅអ្នកខ្ចីពីការប្រគល់វត្ថុរបស់អ្នកដទៃនោះ។[48]

យ៉ាងណាមិញប្រសិនបើអ្នកខ្ចីបានធ្វើសកម្មភាពដែលសុចរិតនោះ គឺអ្នកខ្ចីមានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាតដែលបានកើតឡើងចេញពីសកម្មភាពនោះបាន។

**ឧទាហរណ៍៖** លោក ក បានប្រគល់ស្រាក្រហមឱ្យលោក ខ ដោយបានដឹងថា ស្រាក្រហមនោះគឺជាកម្មសិទ្ធរបស់ លោក គ។ លោក ខ គឺជាអ្នកគ្រប់គ្រងនៅហាងស្រាក្រហមមួយ ប៉ុន្តែគាត់មិនអាចបើកហាងបានក្នុងរយៈពេល ៤ ថ្ងៃ ព្រោះគាត់សងស្រាក្រហមនោះទៅឱ្យលោក គ វិញដោយផ្អែកលើមាត្រា ៥៨៨ កថាខណ្ឌទី៣។ នៅក្នុងករណីនេះ លោក ក អាចរំលាយកិច្ចសន្យាបាន ប៉ុន្តែគាត់ត្រូវសងប្រាក់ចំណូលនៅក្នុងរយៈពេល ៣ ថ្ងៃ ទៅឱ្យលោក ខ នៅមុនពេលរំលាយ។

#### ១.២ ករណីកម្មវត្ថុជាប្រាក់

អ្នកខ្ចីមានសិទ្ធិបង់ប្រាក់ និងការប្រាក់តាមពេលកំណត់តាមកិច្ចសន្យា។ ភាគីអ្នកឱ្យខ្ចីគ្មានសិទ្ធិទាមទារឱ្យភាគីអ្នកខ្ចីសងតាមតម្រូវការរបស់ខ្លួនខុសពីកិច្ចសន្យាបានឡើយ។

បើសិនជាមានការខ្ចីបរិភោគដោយមានការប្រាក់ ដោយមានការព្រមព្រៀងគ្នាពីពេលវេលានៃការបង់ការប្រាក់រួចហើយ កូនបំណុលមិនអាចសងមុនកាលកំណត់នៃកិច្ចសន្យាដើម្បីរួចផុតពីការសងការប្រាក់បានទេ។ ប៉ុន្តែបើសិនជាមានការព្រមព្រៀងគ្នាចំពោះភាគីទាំងសងខាងពីការសងមុនពេលកំណត់ តែភាគីអ្នកខ្ចីត្រូវ

[47] មាត្រា ៥៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា ៥៨៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បង់ការខូចខាតទៅភាគីអ្នកឱ្យខ្ចី ហើយមិនធ្វើឱ្យខូចផលប្រយោជន៍ភាគីអ្នកខ្ចីទេនោះ ភាគីអ្នកខ្ចីអាចសងមុនកាលកំណត់បាន។ [49] ប៉ុន្តែការទាមទារសងការខូចខាតត្រូវសមាមាត្រទៅនឹងច្បាប់។ បើសិនជាមានការទាមទារច្រើនលើសលប់ពេក ភាគីអ្នកខ្ចីអាចទាមទារឱ្យតុលាការកាត់បន្ថយបាន តែក្នុងករណីដែលការខ្ចី គ្មានការប្រាក់កូនបំណុលអាចសងប្រាក់មុនកាលកំណត់បាន។

### ២. ភាតព្វកិច្ចរបស់ភាគីអ្នកខ្ចី

#### ២.១ ភាតព្វកិច្ចចំពោះកម្មវត្ថុជាវត្ថុ

ជាគោលការណ៍ អ្នកខ្ចីមានករណីយកិច្ចចំពោះអ្នកឱ្យខ្ចីប្រគល់នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង។ ប្រសិនបើភាគី បានកំណត់កាលបរិច្ឆេទនៃការសង អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងនូវវត្ថុនោះមុនពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទដែលកំណត់ក្នុងកិច្ចសន្យាបានឡើយ។ ប៉ុន្តែមានករណីមួយចំនួន ដែលអ្នកឱ្យខ្ចីអាចធ្វើការទាមទារឱ្យសងមុនពេលកំណត់នោះបាន។ ករណីនោះមានដូចជា អ្នកខ្ចីត្រូវបានប្រកាសក្ស័យធន កូនបំណុលបានធ្វើឱ្យខូចខាតប្រាតិភោគ កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែមិនបានបំពេញករណីយកិច្ចនេះ និងមានហេតុដែលគូភាគីបានព្រមព្រៀងគ្នាបានកើតឡើង។[50]

អ្នកខ្ចីត្រូវទទួលបន្ទុកហានិភ័យលើការខូចខាតចំពោះវត្ថុ ដែលជាកម្មវត្ថុដោយសារតែមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចីក្នុងការកាន់កាប់ជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុ ដែលជាកម្មវត្ថុនោះ។ [51] អ្នកខ្ចីត្រូវទទួលខុសត្រូវចំពោះហានិភ័យដែលកើតឡើងដោយប្រការណាមួយគិតចាប់តាំងរយៈពេលដែលខ្លួនស្ថិតជាកម្មសិទ្ធិ។ ប្រសិនបើភាគីមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសងដោយកំណត់អំឡុងពេលសមរម្យបាន។ អ្នកខ្ចី នៃកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ អាចសងនៅពេលណាក៏បាន។ អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគ ដែលមានការប្រាក់អាចសងនៅមុនកាលបរិច្ឆេទសង ដែលបានកំណត់ដោយកិច្ចសន្យាបាន។ ប្រសិនបើពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយក វត្ថុដែលជាកម្មវត្ថុនោះ ទៅសងនៅលំនៅឋានរបស់អ្នកឱ្យខ្ចី។

ប្រសិនបើ អ្នកខ្ចី មិនអាចសងបានទេ អ្នកខ្ចីមានករណីយកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនឹងតម្លៃនៃវត្ថុដែលជាកម្មវត្ថុនៅទីកន្លែង និងថ្ងៃដែលត្រូវសង។ ប្រសិនបើពុំបានកំណត់ថ្ងៃ ឬទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនឹងតម្លៃនោះនៅថ្ងៃ និងទីកន្លែងដែលបានធ្វើកិច្ចសន្យា។

---

[49] មាត្រា ៣៣០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[50] មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះកាតព្វកិច្ចដែលឥតមានកំណត់ពេលវេលាសងវិញគឺជា គោលការណ៍នៅពេលម្ចាស់បំណុលដាស់តឿនពេលដែលត្រូវសងបំណុលមកដល់ (មាត្រា ៣៩៩ ចំណុច គ) ប៉ុន្តែ ប្រសិនបើយកគោលការណ៍នេះមកអនុវត្តចំពោះការខ្ចីបរិភោគ ពេលណាក៏អ្នកខ្ចីត្រូវត្រៀមសងវិញដែរ ហើយការខ្ចីបរិភោគក្លាយទៅជាគ្មានន័យទៅវិញ ហេតុនេះហើយបានជាកថាខណ្ឌទី២ នៃមាត្រា៥៩៤ បានបញ្ញត្តិថា ក្រោយអំឡុងពេលសមរម្យមួយបានកន្លងផុតពីពេលដាស់តឿនសងទើបដល់ពេលត្រូវសង ដែលក្នុងអំឡុងពេលសមរម្យនេះ អ្នកខ្ចីអាចត្រៀមដើម្បីសងបាន។[52]

### ២.២ កាតព្វកិច្ចចំពោះកម្មវត្ថុជាប្រាក់

អ្នកខ្ចី ត្រូវមានកាតព្វកិច្ចត្រូវបង់ប្រាក់ ហើយបង់ការប្រាក់ត្រូវអនុវត្តតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ទោះបីជាតម្លៃរូបិយវត្ថុ ឬតម្លៃនៃវត្ថុមានការប្រែប្រួលនៅមុនពេលសងក៏ដោយ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ដូចគ្នានឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់។[53] **ឧទាហរណ៍៖** ការខ្ចីលុយចំនួន ៥ពាន់ដុល្លារ ដែលត្រូវដល់ពេលសងវិញ ទោះបីជាតម្លៃនៃវត្ថុបានធ្លាក់ចុះក៏ដោយ អ្នកខ្ចីគ្រាន់តែសងទឹកប្រាក់ចំនួន ៥ពាន់ដុល្លារ គឺគ្រប់គ្រាន់ហើយ។ បើសិនចង់ទទួលបានតម្លៃសារធាតុ ចាំបាច់ត្រូវធ្វើការសន្យាពិសេស ដោយគិតប្រាក់ដែលសងទៅតាមការផ្លាស់ប្តូរនៃតម្លៃរូបិយវត្ថុ។ ក្នុងករណីដែលបានទទួលលទ្ធផលមួយដែលអសមភាពយ៉ាងខ្លាំងដោយសារតែគោរពនូវគោលការណ៍ខាងលើ គេអាចកែប្រែទៅតាមស្ថានភាពបាន។

ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ការសងមុនពេលកំណត់នឹងធ្វើឱ្យខូចផលប្រយោជន៍ដល់ការទទួលប្រាក់របស់អ្នកខ្ចី ហេតុនេះហើយបានជាមានចម្ងល់មួយកើតឡើងថា ប្រហែលអ្នកខ្ចីគ្មានសេរីភាពក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលទេ ដូចនេះបានគេកំណត់ថា អ្នកខ្ចីអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលបាន (អ្នកឱ្យខ្ចីអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់បានឡើយ)។ ក្នុងករណីនេះ អ្នកខ្ចីមានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកឱ្យខ្ចីដោយស្របតាមកថាខណ្ឌទី២ នៃមាត្រា៣៣០នៃក្រមរដ្ឋប្បវេណី។ ការខូចខាតត្រូវស្ថិតលើការបកស្រាយ។ បន្ថែមពីនេះករណីការប្រាក់គឺជាតម្លៃថ្នូរនៃការប្រើប្រាស់ប្រាក់ដើម ហើយអ្នកឱ្យខ្ចីអាចប្រើប្រាស់នូវប្រាក់ដើមរបស់ខ្លួន បន្ទាប់ពីពេលដែលបានទទួលការសងមុនពេលកំណត់ ហេតុនេះហើយបានជាភាគច្រើនគេបកស្រាយ ការប្រាក់ដែលកើតឡើងពីថ្ងៃសងរហូតដល់ថ្ងៃបរិច្ឆេទកំណត់ក្នុងកិច្ចសន្យា មិនមែនការខូចខាតទេ។ ដូចនេះ ការខូចខាតក្នុង

[52] មើលសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី មាត្រា ៥៩៤

[53] មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ន័យនេះគេសំដៅទៅលើសោហ៊ុយផ្សេងៗដែលកើតឡើងដើម្បីទទួលនូវការសងមុនពេលកំណត់នោះ ដែលត្រូវបន្ថែមពីសោហ៊ុយទទួលការសងនៅពេលកំណត់ ដូចជាសោហ៊ុយសំរាប់គណនាប្រាក់សារជាថ្មី សោហ៊ុយលើកិច្ចសន្យាជាដើម។

## ផ្នែកទី២៖ ការរំលាយ និងការលុបចោលកិច្ចសន្យាខ្ចីបរិភោគ

### កថាខណ្ឌទី១៖ មូលហេតុនៃការរំលាយកិច្ចសន្យាខ្ចីបរិភោគ

ការរំលាយកិច្ចសន្យា គឺជាការរំលត់កាតព្វកិច្ចរវាងភាគី នៃកិច្ចសន្យាទៅវិញទៅមក។ ភាគីនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។[54] ការបំពានយ៉ាងធ្ងន់ធ្ងរគឺសំដៅទៅលើករណីដែលភាគីម្ខាង មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា។[55] តាមស្មារតីនៃបញ្ញត្តិ នេះមានគោលបំណងបញ្ជាក់ពីភាពគ្មានលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច។

#### ១. មូលហេតុនៃការរំលាយរបស់ភាគីអ្នកឱ្យខ្ចី

ការរំលាយកិច្ចសន្យា គឺសំដៅទៅលើសកម្មភាពឯកតោភាគី ដែលធ្វើឱ្យភាគីទាំងសងខាងរួចផុតពីកាតព្វកិច្ចនៅក្នុងកិច្ចសន្យា លើកលែងតែករណីសងការខូចខាត (មាត្រា៤១១ នៃក្រមរដ្ឋប្បវេណី)។ រីឯការរំលាយកិច្ចសន្យាខ្ចីបរិភោគវិញក៏ភាគីទាំងសងខាងមានសិទ្ធិរំលាយកិច្ចសន្យាបានដែរនៅពេលណាដែលមានភាគីណាម្ខាងមិនអនុវត្តកាតព្វកិច្ច។ ជាក់ស្តែងដូចការរំលាយដោយការធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកឱ្យខ្ចី ពោលគឺនៅចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើងរហូតដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់ចុះយ៉ាងខ្លាំងដែលនាំឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគនោះបាន។ ប៉ុន្តែក្នុងករណីនេះដែរប្រសិនបើអ្នកឱ្យខ្ចី ទទួលបានកម្រៃជើងសារឬតម្លៃថ្នូរផ្សេងៗជាមុន នោះអ្នកឱ្យខ្ចីមានករណីយកិច្ចសងទៅអ្នកខ្ចីវិញ។[56] ចំពោះកម្មវត្ថុវិញ ប្រសិនបើអ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុ ដោយពុំដឹងថាជាវត្ថុរបស់អ្នកដទៃ ប្រសិនបើពុំអាចធ្វើឱ្យអ្នកខ្ចីបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ឬវត្ថុជំនួសទេ អាចរំលាយកិច្ចសន្យាបាន ប៉ុន្តែបើអ្នកខ្ចីសុចរិត មានសិទ្ធិទាមទារសំណងការខូចខាត (ផ្អែកតាមបញ្ញត្តិមាត្រា ៥៨៨ នៃក្រមរដ្ឋប្បវេណី)។[57] **ឧទាហរណ៍៖** ក្នុងករណីប្រសិនបើអ្នកខ្ចីបានប្រគល់ស្រូវ ដោយយល់ច្រឡំថាជារបស់ខ្លួនទៅឱ្យអ្នកខ្ចី ប៉ុន្តែមិនមែនជាកម្មសិទ្ធិរបស់ខ្លួនទេនោះ។ ជាដំបូងអ្នកឱ្យខ្ចីមានករណីកិច្ចធ្វើឱ្យអ្នកខ្ចីធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុនោះ ឬប្រគល់វត្ថុផ្សេងជំនួសវត្ថុនោះទៅឱ្យអ្នកខ្ចី។ ប៉ុន្តែ

[54] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[55] មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[56] មាត្រា ៥៨១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] មាត្រា៥៨៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រសិនបើមិនអាចធ្វើបានទេ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យានោះបាន លុះត្រាតែអ្នកឱ្យខ្ចីនោះសុចរិត។ ម៉្យាងទៀតចំពោះការខ្ចីបរិភោគដោយមានការប្រាក់ ប្រសិនបើអ្នកខ្ចីសុចរិត អ្នកឱ្យខ្ចីត្រូវសងនូវសំណងនៃការខូចខាតចំពោះអ្នកខ្ចី។

**២. មូលហេតុនៃការរំលាយរបស់ភាគីអ្នកខ្ចី**

អលទ្ធភាពអនុវត្តកាតព្វកិច្ចជាការមិនមានកំហុសរបស់ភាគីណាមួយនោះទេ ម៉្យាងទៀតអ្នកខ្ចីក៏អាចរំលាយកិច្ចសន្យាបាន ករណីដែលអ្នកឱ្យខ្ចីពុំអាចអនុវត្តកាតព្វកិច្ចបាន ផ្ទុយទៅវិញអ្នកខ្ចីក៏អាចរំលាយកិច្ចសន្យាកិច្ចសន្យាខ្ចីបរិភោគបានផងដែរ។[58]

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មសិទ្ធនៃវត្ថុនោះហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន។ ប្រសិនបើអ្នកឱ្យខ្ចីពុំអាចអនុវត្តកាតព្វកិច្ចខាងលើនេះបានទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន។

នៅក្នុងករណីដែលការមិនទទួលសំណើរផ្តល់ការសងរបស់ម្ចាស់បំណុល គឺជាការបំពានករណីយកិច្ចដ៏ធ្ងន់ធ្ងរពីម្ចាស់បំណុល នោះកូនបំណុលអាចរំលាយកិច្ចសន្យាបាន។[59]

**កថាខណ្ឌទី២៖ មូលហេតុនៃការលុបចោលកិច្ចសន្យាខ្ចីបរិភោគ**

ជាគោលការណ៍ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈរបស់គូភាគីតាមរយៈសំណើ និងស្ទីការត្រូវគ្នា ហើយនឹងបង្កើតឱ្យមាននូវសិទ្ធិ និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ ក៏ប៉ុន្តែនៅក្នុងករណីភាគីម្ខាងនៃកិច្ចសន្យាបានបង្ហាញឆន្ទៈដោយមានវិការៈ ឬដោយមូលហេតុនៃសមត្ថភាពក្នុងការយល់ដឹងរបស់ខ្លួន ឬដោយអំពើទុច្ចរិតរបស់ភាគីម្ខាងទៀត ដែលបានធ្វើឱ្យខាតបង់នូវផលប្រយោជន៍របស់ភាគីនោះ។

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិដល់ភាគីម្ខាងទៀតដែលបានខូចខាតនូវផលប្រយោជន៍ពីការចុះកិច្ចសន្យាដោយមានវិការៈ ឬកិច្ចសន្យាដែលបានធ្វើឡើងដោយអសមត្ថជន អាចធ្វើការលុបចោលកិច្ចសន្យានោះវិញបាន។ ក្នុងន័យនេះ មានន័យថាកិច្ចសន្យាមិនអាចមានអានុភាពឡើយប្រសិនបើត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ឬកិច្ចសន្យាដែលនាំឱ្យមានការខាតបង់នូវផលប្រយោជន៍របស់ភាគីណាមួយ ហើយភាគីនោះ ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធអាចអនុវត្តសិទ្ធិលុបចោលនូវកិច្ចសន្យានោះបាន។

[58] មាត្រា ៥៨៨-២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា ៤៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សកម្មភាពដែលអាចលុបចោលបានមានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល អះអាងអំពីសកម្មភាពនោះ ហើយក្រោយពេលលុបចោល សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ក៏ប៉ុន្តែការលុបចោលត្រូវធ្វើឡើងតាមវិធីនៃការជូនដំណឹងទៅភាគីម្ខាងទៀត ហើយនឹងមានអានុភាពគិតចាប់ពីពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។

**១. មូលហេតុនៃការលុបចោលរបស់ភាគីអ្នកឱ្យខ្ចី**

កិច្ចសន្យាមិនអាចមានអានុភាពឡើយ ប្រសិនបើត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវតាមកំណត់របស់ច្បាប់ ឬកិច្ចសន្យាដែលនាំឱ្យមានការខាតបង់នូវប្រយោជន៍របស់ភាគីណាមួយ ហើយភាគីនោះ ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធអាចអនុវត្តសិទ្ធិលុបចោលនូវកិច្ចសន្យានោះបាន។ ចំណែកឯកិច្ចសន្យាខ្ចីបរិភោគវិញ ភាគីទាំងសងខាងក៏អាចធ្វើការលុបចោលនូវកិច្ចសន្យាបានដែរ ជាពិសេសគឺភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ទាក់ទងទៅនឹងកិច្ចសន្យា។ ជាក់ស្តែងនៅពេល ដែលភាគីអ្នកឱ្យខ្ចីបានរកឃើញថាមានវិការៈក្នុងការបង្ហាញឆន្ទៈរបស់អ្នកខ្ចីនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ អាចធ្វើការលុបចោលកិច្ចសន្យានោះបាន។

វិការៈក្នុងការបង្ហាញឆន្ទៈនោះមានដូចជា៖

- **ការភាន់ច្រឡំ៖** ជាការយល់ខុសទៅលើអ្វីដែលជាកម្មវត្ថុនៃកិច្ចសន្យាដោយផ្ទុយពីភាពពិតនៃវត្ថុនោះក៏ថាបាន។[60] ពោលគឺនៅពេលដែលភាគីអ្នកឱ្យខ្ចីយល់ច្រឡំខុសទៅលើកម្មវត្ថុដែលអ្នកខ្ចីប្រគល់ឱ្យ ដែលការពិតកម្មវត្ថុមិនមានតាមអ្វីដែលបានសន្យា។
- **ការឆបោក៖** ជាចេតនាទុច្ចរិតរបស់ភាគីម្ខាងទៀត ដែលមានបំណងបង្ហាញនូវអ្វីដែលមិនមែនជាការពិត ដើម្បីទទួលបាននូវផលប្រយោជន៍អ្វីមួយពីកិច្ចសន្យា។[61] ជាក់ស្តែងដូចករណីដែលអ្នកខ្ចីបានបោកប្រាស់នូវទំនុកចិត្ត មិនធ្វើតាមការព្រមព្រៀងគេចវេសមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។
- **ការបង្ហាញព័ត៌មានមិនពិត៖** គឺជាការបង្ហាញទៅដល់ភាគីម្ខាងទៀតនូវអ្វីដែលមិនមែនជាការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈនូវការជឿជាក់ថាហេតុទាំងនោះជាការពិត។[62]
- **ការគម្រាមកំហែង៖** ជាការយល់ព្រមទៅលើការបង្កើតកិច្ចសន្យាដោយអឆន្ទៈរបស់ខ្លួន ប៉ុន្តែប្រសិនបើមិនយល់ព្រម ចំពោះការបង្កើតនោះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ណាមួយរបស់ខ្លួនជាមិនខាន។ ការចាត់ទុកជាការគម្រាមលុះត្រាតែភាគីនោះ បានជឿជាក់ថាប្រសិនបើខ្លួនមិនយល់ព្រម

[60] មាត្រា ៣៤២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[61] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នោះស្ថានភាពនៃការខូចខាតផលប្រយោជន៍នោះ ពិតជាអាចកើតឡើងជាមិនខាន។[63] **ឧទាហរណ៍៖** ក បានគម្រាម ខ ថាបើមិនមិនចុះហត្ថលេខាលើលិខិតលើកលែងបំណុលចំនួន ១០ ០០០ដុល្លារ ដែល ក មានចំពោះ ខ នោះទេ ខ្លួននឹងវាយ ខ នៅថ្ងៃទី ១ ខែ មករា ឆ្នាំ២០២២ ។ ខ ក៏បានចុះហត្ថលេខាលិខិតលើកលែងបំណុលនោះ ដោយសារភ័យខ្លាច។ ក្នុងករណីនេះ ខ អាចលុបចោលការលើកលែងបំណុលចំពោះ ក ដោយផ្អែកលើការគំរាមកំហែង (មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី)។

- **ឋបនីយផ្លូវចិត្ត៖** ជាការបង្ហាញឆន្ទៈដែលផ្ទុយពីអ្វីដែលខ្លួនយល់ឃើញ ឬផ្ទុយពីឆន្ទៈពិតប្រាកដរបស់ខ្លួន។[64] អាចបញ្ជាក់បានថាគោលបំណងរបស់អ្នកបង្កើតគឺផ្ទុយពីអ្វីដែលខ្លួនបានព្រមព្រៀង ដោយសារតែប្រការណាមួយ។
- **ការរំលោភលើស្ថានភាព៖** នៅពេលធ្វើកិច្ចសន្យាភាគីម្ខាងបានប្រើឋានៈរបស់ខ្លួនដើម្បីកេងយកចំណេញពីកិច្ចសន្យា ហើយភាគីម្ខាងទៀតមិនអាចតបតបាន។[65]
- **អំពើកេងចំណេញហួសហេតុ៖** ក្នុងករណីដែលភាគីម្ខាងបានចុះកិច្ចសន្យាដោយយកការឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាបាន។[66]

### ២. មូលហេតុនៃការលុបចោលរបស់ភាគីអ្នកខ្ចី

ភាគីទាំងសងនៃកិច្ចសន្យាគឺមានសិទ្ធិស្មើគ្នាក្នុងការលុបចោលកិច្ចសន្យាខ្ចីបរិភោគ ប្រសិនបើរកឃើញថាមានភាគីណាម្នាក់បានបង្ហាញឆន្ទៈដែលមានវិការៈ ឬភាគីដែលបានខាតបង់ប្រយោជន៍ ដោយការចុះកិច្ចសន្យាខ្ចីបរិភោគនេះ។ មិនតែប៉ុណ្ណោះភាគីអ្នកខ្ចី ក៏មានអាទិភាពក្នុងការលុបចោលកិច្ចសន្យាពីអ្នកឱ្យខ្ចីបានដែរ ក្នុងករណីដែលបានរកឃើញមានវិការៈដែលបង្ហាញឡើងតាមឆន្ទៈ ឬកាយវិការខុសប្រក្រតីណាមួយ។ ពោលគឺក្នុងករណីដែលអ្នកឱ្យខ្ចីមានកេងប្រវ័ញ្ចហួសហេតុទៅលើភាគីអ្នកខ្ចី តាមរយៈការយកនូវការប្រាក់ខ្ពស់ហួសពីច្បាប់កំណត់ ដោយហេតុថាអ្នកខ្ចីខ្វះនូវចំណេះដឹង មានភាពល្ងង់ខ្លៅទើបភាគីអ្នកឱ្យខ្ចីធ្វើការកេងចំណេញ បញ្ហានេះភាគីអ្នកខ្ចីអាចធ្វើការសុំលុបចោលនូវកិច្ចសន្យានោះបាន។ លើសពីនេះទៀតអាចមកពីការរងនូវការ

[63] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[64] មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[65] មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[66] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គំរាមគំហែងពីអ្នកឱ្យខ្ចី។ **ឧទាហរណ៍៖** លោក ក បានប្រាប់ទៅ ខ ថាបើមិនចង់ស្លាប់ទេ គឺត្រូវតែចុះកិច្ចសន្យាឱ្យខ្ចី ដើម្បីធ្វើអាជីវកម្មរបស់ខ្លួន។ ដោយសារតែមានភាពភ័យខ្លាច លោក ខ ក៏បានយល់ព្រមក្នុងការចុះកិច្ចសន្យាឱ្យលោក ក ខ្ចីដី។ ក្នុងករណីនេះលោក ខ អាចលុបចោលកិច្ចសន្យាដោយផ្អែកលើការគម្រាមកំហែងបាន។ ម្យ៉ាងទៀតមានករណីខ្លះ ការឆបោក ដែលជាចេតនាទុច្ចរិតរបស់ភាគីម្ខាងទៀត ដែលមានបំណងបង្ហាញនូវអ្វីដែលមិនមែនជាការពិត ដើម្បីទទួលបានជាផលប្រយោជន៍អ្វីមួយពីកិច្ចសន្យា។ ជាក់ស្តែងដូចភាគីអ្នកឱ្យខ្ចីបានបោកប្រាស់នូវទំនុកចិត្ត ការជឿជាក់ មិនច្បាស់លាស់កម្មវត្ថុដែលបានប្រគល់ឱ្យទៅអ្នកខ្ចី ជារបស់តតិយជន ដូចនេះភាគីអ្នកខ្ចីអាចអះអាងអានុភាពនៃការលុបចោលកិច្ចសន្យាដោយផ្អែលលើការឆបោកបាន។

## ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទនៃកិច្ចសន្យាខ្ចីបរិភោគ

### កថាខណ្ឌទី១៖ នីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ គឺជាការដោះស្រាយវិវាទមួយដែលមានលក្ខណៈឆាប់រហ័សជាងការដោះស្រាយតាមប្រព័ន្ធតុលាការដោយតាមរយៈអ្នកតំណាង ឬមជ្ឈត្តករ។ សារៈប្រយោជន៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺការចំណេញពេលវេលា និងថវិការ ហើយគូភាគីទាំងអស់អាចបញ្ចប់ជំលោះដោយអស់ចិត្ត គឺមិនមានការគុំគួននឹងគ្នា ព្រោះសេចក្តីសម្រេចរបៀបនេះ គឺកើតចេញពីការព្រមព្រៀងរបស់ភាគីនៃវិវាទដោយសន្តិវិធី។

ដំណោះស្រាយក្រៅប្រព័ន្ធតុលាការនេះស្តែងឡើងតាមរូបភាពជាច្រើនដូចជា មជ្ឈត្តករពាណិជ្ជកម្មសន្ធានការី ការចរចាររវាងគូភាគី ការផ្សះផ្សា ជាដើម។ ក៏ប៉ុន្តែដោយសារតែមជ្ឈត្តករពាណិជ្ជកម្មក្នុងស្រុកមិនទាន់ដំណើរការពេញលេញ ដូចនេះការដោះស្រាយវិវាទតាមមជ្ឈត្តករពាណិជ្ជកម្មមិនមានប្រជាប្រិយភាពក្នុងស្រុក។

**១. ការចរចារ**

ភាគីនៃកិច្ចសន្យាធ្វើការចរចារលើចំណុចរួមដែលអាចអនុវត្តបាន។ ចំណែកឯពេលវេលា និងកាលបរិច្ឆេទក៏ ភាគីជាអ្នកធ្វើការជ្រើសរើសដែរ។ ការដោះស្រាយតាមរយៈការចរចារនេះ គឺមាននូវរយៈពេលលឿនជាងដំណោះស្រាយណាៗទាំងអស់។ ការចរចារបែបនេះវាអាចសម្រេចបានក្នុងរយៈពេល១ថ្ងៃ ឬលើសពីនេះ។ ជាទូទៅ ការដោះស្រាយវិវាទ ដែលមានការចរចាររវាងគូភាគីនេះត្រូវធ្វើឡើងតាមរយៈការសះជា។ ការសះជា គឺសំដៅទៅលើកិច្ចសន្យាដែលភាគីបានព្រមព្រៀងបញ្ចប់វិវាទ ដោយរវាងគូភាគី និងធ្វើសម្បទានទៅវិញទៅមក។[67] អានុភាពនៃកិច្ចសន្យាសះជានេះ ត្រូវបានអនុវត្តតាមរយៈការផ្ទេរសិទ្ធិរបស់ភាគីទី១ ទៅឱ្យភាគីទី២

[67] មាត្រា ៧២៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទៀតជារៀងរហូត ទោះបីជារកឃើញភស្តុតាងជាក់លាក់ថាភាគីទី២ មិនមានសិទ្ធិមកលើវត្ថុដែលជាកម្មវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាសះជាក៏ដោយ។[68] កិច្ចសន្យាសះជានេះមិនអាចមោឃៈដោយសារតែមានការភាន់ច្រឡំទៅលើសិទ្ធិដែលជាកម្មវត្ថុនៃវិវាទបានឡើយ។[69]

### ២. សន្ធានកម្ម៖ កិច្ចសម្របសម្រួលតាមរយៈអាជ្ញាធរដែនដី

ជាទូទៅនៅពេលមានជំលោះកើតឡើង ក្រៅពីការដោះស្រាយទៅតាមប្រព័ន្ធតុលាការ គឺភាគីច្រើនទៅរកអាជ្ញាធរដែនដី (មេឃុំ ឬចៅសង្កាត់) ដើម្បីធ្វើការសម្របសម្រួល បន្ទាប់ពីការការចរចាររវាងគូភាគីមិនបានសម្រេច។

ជាបឋមដើមចោទអាចដាក់ពាក្យបណ្តឹងនៅការិយាល័យឃុំ ឬសង្កាត់ បន្ទាប់មកទើបសង្កាត់បញ្ជូនពាក្យបណ្តឹងទាំងនោះទៅឱ្យចុងចម្លើយដើម្បីកោះហៅឱ្យភាគីទាំងពីរមកជុំគ្នា ហើយភាគីទាំងពីរក៏អាចនាំសាក្សីរបស់ខ្លួនដើម្បីមកធ្វើការដាក់បន្ទុក ឬដោះបន្ទុកឱ្យខ្លួន និងនាំយកនូវភស្តុតាងនានាដែលមានពាក់ព័ន្ធទៅនឹងបណ្តឹងនេះ ក៏ប៉ុន្តែមេឃុំ ឬចៅសង្កាត់មិនមានសិទ្ធិក្នុងការចាប់បង្ខំឱ្យគូភាគីធ្វើតាមការសម្រេចរបស់ខ្លួនបានទេ។

ប្រសិនបើការដោះស្រាយនេះបានសម្រេច សង្កាត់ត្រូវចេញនូវលិខិតសះជា ឬក៏តាមរយៈកំណត់ហេតុសម្រុះសម្រួលមួយដើម្បីបញ្ជាក់ថាវិវាទត្រូវបានបញ្ចប់ដោយស្ថាពរ ក៏ប៉ុន្តែប្រសិនបើភាគីនៅតែមិនសុខចិត្តទៀតនោះ ពួកគេអាចដាក់ពាក្យបណ្តឹងទៅតុលាការជាបន្តទៀតបាន។

នៅក្នុងឧបសម្ព័ន្ធយោងខាងក្រោយនឹងបង្ហាញអំពីលិខិតសះជា មួយដែលក្នុងនោះត្រូវចុះនិទ្ទេសមួយចំនួនដែលមានដូចជាលេខពាក្យបណ្តឹង ថ្ងៃ ខែ ឆ្នាំ កាលបរិច្ឆេទរបស់លិខិតបញ្ជាំ និងកាលបរិច្ឆេទចុះកិច្ចសន្យា ឈ្មោះគូភាគី អាស័យដ្ឋាន និងលេខអត្តសញ្ញាណប័ណ្ណជាដើម។ ចំពោះខ្លឹមសារវិញត្រូវចុះអំពីការព្រមព្រៀងរវាងភាគីទាំងពីរ ហើយចុងបញ្ចប់ត្រូវមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាក្សីទាំងសងខាង និងហត្ថលេខា ឬស្នាមមេដៃរបស់អ្នកបំពេញកិច្ចសន្យា។ ចំពោះរឿងមួយចំនួនដែលតម្លៃកម្មវត្ថុនៃកិច្ចសន្យា មានតម្លៃខ្ពស់គឺត្រូវបានបញ្ជូនទៅកាន់សមត្ថកិច្ចស្រុក ឬខណ្ឌជាអ្នកធ្វើការដោះស្រាយវិញដែលជាទូទៅតំលៃនោះត្រូវគិតចាប់ពីបីពាន់ដុល្លារសហរដ្ឋអាមេរិកឡើង។[70]

ផលប្រយោជន៍អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ គឺវាបានធ្វើឱ្យភាគីទាំងសងខាងចំណេញពេលវេលា ចំណេញប្រាក់កាក់ គ្មានអ្នកឈ្នះក៏គ្មានអ្នកចាញ់ ម្យ៉ាងវិញទៀតនៅក្រោយពេលដែលវិវាទត្រូវបាន

[68] មាត្រា ៧២៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69] មាត្រា ៧២៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[70] ការសម្ភាសន៍ជាមួយចៅសង្កាត់ ខាត់ ណារិទ្ធិ ឆ្នាំ២០០៩

ដោះស្រាយហើយ គូវិវាទគ្មានការគុំគួននឹងគ្នាព្រោះថាលទ្ធផលដែលទទួលបាននោះគឺសុទ្ធតែកើតចេញពីការព្រមព្រៀងរបស់គូវិវាទទាំងសងខាងប៉ុណ្ណោះ។

នៅក្នុងដំណើរការសន្ធានកម្ម សន្ធានការីគ្រាន់តែជាអ្នកជួយសម្រួលភាពតានតឹងរវាងភាគី និងអ្នកជួយផ្តល់នូវជម្រើសក៏ដូចជាដំណោះស្រាយជូនភាគីប៉ុណ្ណោះ។ សន្ធានការីគ្មានសិទ្ធិក្នុងការចាប់បង្ខំឱ្យភាគីទទួលយកដំណោះស្រាយណាមួយដែលពួកគេមិនពេញចិត្តឡើយ។ នៅក្នុងដំណើរការនេះលទ្ធផលគឺត្រូវគ្រប់គ្រងដោយភាគីវិវាទសិទ្ធិក្នុងការចេញសេចក្តីសម្រេចសំរាប់ភាគីនោះទេ។ ចំពោះរាល់ការសម្រេចចិត្តផ្សេងៗ គឺភាគីជាអ្នកដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើវិវាទរបស់ខ្លួន។

**៣. មជ្ឈត្តការ**

មជ្ឈត្តការ គឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចម្បងទី៣ (ការចរចារ សន្ធានកម្ម និង មជ្ឈត្តការ)។ នៅក្នុងមជ្ឈត្តការគូភាគីដាក់វិវាទរបស់ខ្លួនទៅភាគីទី៣ដែលអព្យាក្រឹត្យមួយ។ ភាគីទី៣នេះពិចារណាអំពី ភស្តុតាង ដែលភាគីបានដាក់ជូន និងចេញសេចក្តីសម្រេចមួយហៅថា មជ្ឈត្តវិនិច្ឆ័យ។

មជ្ឈត្តវិនិច្ឆ័យ ជាការសម្រេចដែលធ្វើឡើងដោយវេទិកាមជ្ឈត្តកម្ម មានលក្ខណៈស្ថាពរ ហើយមិនត្រូវបានពិនិត្យឡើងវិញលើអង្គសេចក្តីទេ។ ដូច្នេះគូភាគីវិវាទអាចជៀសវាងដំណើរការវែងឆ្ងាយនៃបណ្តឹងឧទ្ធរណ៍ធម្មតា ក្រោមប្រព័ន្ធតុលាការជាតិ។

ប្រសិនបើគូភាគីមានកិច្ចព្រមព្រៀង មជ្ឈត្តការជាមុនស្រាប់ ដែលជាទូទៅជាផ្នែកមួយនៃកិច្ចសន្យាដើម ភាគីម្ខាងត្រូវបង្ហាញភាគីម្ខាងទៀតនូវសំណើរជាលាយលក្ខ័ណ៍អក្សរ ដើម្បីធ្វើមជ្ឈត្តការ។ យោងទៅតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សំណើរជាលាយលក្ខ័ណ៍អក្សរនោះ ទៅប្រគល់ដល់ភាគីម្ខាងទៀតដោយផ្ទាល់ ឬទៅដល់ទីកន្លែងអាជីវកម្ម លំនៅស្ថានអចិន្ត្រៃយ៍ ឬអាស័យដ្ឋានប្រៃសណីយ៍របស់គាត់។ ភាគីដែលផ្តួចផ្តើមធ្វើមជ្ឈត្តការហៅថា “ ភាគីប្តឹង ” ហើយភាគីដែលទទួលសំណើរហៅថា “ ភាគីឆ្លើយតប ”។ ដំណើរការមជ្ឈត្តកម្មចាប់ផ្តើមនៅពេលភាគីឆ្លើយតបបានទទួលសំណើរ។ អ្នកប្តឹងអាចទាមទារត្រូវបញ្ជាក់នៅក្នុងពាក្យបណ្តឹងទាមទារដូចជា អង្គហេតុដែលគាំទ្រការទាមទារ ចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ។ នៅពេលដែលភាគីប្តឹងដាក់ពាក្យបណ្តឹងរួច ភាគីឆ្លើយតបក៏ត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនដែរ។ ភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួន ដែលឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងទាមទារ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងបណ្តឹងតបដែលខ្លួនមានផង។ ករណីនេះមិនមានកំណត់ពេលវេលាឡើយសំរាប់ការធ្វើបណ្តឹងដោះសាររបស់ភាគីឆ្លើយតបទេ លើកលែងតែមានបញ្ជាក់ដោយមជ្ឈត្តករ។

មជ្ឈត្តការ អនុញ្ញាតឱ្យគូភាគីវិវាទធ្វើការកំណត់នីតិវិធីដែលពួកគេចង់បាន ហើយយកមកអនុវត្តលើដំណើរការមជ្ឈត្តការរបស់ពួកគេ។ ផ្អែកទៅតាមតម្រូវការជាក់ស្តែងនៃវិវាទគូភាគីអាចជ្រើសរើសវិធានច្បាប់ដែលអាចយក មកអនុវត្តបាន ទីកន្លែងធ្វើមជ្ឈត្តការ និងកំណត់គុណវុឌ្ឍិរបស់មជ្ឈត្តករបាន។

ក្រោយពេលប្តឹងទាមទារបានដាក់ជាបឋម ភាគីវិវាទត្រូវជ្រើសរើសមជ្ឈត្តករ ដើម្បីគ្រប់គ្រងដំណើរការដោះស្រាយវិវាទរបស់ខ្លួន។ ភាគីវិវាទមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករតាមតម្រូវការ ក៏ប៉ុន្តែត្រូវកំណត់ចំនួនមជ្ឈត្តករជាចំនួនសេសមិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងតុលាការព្រមទាំងមិនធ្លាប់បានផ្តន្ទាទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយទេ។ ប្រសិនបើភាគីវិវាទមិនបានកំណត់ចំនួនមជ្ឈត្តករទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) រូប។ មជ្ឈត្តករដែលបានជ្រើសរើស មិនត្រូវបានបដិសេធដោយសារមូលហេតុសញ្ជាតិទេ។ ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬលើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬលើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរមជ្ឈត្តការ។ ភាពបត់បែន និងការបញ្ចប់ជាស្ថាពរយ៉ាងរលូននៃដំណើរការនៃមជ្ឈត្តវិនិច្ឆ័យតែងតែជួយភាគីដោះស្រាយវិវាទបានយ៉ាងឆាប់រហ័ស និងចំណាយតិច ប្រសិនបើប្រៀបធៀបទៅនឹងដំណោះស្រាយវិវាទនៅតុលាការ ឬតាមមធ្យោបាយផ្សេងៗទៀត។ ការចំណាយពាក់ព័ន្ធនឹងមជ្ឈត្តការ ជាទូទៅគឺទាបជាងការចំណាយនៅក្នុងនីតិវិធីតុលាការ។

ការអនុវត្តសាលដីការបស់តុលាការបរទេស គឺមានភាពស្មុគស្មាញ ហើយភាគច្រើនមិនអាចធ្វើទៅបានដោយសារគ្មានការទទួលស្គាល់បដិការវាងប្រទេសកម្ពុជា និងបណ្តាប្រទេសភាគច្រើននៅលើពិភពលោក។ ផ្ទុយទៅវិញមជ្ឈត្តវិនិច្ឆ័យអាចអនុវត្តបានយ៉ាងទូលំទូលាយ ដោយសារមានអនុសញ្ញាទីក្រុងញូយ៉ក ឆ្នាំ១៩៥៨ ស្តីពីការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសដែលមានប្រទេសជាភាគីហត្ថលេខីជាង១៦០ (មួយរយហុកសិប)អនុសញ្ញានេះតម្រូវឱ្យរដ្ឋនីមួយៗទទួលស្គាល់ និងអនុវត្តមជ្ឈិត្តវិនិច្ឆ័យបរទេសដោយមិនធ្វើការពិនិត្យឡើងវិញលើអង្គសេចក្តីទេ។

មជ្ឈត្តការ គឺជាប្រព័ន្ធដោះស្រាយវិវាទមួយដែលមានលក្ខណៈអន្តរជាតិ សមស្របសម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្ម។ មជ្ឈត្តករទាំងអស់មានប្រវត្តិរូប និងបទពិសោធន៍ចំរុះ ទាក់ទងនឹងប្រព័ន្ធច្បាប់ក៏ដូចជាជំនាញបច្ចេកទេសផ្សេងៗ។ លើកលែងតែមានការព្រមព្រៀងគ្នាពីគូភាគីវិវាទ ដំណើរការមជ្ឈត្តកម្ម គឺមានភាពសម្ងាត់ ដូច្នេះវាមិនបើកចំហរជាសាធារណៈឡើយ។

## កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទតាមរយៈស្ថាប័នតុលាការ

### ១. តុលាការខេត្តក្រុង

សមត្ថកិច្ចរបស់តុលាការកម្ពុជា អាចទទួលដោះស្រាយគ្រប់រឿងក្ដីទាំងអស់បូករួមទាំងរឿងក្ដីរដ្ឋប្បវេណីផងដែរ។ ការដោះស្រាយវិវាទ តាមរយៈតុលាការនេះ ត្រូវបានដោះស្រាយតាមឋានានុក្រមនៃតុលាការ ដែលមាន២ជាន់ ៣ ថ្នាក់។ នីតិវិធីនៃបណ្ដឹង ជាបឋមដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការខេត្តក្រុង នៃកន្លែងដែលបង់រូបិយណត្តិ ឬមូលប្បទានបត្រ ឬកន្លែងធ្វើការប្រគល់វត្ថុ ជាកម្មវត្ថុនៃកិច្ចសន្យា ដោយនៅក្នុងពាក្យបណ្ដឹងនោះ ដើមចោទត្រូវសរសេរជាលិខិតលាយលក្ខណ៍អក្សរដោយបញ្ជាក់នូវឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយឈ្មោះនិងអាស័យដ្ឋានស្របច្បាប់របស់អ្នកតំណាងដែលច្បាប់បានកំណត់។ អ្នកដាក់ពាក្យបណ្ដឹងក៏ត្រូវបញ្ជាក់អង្គហេតុ ឱ្យបានត្រឹមត្រូវ និងបញ្ជាក់នូវការទាមទាររបស់ខ្លួន រួមទាំងមធ្យោបាយតទល់ ដើម្បីទុកជាឯកសារត្រៀម។ នៅពេលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដាក់ពាក្យសុំ ដោយត្រូវបានគណនាទៅតាមកម្មវត្ថុនៃបណ្ដឹង មានន័យថាកាលណាតម្លៃវត្ថុនៃបណ្ដឹងកាន់តែខ្ពស់នាំឱ្យអត្រាពន្ធកាន់តែទាប ផ្ទុយមកវិញបើតម្លៃកាន់តែទាប នាំឱ្យតម្លៃអត្រាពន្ធកាន់តែខ្ពស់។ ក្រៅពីពន្ធលើការដាក់ពាក្យសុំនេះ នៅមានប្រាក់ប្រដាប់ក្ដីពីតុលាការ ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង បញ្ជូនឯកសារ សម្រាប់ជាសោហ៊ុយ ធ្វើដំណើរស្នាក់នៅ និងការចំណាយផ្សេងៗទៀត ដែលមានសារៈសំខាន់សម្រាប់ការប្រព្រឹត្តនៅក្នុងតុលាការ។ បន្ថែមពីនេះ នៅមានប្រាក់ប្រដាប់ក្ដីភាគី ដែលភាគីត្រូវបង់ទៅលើលិខិតដូចជាពាក្យបណ្ដឹង ថ្លៃចំណាយលើឯកសារនានា សោហ៊ុយប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅផ្សេងៗទៀត។ បន្ទាប់មកតុលាការដែលទទួលបន្ទុកលើរឿងក្ដីនេះត្រូវធ្វើការពិនិត្យទៅលើពាក្យបណ្ដឹង ថាតើវាស្របទៅនឹងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែរឬទេ? ប្រសិនបើតុលាការពិនិត្យទៅឃើញខ្វះខាតទាំងនោះ។ ប្រសិនបើភាគីមិនព្រមធ្វើតាមការណែនាំរបស់តុលាការ នោះតុលាការអាចនឹងចេញដីកាសម្រេចមិនចាត់ការចាត់ការក៏ប៉ុន្តែភាគីអាចដាក់ពាក្យប្ដឹងជំទាស់លើដីកាសម្រេចនោះបាន។ នៅពេលដែលពាក្យបណ្ដឹងបានបំពេញត្រឹមត្រូវហើយ ដាច់ខាតតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកដំបូងយ៉ាងឆាប់រហ័ស ដើម្បីកោះហៅឱ្យគូភាគីមកជុំគ្នា ហើយកំណត់រយៈពេលសាមសិនថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង។ នៅពេលដែលតុលាការកំពុងចាត់ការបណ្ដឹងដើម ចុងចម្លើយក៏អាចប្ដឹងតបមកវិញបានដែរ រហូតដល់ពេលទាញហេតុផលផ្ទាល់មាត់ លុះត្រាតែការទាមទារដែលជាកម្មវត្ថុ នៃបណ្ដឹងតបនោះទាក់ទងជាមួយការទាមទាររបស់ដើមបណ្ដឹង។ ភាគីទាំងសងខាងត្រូវត្រៀមឯកសារ ដោយបញ្ជាក់ពីមធ្យោបាយតទល់ ឬការពារខ្លួនដោយសេចក្ដីថ្លែងការណ៍ចំពោះមធ្យោបាយតទល់នោះ ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងបណ្ដឹង។ ចំពោះករណីភស្តុតាងវិញភាគីត្រូវបង្ហាញប្រាប់តុលាការទាំងអស់បូករួមទាំងឯកសារ

នានាដែលមានការពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងរឿងក្ដី ដូចជាវិក្កយបត្រធនាគារ កិច្ចសន្យា លិខិតបញ្ចាំនៅធនាគារ វិញ្ញាបនបត្រសំគាល់អចលនវត្ថុនៅឃុំសង្កាត់ ឬប្លង់កម្មសិទ្ធិដី ផ្ទះអាគារជាដើម។ ភាគីទាំងសងខាងត្រូវរៀបរាប់អំពីចម្លើយទៅតាមការពិតដោយមិនកុហកចំពោះមុខចៅក្រមជាដាច់ខាត បើភាគីណាមួយមានសាក្សី គឺតម្រូវធ្វើការស្បថជាមុនសិន មុននឹងឆ្លើយនូវសំណួររបស់ចៅក្រម ឬមេធាវីដើម្បីធ្វើការដាក់បន្ទុក ឬដោះបន្ទុកទៅលើភាគីណាមួយ។ ក្រោយពីបានពិនិត្យភស្តុតាងរួចអស់ហើយ ចៅក្រមត្រូវទទួលស្គាល់អង្គហេតុ ដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ប៉ុន្តែប្រសិនបើអង្គហេតុមានភាពជាក់ស្តែងតុលាការមិនចាំបាច់ធ្វើការយោងទៅតាមភស្តុតាងទេ។ បន្ទាប់មកតុលាការត្រូវធ្វើការការសាកល្បងផ្សះផ្សារជាបឋម លើកលែងតែភាគីយល់ថាមិនសមរម្យ។ បន្ទាប់មកតុលាការឱ្យក្រឡាបញ្ជីធ្វើការកត់ត្រា ជាកំណត់ហេតុនៅក្នុងនីតិវិធីសម្រាប់ទាញហេតុផលនេះ នៅគ្រប់កាលបរិច្ឆេទនីមួយៗ នៅក្នុងបន្ទប់ត្រៀមរបស់តុលាការ ឬនៅក្នុងបន្ទប់ណាមួយក៏បានតាមរយៈការសម្រេចរបស់តុលាការ ដែលមានលក្ខណៈជាសាធារណៈ លើកលែងតែមានការយល់ព្រមពីភាគីទាំងពីជាមុន។ បន្ទាប់មកតុលាការត្រូវចេញនូវដីកាសម្រេច ប្រសិនបើភាគីមិនព្រមនោះទេ នីតិវិធីត្រូវឈានចូលដល់សវនាការដែលត្រូវធ្វើឡើងជាសាធារណៈ។ ប្រសិនបើមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ភាគី សវនាការត្រូវធ្វើជាសាធារណៈ។

ប្រសិនបើនៅក្នុងករណីនីតិវិធីត្រៀមទាញហេតុផលនៅក្នុងកាលបរិច្ឆេទលើកទី១ ដើមចោទអវត្តមាន តុលាការនឹងច្រានចោល ការទាមទាររបស់ដើមចោទ ហើយតុលាការនឹងចេញសាលក្រមកំបាំងមុខ។

នៅក្នុងកាលបរិច្ឆេទបន្តនៃនីតិវិធីត្រៀមទាញហេតុផល ដើមចោទអវត្តមាន តុលាការនឹងបញ្ឈប់នូវនីតិវិធីសំរាប់ត្រៀមទាញហេតុផលផ្ទាល់មាត់ភ្លាម ហើយឈានចូលដល់ការកំណត់កាលបរិច្ឆេទលើកទី១ នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទៀតផង។ ប្រសិនបើដើមចោទអវត្តមាន នៅកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ទៀត តុលាការនឹងចេញសាលក្រមកំបាំងមុខដើមចោទ។

បើចុងចម្លើយអវត្តមាន នៅដំណាក់កាលនៃការបរិច្ឆេទចំពោះការទាញហេតុផលផ្ទាល់មាត់ មានន័យថាចុងចម្លើយសារភាពតាមសេចក្ដីថ្លែងការណ៍ដើមចោទ ដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថាការទាមទាររបស់ដើមចោទត្រឹមត្រូវ នោះតុលាការទទួលការទាមទាររបស់ដើមចោទ តាមរយៈសាលក្រមកំបាំងមុខ តែបើការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេនោះ តុលាការនឹងច្រានចោលនូវការទាមទារនោះ។

ប៉ុន្តែ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើង នៅក្នុងករណីដែលភាគិមិនបានបង្ហាញខ្លួនដោយមិនបានទទួលការកោះហៅដោយស្របច្បាប់ ឬជាខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួននោះ ឬមិនបាន

ជូនដំណឹងដល់ចុងចម្លើយមុនកាលបរិច្ឆេទ ឬដោយសារនៅពេលនោះមានគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈណាផ្សេងទៀត ដែលមិនអាចជៀសវាងបាន ដោយមានការបញ្ជាក់ច្បាស់លាស់។

ភាគីណាដែលអវត្តមានដោយសារតែមូលហេតុដែលមិនអាចព្យាករណ៍ទុកបាន ហើយទទួលសាលក្រមកំបាំងមុខ ភាគីនោះអាចធ្វើការប្តឹងទាស់បាន។ អំឡុងពេលនៃបណ្តឹងទាស់នេះមានរយៈពេលពីរសប្តាហ៍ដោយគិតចាប់ពីពេលដែលភាគីទទួលបានការបញ្ជូនសាលក្រមកំបាំងនោះដោយមិនអាចព្យាករណ៍បានឡើយ។

នៅក្នុងករណីដែលភាគីប្តឹងទាស់អវត្តមាន នៅក្នុងកាលបរិច្ឆេទដំបូង នៃការអនុវត្តនីតិវិធីឡើងវិញនោះ តុលាការត្រូវច្រានចោលនូវបណ្តឹងទាស់នោះដោយចេញនូវសាលក្រមកំបាំងមុខលើកទីពីរ ដោយមិនអាចប្តឹងទាស់ចំពោះសាលក្រមនេះបានឡើយ។

ការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធអនុវត្តសិទ្ធិលើបំណុល ដែលកំណត់ដោយអំណាចរបស់រដ្ឋ។ ការអនុវត្តដោយបង្ខំមិនមែនអនុវត្តត្រឹមតែសាលក្រមនោះទេ គឺអនុវត្តរាល់សេចក្តីសម្រេចរបស់តុលាការដែលមានប្រសិទ្ធភាពអនុវត្តន៍។ ដូច្នេះការអះអាងផ្សេងរបស់អ្នកចាញ់ក្នុងរឿងក្តីនេះ មិនបានត្រូវយកមកពិចារណាក្នុងនីតិវិធីអនុវត្តដោយបង្ខំឡើយ។ ការអនុវត្តដោយបង្ខំត្រូវអនុវត្តដោយស្ថាប័នអនុវត្តគឺតុលាការអនុវត្ត និងអាជ្ញាសាលា។ ប៉ុន្តែដោយសារតែបច្ចុប្បន្ននេះអាជ្ញាសាលាមិនទាន់បានបង្កើតឡើងនូវឡើយ ដូចនេះគឺមានតែតុលាការមួយគត់។

នីតិវិធីនៃការអនុវត្តដោយបង្ខំ ជាដំបូងត្រូវដាក់ពាក្យសុំ ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរមានកំណត់ចំណុចដូចខាងក្រោមនេះ៖

១. ឈ្មោះ និងអាស័យដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាង

២. ឈ្មោះ និងអាស័យដ្ឋានរបស់កូនបំណុលនៃការអនុវត្ត ឬអ្នកតំណាង

៣. សញ្ញាណនៃលិខិតអនុវត្តមានន័យថាលិខិតអនុវត្តដែលបានភ្ជាប់ជាមួយនឹងពាក្យសុំ

៤. ខ្លឹមសារនៃសេចក្តីសម្រេច ដែលម្ចាស់បំណុលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល មានន័យថាលក្ខណៈនៃការសុំអនុវត្ត គឺអាចធ្វើបានដោយផ្ទាល់ ឬដោយប្រយោល។

៥. ខ្លឹមសារនៃសេចក្តីសម្រេចក្នុងលិខិតអនុវត្ត។

ការអនុវត្តដោយបង្ខំនេះត្រូវអនុវត្តនៅពេលកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។ តុលាការ អាចបង្ខំឱ្យកូនបំណុល បំពេញកាតព្វកិច្ច ដូចជាការបណ្តេញចេញ និងការពិន័យជាដើម។

**២. សាលាឧទ្ធរណ៍**

ប្រសិនបើភាគីណាមួយមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចរបស់សាលាដំបូង អាចប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ (មួយខែ) បានដើម្បីឱ្យសាលាឧទ្ធរណ៍ធ្វើការដោះស្រាយជាបន្ត។ សមាសភាពរបស់ចៅក្រមក្នុងករណីនេះមាន ៣ រូប ដែលធ្វើការដោះស្រាយដោយពិនិត្យលើអង្គហេតុ និងអង្គច្បាប់។

**៣. តុលាការកំពូល**

ក្នុងករណីដែល សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ នៅតែធ្វើឱ្យភាគីណាមួយ មិនពេញចិត្តទៀតនោះ ភាគីដែលមិនសុខចិត្តអាចធ្វើការប្តឹងសារទុក្ខលើកទី ១ មកតុលាការកំពូលបាន។ សមាសភាពរបស់ចៅក្រមមាន ៥ រូប ហើយធ្វើការពិនិត្យតែលើអង្គច្បាប់ប៉ុណ្ណោះ។ ប្រសិនបើតុលាការមើលឃើញថា មានភាពមិនត្រឹមត្រូវតុលាការអាចចេញសាលដីកាមួយ ដើម្បីបង្វិលសំណុំរឿងឱ្យសាលាឧទ្ធរណ៍ធ្វើការជំនុំជម្រះសារជាថ្មី ប៉ុន្តែត្រូវមានការផ្លាស់ប្តូរនូវសមាសភាពចៅក្រមចំនួន ៣ រូបជាថ្មី ជំនួសចៅក្រម ៣ រូបចាស់ ដែលជំនុំជម្រះនៅសាលាឧទ្ធរណ៍នោះ។ ក៏ប៉ុន្តែបើតុលាការពិនិត្យឃើញថា សេចក្តីសម្រេចចេញដោយសាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមអង្គច្បាប់ហើយនោះ ចៅក្រមនឹងចេញសាលដីកាមួយដើម្បីឱ្យសាលដីការបស់សាលាឧទ្ធរណ៍ចូលជាស្ថាពរ។ រាល់សាលដីការបស់តុលាការកំពូលត្រូវចូលជាស្ថាពរនៅថ្ងៃដែលចេញសាលដីកានោះតែម្តង។

បើបណ្តឹងសាទុក្ខលើកទី១ នៅតែមិនពេញចិត្តទៀត អាចប្តឹងសារទុក្ខលើកទី២ ជាបន្តទៀតបាន ដែលនៅក្នុងដំណាក់កាលនេះសមាសភាពចៅក្រមមាន ៩ រូប ហើយធ្វើការពិនិត្យមើលទៅលើអង្គហេតុ និងច្បាប់។ ក្រោយពេលដែលតុលាការកំពូលចេញសាលដីកាហើយ ភាគីមិនអាចធ្វើការប្តឹងបន្តទៀតបានឡើយ ព្រោះថាសាលដីកាសារទុក្ខលើកទី២ នេះជាបណ្តឹងបិទផ្លូវតវ៉ារបស់ភាគីទាំងពីរ។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីយើងខ្ញុំបានបកស្រាយនូវប្រធានបទ កិច្ចសន្យាខ្ចីបរិភោគ យ៉ាងលម្អិតមកបានសង្កេតឃើញថាកិច្ចសន្យាខ្ចីបរិភោគនេះជាកិច្ចសន្យាមួយប្រភេទ ដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់នៅក្នុងជីវភាពប្រចាំថ្ងៃ ក៏ដូចជានៅក្នុងកិច្ចការរកស៊ីផងដែរដោយអាស្រ័យតាមទំហំនៃភាពចាំបាច់របស់ប្រជាពលរដ្ឋ ឬតាមតម្រូវការស្ថានភាពអាជីវកម្មជាក់ស្ដែង។ ម៉្យាងទៀតកិច្ចសន្យាខ្ចីបរិភោគបានចូលរួមយ៉ាងច្រើនក្នុងវិស័យទំនាក់ទំនងឯកជន ជាពិសេសគឺទាក់ទងនឹងការខ្ចីចងកាប្រាក់ ឬការផ្ដល់ឥណទានតាមរយៈធនាគារ។ យ៉ាងណាមិញមនុស្សភាគច្រើនតែងតែធ្វើសកម្មភាពខ្ចីបរិភោគជាញឹកញាប់ ប៉ុន្តែពួកគេមិនសូវបានដឹងថា ការខ្ចីបែបនេះវាជាកិច្ចសន្យាខ្ចីបរិភោគនោះឡើយដោយគ្រាន់តែគិតថាជាការខ្ចីគ្នាទៅវិញទៅមកនៅពេលដែលមានជួបការលំបាកខ្វះខាតម្ដងៗតែប៉ុណ្ណោះ។ ប្រសិនបើពិនិត្យមើលខ្លឹមសារនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ កម្ពុជា កិច្ចសន្យាខ្ចីបរិភោគជាកិច្ចសន្យាមួយដែលមានចំណងគតិយុត្តិរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចី។ ថ្វីត្បិតតែកិច្ចសន្យានេះមានលក្ខខណ្ឌសុពលភាពដូចជាកិច្ចសន្យាទូទៅ ប៉ុន្តែកិច្ចសន្យានេះបានកំណត់លក្ខខណ្ឌពិសេសមួយចំនួន ដែលតម្រូវឱ្យគូភាគីត្រូវគោរពតាម។ មួយវិញទៀតយើងសង្កេតឃើញថា នៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះមានការបែងចែកជាការខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ និងការខ្ចីបរិភោគដែលគ្មានភ្ជាប់ការប្រាក់ ប៉ុន្តែជាទូទៅនៅក្នុងសង្គមយើងសព្វថ្ងៃនេះ ការដែលខ្ចីបរិភោគដែលភ្ជាប់ការប្រាក់មានលក្ខណៈសកម្មជាងការខ្ចីដែលគ្មានភ្ជាប់ការប្រាក់។ លើសពីនេះទៅទៀតចំពោះកិច្ចសន្យាខ្ចីបរិភោគបានចូលរួមយ៉ាងច្រើនក្នុងវិស័យទំនាក់ទំនងឯកជន ជាពិសេសគឺទាក់ទងនឹងការខ្ចីចងកាប្រាក់ ឬការផ្ដល់ឥណទានតាមរយៈធនាគារ ។ ក្នុងករណីនេះប្រសិនបើភាគីជាអ្នកឱ្យខ្ចី និងភាគីអ្នកខ្ចីមានយល់ដឹងច្បាស់អំពីការខ្ចីបរិភោគនេះ នោះភាគីទាំងសងខាងនឹងទទួលបាននូវផលប្រយោជន៍ និងផលចំណេញពីការខ្ចីនេះ។ ក៏ប៉ុន្តែប្រសិនបើមិនទាន់យល់ច្បាស់ពីកិច្ចសន្យាខ្ចីបរិភោគនេះទេ នោះវាជាបញ្ហាដែលនាំឱ្យមានវិវាទនៃកិច្ចសន្យានេះកើតឡើងដែលនាំឱ្យភាគីខាតបង់ពីកិច្ចសន្យា និងពេលវេលាជាមិនខាន។

ជាការពិតណាស់កាលណាករណីកិច្ចសន្យាវិវាទគឺ ពុំបានផ្ដល់ផលប្រយោជន៍ ចំពោះភាគីណាម្នាក់នោះទេ។ ហេតុដូចនេះហើយ ដើម្បីការពារប្រយោជន៍ភាគីទាំងសងខាង ត្រូវមានភាពច្បាស់លាស់នៅក្នុងគោលបំណងបង្កើតកិច្ចសន្យាគោលដៅនៃការយកទៅប្រើប្រាស់កម្មវត្ថុនៃការខ្ចីត្រូវមានការពិនិត្យឱ្យបានច្បាស់លាស់ដូចជា ករណីកម្មវត្ថុមានវិការៈ ឬការព្រមព្រៀងពិតប្រាកដែល មិនបានខាតបង់ផលប្រយោជន៍ដោយប្រការណាមួយនៅក្នុងការព្រមព្រៀង។ ជាពិសេសការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ភាគីអ្នកឱ្យខ្ចី និងភាគីអ្នកខ្ចី ត្រូវអនុវត្តកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក ចាប់តាំងពីបានព្រមព្រៀងគ្នាចុះកិច្ចសន្យា រហូតដល់កិច្ចសន្យាត្រូវបញ្ចប់ដើម្បីជៀសវាងមាននូវវិវាទកើតមានឡើង។

ដូចនេះភាគីនៃកិច្ចព្រមព្រៀងគួរតែប្រតិបត្តិគោលការណ៍នៃ **ភាពសុចរិត** និង **ភាពស្មោះត្រង់** ដើម្បីបំពេញការកាលិកឱ្យគ្នាទៅវិញទៅមកដែលអនុញ្ញាតឱ្យគូភាគីអនុវត្តសិទ្ធិនិងកាតព្វកិច្ចបានយ៉ាងល្អប្រសើរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបញ្ចប់ ការស្រាវជ្រាវទៅលើប្រធានបទ **កិច្ចសន្យាខ្ចីបរិភោគ** រួចមកយើងខ្ញុំសុំផ្តល់នូវសេចក្តីអនុសាសន៍ កែលំអក្នុងន័យស្ថាបនា ដើម្បីជាផលប្រយោជន៍សម្រាប់ការអនុវត្តក្នុងកិច្ចសន្យាខ្ចីបរិភោគ និងការពារកុំឱ្យកើតមានវិវាទកើតឡើង។

ការសិក្សាយល់ដឹងឱ្យច្បាស់អំពី កិច្ចសន្យាខ្ចីបរិភោគ បានផ្តល់ការយល់ដឹងកាន់តែច្រើនអំពីការខ្ចីបរិភោគ ការពារអំពីការឆបោក កេងប្រវ័ញ្ចនានា ពីសង្គមសព្វថ្ងៃ។ ជាក់ស្តែង នៅក្នុងសង្គមយើងសព្វថ្ងៃតែងមានការប្រាស្រ័យទាក់ទងគ្នាក្នុងការខ្ចីប្រាក់ដោយផ្ទាល់មាត់ ដោយគិតពីមនោសញ្ចេតនាភាគច្រើន ហើយច្បាប់ក៏មិនតម្រូវឱ្យធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរទាំងអស់នោះដែរ ទើបពេលខ្លះមានវិវាទកើតឡើងដែលមកពីភាគីណាមួយមិនអនុវត្តកាតព្វកិច្ចនោះ ច្បាប់មិនអាចស្វែងរកភស្តុតាង ឬសំអាងហេតុណាមួយមកដោះស្រាយទាមទារក្នុងសវនាការទេ ដោយសារតែកិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់ មិនមានស្នាមមេដៃ ឬលិខិតស្នាមអ្វីឡើយ។ ហេតុដូចនេះហើយភាគីទាំងសងខាងគួរតែធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីធានាឱ្យមានទំនុកចិត្តចំពោះភាគីទាំងសងខាង។

ចំពោះករណីដែលការខ្ចីនោះមានមិនភ្ជាប់ការប្រាក់ក៏ដោយក៏គួរណាស់តែធ្វើកិច្ចសន្យាខ្ចីបរិភោគជាលិខិតលាយលក្ខណ៍អក្សរឱ្យដូចទៅនឹងការខ្ចីដែលភ្ជាប់ការប្រាក់ដែរ ពីព្រោះការខ្ចីដែលមិនមានភ្ជាប់ការប្រាក់ និងមិនបានធ្វើលិខិតជាលាយលក្ខណ៍អក្សរទេ អ្នកឱ្យខ្ចីមានសិទ្ធិដកហូតនូវវត្ថុដែលជាកម្មវត្ថុនោះពេលណាក៏បាន ដូច្នេះការដកហូតនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ដំណើរការ ឬសកម្មភាពណាមួយដែលចាំបាច់ត្រូវមានកម្មវត្ថុនោះ ដើម្បីដំណើរការក្នុងការទាញយកផលប្រយោជន៍របស់អ្នកខ្ចី។ មួយវិញទៀតនៅក្នុងកិច្ចសន្យានោះត្រូវកំណត់ឱ្យច្បាស់នូវកម្មវត្ថុ និងអត្រាការប្រាក់ដែលបានព្រមព្រៀងគ្នា។ រីឯអត្រាការប្រាក់ត្រូវស្របទៅតាមច្បាប់ដែលបានកំណត់ជៀសវាងម្ចាស់បំណុលក្លាយទៅជាកូនបំណុលវិញ ដោយសារតែការយកការប្រាក់លើសពីច្បាប់កំណត់ ដែលយកការប្រាក់ដែលបង់លើសតាមផ្លូវច្បាប់ទៅកាត់ជាមួយប្រាក់ដើម។

ដូចនេះយើងយល់ឃើញថាក្រមរដ្ឋប្បវេណី កម្ពុជាគឺពិចារណាបញ្ញត្តិបន្ថែម ចំពោះលក្ខខណ្ឌតម្រូវដោយការធ្វើលិខិតជាលាយលក្ខណ៍អក្សរក្នុងករណីខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ និងកំណត់អំពីអត្រាការប្រាក់ឱ្យកាន់តែច្បាស់លាស់ជាងនេះទៅទៀត។ លើសពីនេះទៅទៀតរដ្ឋាភិបាលគួរលើកទឹកចិត្ត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីច្បាប់គតិយុត្តិនានាដល់ប្រជាពលរដ្ឋទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
- ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១
- ប្រកាសលេខៈ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត
- ក្រមនីតិវិធីរប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

## សៀវភៅ

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ៣ គន្លឹទី៥ ឆ្នាំ ២០១០
- មេរៀនស្តីពី "ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី" ភាគ១ មូលដ្ឋាននៃនីតិកិច្ចសន្យា ឆ្នាំ ២០១៥
- សៀវភៅណែនាំសិក្សា ច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន) ឆ្នាំ ២០០៨
- មេរៀនស្តីពី "ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី" ភាគ៣ ឆ្នាំ ២០១៧

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងមិនបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យា អាចមិនផ្តល់តាវកាលិករបស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

**មាត្រា ៥៧៧.–** ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថាប្រទានកម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ។

## ជំពូកទី ៤
## ការខ្ចីបរិភោគ

### ផ្នែកទី ១
### និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

**មាត្រា ៥៧៨.–** និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពី

អ្នកឱ្យខ្ចីនោះ ។

**មាត្រា ៥៧៩.–** ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចីតែប៉ុណ្ណោះ ។

**មាត្រា ៥៨០.–** ការដកកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ

ចំពោះកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ ភាគីនីមួយៗនៃកិច្ចសន្យា អាចដកកិច្ចសន្យានោះនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះផ្នែកនៃវត្ថុដែលជាកម្មវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ហើយ ។

**មាត្រា ៥៨១.–** ការរំលាយដោយការធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកខ្ចី

១-នៅក្នុងចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើង រហូតទៅដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន ។

២-បើអ្នកឱ្យខ្ចីបានរំលាយកិច្ចសន្យាដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងករណីដែលបានទទួលការប្រាក់កម្រៃជើងសារ ឬ តម្លៃថ្នូរផ្សេងទៀតជាមុន អ្នកឱ្យខ្ចីនោះត្រូវសងទៅឱ្យអ្នកខ្ចីវិញ ។

**មាត្រា ៥៨២.–** ឧបសន្យានៃការខ្ចីបរិភោគ

១-បុគ្គលដែលមានករណីយកិច្ចផ្តល់តាវកាលិកជាប្រាក់ ឬ វត្ថុជំនួសផ្សេងទៀតដោយមូលហេតុក្រៅអំពីការខ្ចីបរិភោគ ប្រសិនបើបានព្រមព្រៀងជាមួយម្ចាស់បំណុលថាយកវត្ថុនោះធ្វើជាកម្មវត្ថុនៃការខ្ចីបរិភោគ ការខ្ចីបរិភោគត្រូវបានបង្កើតឡើងដោយការព្រមព្រៀងនេះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រាតិភោគ

សម្រាប់កាតព្វកិច្ចចាស់ ត្រូវបានសន្មតថា ត្រូវក្លាយទៅជាប្រាតិភោគសម្រាប់កាតព្វកិច្ចថ្មី ។

## ផ្នែកទី ២
## ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

**មាត្រា ៥៨៣.–** សិទ្ធិលើបំណុលដែលជាការប្រាក់

១-ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុ ដែលបានខ្ចី មកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់ ។

២-នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ វត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហៅថា ប្រាក់ដើម ភាគដែលបានកំណត់ ដែលត្រូវបានដាក់ចូលទៅក្នុងចំនួនទឹកប្រាក់នៃប្រាក់ដើម ហៅថាអត្រាការប្រាក់ ។

៣-ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុល តាមការព្រមព្រៀងបាន ។ ប៉ុន្តែ ចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ ។

៤-នៅក្នុងការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ដោយមិនយោលតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចី ប្រសិនបើអ្នកខ្ចីបានសងដោយដឹងអំពីការអនុវត្តបញ្ញត្តិវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ ការសងមានអានុភាពត្រឹមកម្រិតដែលត្រូវបានសងនោះតែប៉ុណ្ណោះ ។

**មាត្រា ៥៨៤.–** អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា

១-អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬ ដោយការព្រមព្រៀងរបស់ភាគី ។

២-ក្នុងករណីដែលត្រូវបង់ការប្រាក់ តាមការព្រមព្រៀងរវាងភាគី ឬ បញ្ញត្តិច្បាប់ ប្រសិនបើភាគីពុំបានកំណត់អំពីអត្រាការប្រាក់ទេនោះ ត្រូវអនុលោមតាមអត្រាការប្រាក់ ដែលកំណត់ដោយច្បាប់ដែលបញ្ញត្តនៅក្នុងក្រមនេះ ឬ ច្បាប់ពិសេស ។

៣-អត្រាការប្រាក់ដែលកំណត់តាមការព្រមព្រៀងរបស់ភាគី ហើយដែលហួស អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ពុំមានអានុភាពឡើយ បើពុំបានកំណត់តាមលិខិត ជាលាយល័ក្ខណ៍អក្សរ យោងតាមរូបមន្តដែលកំណត់ក្នុងកថាខណ្ឌទី ៣ មាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) ខាងលើទេ ។

**មាត្រា ៥៨៥.–** ការកម្រិតការប្រាក់

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែល អាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ភាគីអាចកំណត់ការប្រាក់ ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ២ នៃមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយ ច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ខាងលើនេះ បាន តែមិនអាចកំណត់លើសពី អត្រាការប្រាក់ដែលត្រូវបានកម្រិតបានឡើយ ។

៣-ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបាន កម្រិត កិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈ រីឯ អ្នកខ្ចីមានករណីយកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ ដែលត្រូវបានកម្រិតនោះ តែប៉ុណ្ណោះ ។

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវ បានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុល ទៅលើប្រាក់ដើម ។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែក ដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចី ដោយភ្ជាប់ជាមួយ នូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែល

កំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសង រហូតដល់ថ្ងៃដែលបានសងនោះ ។

៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យា ខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែង ដូចជាករណីនៃ ការប្រគល់ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួន ទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួន ប្រាក់ដើម ។

៦-ចំពោះការអនុវត្តមាត្រានេះ ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួល ក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ទោះបីជាបានទទួលនៅក្នុងនាមជា ប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និង កម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុក ថាជាការប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើ កិច្ចសន្យា និង សោហ៊ុយនៃការសង ។

**មាត្រា ៥៨៦.–** ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយ ច្បាប់

១-បើគ្មានការកំណត់ពិសេសទេ ការប្រាក់ ត្រូវបង់នៅរៀងរាល់ពេលដែលពេល វេលា ១ (មួយ) ឆ្នាំ បានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ប្រសិនបើត្រូវសងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលពេលវេលា ១ (មួយ) ឆ្នាំ មិនទាន់បានកន្លងផុត ត្រូវបង់ការប្រាក់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ។

២-ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឱ្យខ្ចីអាចប្តូរការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

# ផ្នែកទី ៣
# ករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី

**មាត្រា ៥៨៧.-** ករណីយកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

១-អ្នកឱ្យខ្ចី មានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា ។

២-អ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬ ខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុ ដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ ។

**មាត្រា ៥៨៨.-** ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ នៅក្រោយពេលដែលអ្នកខ្ចីបានបរិភោគវត្ថុនោះរួចហើយ ពុំអាចទាមទារឱ្យប្រគល់វត្ថុជំនួសបានឡើយ ។

២-ប្រសិនបើអ្នកឱ្យខ្ចី ពុំអាចអនុវត្តកាតព្វកិច្ចដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ប្រសិនបើបានទទួលការប្រគល់ដោយពុំបានដឹងថាអ្នកឱ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឱ្យអ្នកឱ្យខ្ចីសងសំណងនៃការខូចខាតបាន ។

៤-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឱ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះ

ដោយពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

៥-លើកលែងតែករណីដែលបានទទួលការប្រគល់វត្ថុជំនួស ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៤ ខាងលើនេះ ប្រសិនបើអ្នកខ្ចីវត្ថុរបស់អ្នកដទៃ បានសងវត្ថុដែលត្រូវបានផ្តល់ ឬ តម្លៃនៃវត្ថុនោះ ឱ្យទៅកម្មសិទ្ធិករ អ្នកខ្ចីវត្ថុរបស់អ្នកដទៃនោះ ត្រូវរួចផុតពីករណីយកិច្ចសង ចំពោះអ្នកឱ្យខ្ចី ។

**មាត្រា ៥៨៩.–** សិទ្ធិរំលាយរបស់អ្នកឱ្យខ្ចីវត្ថុអ្នកដទៃ

អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយពុំដឹងថាជាវត្ថុរបស់អ្នកដទៃ ប្រសិនបើពុំអាចធ្វើឱ្យអ្នកខ្ចីបានលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួសទេ អាចរំលាយកិច្ចសន្យាបាន ។ ប៉ុន្តែ ប្រសិនបើអ្នកខ្ចីសុចរិត មានសិទ្ធិទាមទារសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៨៨ (ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ) ខាងលើនេះ លុះត្រាតែក្នុងករណីដែលបានសងសំណងនៃការខូចខាតនោះ ទើបអាចរំលាយកិច្ចសន្យាបាន ។

**មាត្រា ៥៩០.–** ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីនូវវត្ថុដែលមានវិការៈ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលបានទទួលការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះ អាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន ។

២-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកឱ្យខ្ចីបាន ដឹងអំពីវិការៈនោះហើយ តែពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

## ផ្នែកទី ៤
## ករណីយកិច្ចសងរបស់អ្នកខ្ចី

**មាត្រា ៥៩១.–** ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី

១-អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

២-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់ តាមបញ្ញត្តិពីមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ដល់មាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមនេះ ។

**មាត្រា ៥៩២.–** ការសងដោយយោលតាមតម្លៃ

១-ប្រសិនបើពុំអាចសងដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៩១ (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី) ខាងលើបានទេ អ្នកខ្ចីមានករណីយកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនឹងតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៅទីកន្លែង និង ថ្ងៃដែលត្រូវសង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើពុំបានកំណត់ថ្ងៃ ឬ ទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនឹងតម្លៃនោះ នៅថ្ងៃ និង ទីកន្លែងដែលបានធ្វើកិច្ចសន្យា ។

**មាត្រា ៥៩៣.–** ការប្រែប្រួលនៃតម្លៃរូបិយវត្ថុ ជាអាទិ៍

ទោះបីជាតម្លៃរូបិយវត្ថុ ឬ តម្លៃនៃវត្ថុ មានការប្រែប្រួល នៅមុនពេលសងក៏ដោយ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ដូចគ្នានឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់ ។

**មាត្រា ៥៩៤.–** ពេលវេលានៃការសង

១-ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យ

សងវត្ថុដែលជាកម្មវត្ថុបានឡើយ រហូតដល់ពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទនៃកិច្ចសន្យា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលហេតុដែលបានកំណត់នៅក្នុងមាត្រា ៣៣១ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ បានកើតឡើង ។

២-ប្រសិនបើភាគីមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសង ដោយកំណត់អំឡុងពេលសមរម្យបាន ។

៣-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ អាចសងនៅពេលណាក៏បាន ។

៤-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ អាចសងនៅមុនកាលបរិច្ឆេទសងដែលបានកំណត់ដោយកិច្ចសន្យាបាន ។ ប៉ុន្តែ នៅក្នុងករណីដែលធ្វើឱ្យមានការខូចខាតដល់អ្នកឱ្យខ្ចីដោយសារការសងនោះ អ្នកខ្ចីត្រូវសងសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

**មាត្រា ៥៩៥.-** ទីកន្លែងនៃការសង

ប្រសិនបើពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយកវត្ថុដែលជាកម្មវត្ថុនោះ ទៅសង នៅលំនៅឋានរបស់អ្នកឱ្យខ្ចី ។

## ជំពូកទី ៥
## ភតិសន្យា

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៩៦.-** និយមន័យនៃភតិសន្យា

១-ភតិសន្យា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផល ពីវត្ថុណាមួយ ដោយយកថ្លៃ ។

# ឯកសារគំរូ
# នៃកិច្ចសន្យាខ្ចីបរិភោគ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

✦✦✦

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ១២៨ កយធ. ប្រក/១១

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ៦ ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

### សម្រេច

ប្រការ ១.-

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

ប្រការ ២.-

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

បានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

**ប្រការ ៣.-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អង្គ.វង្សវឌ្ឍានា

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់
- ឯកសារ-កាលប្បវត្តិ។

កិច្ចសន្យាខ្ចីបរិភោគ

អ្នកតាក់តែងលិខិត..............................

លេខ:............................................ ក្រដាសពុម្ពលេខ:....................

ទីទុកឯកសារ

# <u>កិច្ចសន្យាខ្ចីបរិភោគ</u>

**១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា**

១. កូនបំណុលឈ្មោះ ..............................ភេទ..............ថ្ងៃខែឆ្នាំកំណើត:....................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:....................................ចុះថ្ងៃទី..................មានអាស័យដ្ឋានផ្ទះលេខ:... ផ្លូវលេខ:............ភូមិ.............សង្កាត់......................ខណ្ឌ...................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

អ្នកធានាដោយវត្ថុឈ្មោះ:....................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...................... សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:....................................ចុះថ្ងៃទី..................................និង ឈ្មោះ:...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...........................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:..............................ចុះថ្ងៃទី..............................មានលំនៅផ្ទះលេខ:........... ផ្លូវលេខ:..........ភូមិ.............សង្កាត់......................ខណ្ឌ.........................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

២. ម្ចាស់បំណុលឈ្មោះ:...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:....................សញ្ជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ:..............................ចុះថ្ងៃទី..................មានលំនៅផ្ទះលេខ:.........ភូមិ... សង្កាត់....................ខណ្ឌ......................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ខ") ។

**២. សិទ្ធលើបំណុលដែលត្រូវធានាដោយសិទ្ធិលើការបញ្ចាំ**

កូនបំណុលឈ្មោះ:..............................ភេទ...........ថ្ងៃខែឆ្នាំកំណើត:......................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:..............................ចុះថ្ងៃទី..........................និងលោកស្រី.................. ភេទ...........ថ្ងៃខែឆ្នាំកំណើត:.............................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.................. ចុះថ្ងៃទី..............................មានលំនៅផ្ទះលេខ:..........ផ្លូវលេខ:........សង្កាត់.............ខណ្ឌ............. រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

(១). ចំនួនប្រាក់ដើម..................................................

(២). អំឡុងពេល......................................................

(៣). ការប្រាក់.........................................................

(៤). ប្រាក់ធានាសង..................................................

(៥). ការសន្យាពិសេសកិច្ចសន្យានេះធ្វើឡើង សម្រាប់រយៈពេល..........ឆ្នាំ ប៉ុន្តែកិច្ចសន្យានេះអាចបញ្ចប់ ឬរំលាយមុនរយៈពេលនេះបាន ក្នុងករណីភាគីណាមួយបំពានចំណុចណាមួយ នៃបញ្ញត្តិស្តីពីការបំពានលើកាតព្វកិច្ចដូចមានចែងនៅក្នុង **"ឧបសម្ព័ន្ធ(ក) និង(ខ) នៃកិច្ចសន្យានេះ"** ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានចែងនៅក្នុងចំណុច២ខាងលើ ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាបង្កើតសិទ្ធិលើការបញ្ចាំ **ធម្មតា** លើសិទ្ធិនៃចំណុច៣ដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី២ ខាងលើ និងប្រគល់កម្មវត្ថុអោយទៅភាគី -ខ- ។

**៣. អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ**

(១). ទីតាំងដីស្ថិតនៅ: ដីឡូតិ៍លេខ:.......... ផ្លូវលេខ:.......... ភូមិ.......... សង្កាត់..........
ខណ្ឌ.................. រាជធានីភ្នំពេញ ។

(២). លេខក្បាលដី..............................

(៣). លេខប័ណ្ណ:..................................................

**៤. ខសន្យាផ្សេងៗទៀត**

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងគ្នាកំណត់អំពីលក្ខខណ្ឌផ្សេងៗទៀតដូចមានចែងនៅក្នុង**ឧបសម្ព័ន្ធ (ក)** នៃកិច្ចសន្យានេះ ។

ធ្វើជា........ច្បាប់ នៅថ្ងៃទី.......... ខែ............ ឆ្នាំ២០១៦

**បានអានសេចក្តីនៃលិខិតនេះអោយគូភាគីស្តាប់ចំពោះមុខសាក្សី**

ឈ្មោះ:.............................. អាយុ.......... ឆ្នាំ ទីលំនៅសង្កាត់.............. ខណ្ឌ........
រាជធានីភ្នំពេញ ។

ឈ្មោះ:.............................. អាយុ.......... ឆ្នាំ ទីលំនៅសង្កាត់.............. ខណ្ឌ........
រាជធានីភ្នំពេញ ។

| | | |
|---|---|---|
| **ស្នាមមេដៃ** | **ស្នាមមេដៃ** | **បានឃើញ និងបញ្ជាក់ថា** |
| ភាគី -ក- | ភាគី -ខ- | គូភាគីបានផ្តិតមេដៃចំពោះមុខមេធាវីជាសាក្សី |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Logo

# លិខិតផ្ទេរសិទ្ធិ

ខ្ញុំបាទ/នាងខ្ញុំ............................ភេទ............កើតនៅឆ្នាំ...............ជាបុគ្គលិកក្រុមហ៊ុន.......
....មានតួនាទីជា................កាតសម្គាល់លេខ...............កាន់អត្តសញ្ញាណបណ្ណលេខ...................។

**មូលហេតុ៖**.......................................................................................ចំនួន............ថ្ងៃ/ខែ
ចាប់ពីថ្ងៃទី..............ខែ...............ឆ្នាំ.............ដល់ថ្ងៃទី................ខែ................ឆ្នាំ...............។

## សម្រេច

ផ្ទេរសិទ្ធិទៅឲ្យឈ្មោះ.........................ភេទ...........កើតនៅឆ្នាំ.................ជាបុគ្គលិក
ក្រុមហ៊ុន......................................មានតួនាទីជា.........................កាតសម្គាល់លេខ..............
កាន់អត្តសញ្ញាណបណ្ណលេខ.......................................................។

**ភារកិច្ចទទួល៖**

១.

២.

៣.និងចុះហត្ថលេខាផ្សេងៗឲ្យស្របតាមគោលការណ៍ច្បាប់របស់ក្រុមហ៊ុន។

**សម្ភារៈទទួល៖**

១.

២.

លិខិតផ្ទេរសិទ្ធិនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.......ឆ្នាំ២០..........

| | |
|---|---|
| **អ្នកទទួលសិទ្ធិ** | **អ្នកផ្ទេរសិទ្ធិ** |
| ហត្ថលេខា ឬស្នាមមេដៃ | ហត្ថលេខា ឬស្នាមមេដៃ |
| ឈ្មោះ........................ | ឈ្មោះ........................ |

**ចំលងជូន៖**

-លោក.....

-សាមីខ្លួនដើម្បីអនុវត្តន៍

-ឯកសារកាលប្បវត្តិ

កិច្ចសន្យាខ្ចីបរិភោគ

អ្នកតាក់តែងលិខិត...........................

លេខ:.......................................... ក្រដាសពុម្ពលេខ:....................

ទីទុកឯកសារ

# **កិច្ចសន្យាខ្ចីបរិភោគ**

## ១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

១. កូនបំណុឈ្មោះ ..........................ភេទ..............ថ្ងៃខែឆ្នាំកំណើត:....................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:........................................ចុះថ្ងៃទី....................មានអាស័យដ្ឋានផ្ទះលេខ:... ផ្លូវលេខ:............ភូមិ..............សង្កាត់......................ខណ្ឌ...................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

អ្នកធានាដោយវត្ថុឈ្មោះ...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...................... សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.......................................ចុះថ្ងៃទី...............................និង ឈ្មោះ...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...........................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:...............................ចុះថ្ងៃទី.................................មានលំនៅផ្ទះលេខ:........... ផ្លូវលេខ:...........ភូមិ.............សង្កាត់.......................ខណ្ឌ.......................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

២. ម្ចាស់បំណុលឈ្មោះ.................................ភេទ.........ថ្ងៃខែឆ្នាំកំណើត:...................សញ្ជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ:.............................ចុះថ្ងៃទី....................មានលំនៅផ្ទះលេខ:.........ភូមិ... សង្កាត់...................ខណ្ឌ......................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ខ") ។

## ២. សិទ្ធលើបំណុលដែលត្រូវធានាដោយសិទ្ធិលើការបញ្ចាំ

កូនបំណុលឈ្មោះ..................................ភេទ...........ថ្ងៃខែឆ្នាំកំណើត:.......................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.............................ចុះថ្ងៃទី..........................និងលោកស្រី.................... ភេទ...........ថ្ងៃខែឆ្នាំកំណើត:.............................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:................... ចុះថ្ងៃទី.................................មានលំនៅផ្ទះលេខ:...........ផ្លូវលេខ:.........សង្កាត់..............ខណ្ឌ.............. រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

(១). ចំនួនប្រាក់ដើម.................................................

(២). អំឡុងពេល.........................................................

(៣). ការប្រាក់...........................................................

(៤). ប្រាក់ធានាសង.................................................

(៥). ការសន្យាពិសេសកិច្ចសន្យានេះធ្វើឡើង សម្រាប់រយៈពេល...........ឆ្នាំ ប៉ុន្តែកិច្ចសន្យានេះអាចបញ្ចប់ ឬរំលាយមុនរយៈពេលនេះបាន ក្នុងករណីភាគីណាមួយបំពានចំណុចណាមួយ នៃបញ្ញត្តិស្តីពីការបំពានលើកាតព្វកិច្ចដូចមានចែងនៅក្នុង "**ឧបសម្ព័ន្ធ(ក) និង(ខ) នៃកិច្ចសន្យានេះ**" ។

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានចែងនៅក្នុងចំណុច២ខាងលើ ។

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាបង្កើតសិទ្ធិលើការបញ្ចាំ **ធម្មតា** លើសិទ្ធិនៃចំណុច**៣**ដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី២ ខាងលើ និងប្រគល់កម្មវត្ថុអោយទៅភាគី "ខ" ។

**៣. អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ**

(១). ទីតាំងដីស្ថិតនៅ: ដីឡូត៍លេខ:…………ផ្លូវលេខ:…………ភូមិ……………សង្កាត់………………ខណ្ឌ………………… រាជធានីភ្នំពេញ ។

(២). លេខក្បាលដី………………………………

(៣). លេខប័ណ្ណ:………………………………………………………

**៤. ខសន្យាផ្សេងៗទៀត**

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាកំណត់អំពីលក្ខខណ្ឌផ្សេងៗទៀតដូចមានចែងនៅក្នុង**ឧបសម្ព័ន្ធ (ក)** នៃកិច្ចសន្យានេះ ។

ធ្វើជា………ច្បាប់ នៅថ្ងៃទី…………ខែ……………ឆ្នាំ២០១៦

**បានអានសេចក្តីនៃលិខិតនេះអោយគូភាគីស្តាប់ចំពោះមុខសាក្សី**

ឈ្មោះ………………………………………អាយុ……………ឆ្នាំ ទីលំនៅសង្កាត់………………ខណ្ឌ……… រាជធានីភ្នំពេញ ។

ឈ្មោះ………………………………………អាយុ……………ឆ្នាំ ទីលំនៅសង្កាត់………………ខណ្ឌ……… រាជធានីភ្នំពេញ ។

| **ស្នាមមេដៃ** | **ស្នាមមេដៃ** | **បានឃើញ និងបញ្ជាក់ថា** |
|---|---|---|
| ភាគី "ក" | ភាគី "ខ" | គូភាគីបានផ្តិមេដៃចំពោះមុខមេធាវីជាសាក្សី |

## ឧបសម្ព័ន្ធ(ក)

**១. ប្រាក់កម្ចី**

តាមរយៈនេះ ម្ចាស់បំណុលយល់ព្រមផ្តល់អោយកូនបំណុលនូវប្រាក់ចំនួន.......................................
ដែលមានដាក់ទ្រព្យធានា តទៅនេះហៅថា "**ប្រាក់កម្ចី**" ។ តាមរយៈភាគី "ក" នេះយល់ព្រមទទួលប្រាក់កម្ចីនេះ ។

**២. រយៈពេល និងការបញ្ចប់**

សិទ្ធិ និងកាតព្វកិច្ចកំណត់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគនេះ គឺជាសិទ្ធិ និងកាតព្វកិច្ច ដែលមិនអាចដកហូតវិញឡើយ រហូតដល់ពេលភាគី"ខ"ប្រកាសប្រាប់ដល់ភាគី"ក"ថា ភាគី"ក"បានបំពេញចប់សព្វគ្រប់ និងពេញលក្ខណៈរាល់លក្ខខណ្ឌនៃកិច្ចសន្យាខ្ចីបរិភោគ ។

**៣. លក្ខខណ្ឌមុនកាតព្វកិច្ច**

ភាគី "ខ" ពុំត្រូវបានតម្រូវអោយផ្តល់ប្រាក់កម្ចីអ្វីឡើយ រហូតទាល់តែភាគី "ខ" ទទួលនូវឯកសារដូចខាងក្រោម:

<u>៣.១</u>: កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនទ្រព្យដែលក្នុងនោះ ភាគី "ក" និងអ្នកធានាផ្តល់អចលនវត្ថុ ដែលមានតម្លៃស្មើ ឬលើសធ្វើជាវត្ថុបញ្ចាំសម្រាប់កម្ចីនេះ ។

<u>៣.២</u>: ប្រគល់ជូនភាគី "ខ" នូវវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ/ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុច្បាប់ដើម ។

<u>៣.៣</u>: ការចុះបញ្ជីនូវផលប្រយោជន៍និក្ខេបនៃភាគី "ខ" លើវត្ថុបញ្ចាំដែលផ្តល់អោយនេះបានត្រូវចុះបញ្ជីហើយសព្វគ្រប់ ។

**៤. ការបើកប្រាក់**

ការបើកប្រាក់កម្ចីត្រូវធ្វើឡើងនៅពេលដែលភាគី "ខ" បំពេញសព្វគ្រប់នូវលក្ខខណ្ឌកំណត់កាតព្វកិច្ចខាងលើ និងលក្ខខណ្ឌដទៃទៀតដែលត្រូវអនុវត្ត ។

**៥. ការសង**

<u>៥.១</u>: រាល់ប្រាក់កម្ចីរួមទាំងប្រាក់ត្រូវសងវិញគ្រប់ចំនួនយ៉ាងយូរ............................ចាប់ពីថ្ងៃអនុញ្ញាតអោយបើកប្រាក់យកទៅប្រើប្រាស់ "កាលបរិច្ឆេទសង................................" ។ រយៈពេលនៃប្រាក់កម្ចីនេះនឹងត្រូវបានផ្តល់អោយភាគី "ក" សម្រាប់រយៈពេល...........................បន្តទៀត ប៉ុន្តែលុះត្រាណាភាគី "ក" បានអនុវត្តខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យានេះ និងត្រូវបំពេញបែបបទ និងចុះកិច្ចព្រមព្រៀងដើម្បីកែប្រែរយៈពេលបញ្ចាំជាថ្មី "កាលបរិច្ឆេទពន្យាលពេលសងប្រាក់ចុងក្រោយ.............................." ។ រាល់សោហ៊ុយចំណាយលើការចុះបញ្ជីកែប្រែរយៈពេលបញ្ចាំនេះ គឺជាបន្ទុករបស់ភាគី "ក" ។

<u>៥.២</u>: ក្នុងករណីដែលភាគី "ក" ទូទាត់សងប្រាក់កម្ចីនេះមុនកាលកំណត់សងនោះ ភាគី "ក" ត្រូវបង់កម្រៃជាកពិន័យទៅអោយភាគី "ខ" ដូចខាងក្រោម:

**- ក្នុងអំឡុងពេលឆ្នាំទី១ ត្រូវបង់កម្រៃជាកពិន័យ ចំនួន៣% នៃទឹកប្រាក់ដែលបានបង់ ។**

**- ក្នុងអំឡុងពេលឆ្នាំទី២ ត្រូវបង់កម្រៃជាកពិន័យ ចំនួន២% នៃទឹកប្រាក់ដែលបានបង់ ។**

**- ក្នុងអំឡុងពេលឆ្នាំទី៣ ត្រូវបង់កម្រៃជាកពិន័យ ចំនួន១% នៃទឹកប្រាក់ដែលបានបង់ ។**

**៦. <u>កម្រៃសេវា</u>**

ភាគី "ក" យល់ព្រមបង់ប្រាក់កម្រៃសេវាទៅអោយភាគី "ខ" ចំនួន១%(សម្រាប់រយៈពេល១០ឆ្នាំ) នៃទឹកប្រាក់កម្ចី និងត្រូវបង់នៅពេលបើកប្រាក់កម្ចីលើកដំបូង ព្រមទាំងសោហ៊ុយសេវាលើនីតិវិធីផ្លូវច្បាប់ រដ្ឋបាល ជាមួយស្ថាប័នផ្សេងៗ រហូតដល់ការទប់ស្កាត់នៅការិយាល័យសុរិយោដីបានបំពេញចប់សព្វគ្រប់ ។

**៧. <u>ការប្រាក់</u>**

ប្រាក់កម្ចីនេះមានអាត្រាការប្រាក់ប្រចាំឆ្នាំចំនួន..............។ ការប្រាក់ត្រូវគិតប្រចាំថ្ងៃ ដោយចាប់ផ្ដើមគិតនៅថ្ងៃបើកប្រាក់យកទៅប្រើប្រាស់ ។ ការប្រាក់ត្រូវបង់ប្រចាំខែ ដោយគិតចាប់ពីថ្ងៃបើកប្រាក់កម្ចី **"ថ្ងៃកំណត់បង់"** ។ ការប្រាក់ត្រូវបង់ដោយភាគី "ក" អោយភាគី "ខ" នៅថ្ងៃទី...........រៀងរាល់ខែ ដោយគិតចាប់ពីថ្ងៃទី................ ដល់ថ្ងៃទី.................(គឺរាប់ចំនួនថ្ងៃជាក់ស្ដែង ចាប់ពីថ្ងៃបង់ការប្រាក់មកទល់នឹងថ្ងៃដែលត្រូវបង់ការប្រាក់នៅខែបន្ទាប់) ។ ប្រសិនបើថ្ងៃកំណត់បង់ការប្រាក់ប៉ះចំថ្ងៃឈប់សម្រាកចុងសប្ដាហ៍ ការប្រាក់ត្រូវបង់នៅថ្ងៃធ្វើការទីមួយ ។

**៨. <u>ពិន័យលើការយឺតយ៉ាវ</u>**

ក្នុងករណីភាគី "ខ" មិនបានទទួលប្រាក់គ្រប់ចំនួនទាំងអស់ដែលត្រូវសងអនុលោមតាមកិច្ចសន្យានេះនៅកាលបរិច្ឆេទកំណត់សងនោះ ភាគី "ក" ត្រូវបង់ជូនភាគី "ខ" តាមការទាមទារនូវការប្រាក់លើចំនួននោះ ចាប់គិតពី និងរួមបញ្ចូលទាំងកាលបរិច្ឆេទកំណត់សងរហូតដល់ថ្ងៃដែលភាគី "ខ" ទទួលបានចំនួនទឹកប្រាក់នោះដោយគិតអត្រា................................ក្នុង១ឆ្នាំ ការប្រាក់នេះនឹងត្រូវគិតផ្គួបប្រចាំថ្ងៃ ។

**៩. <u>ការទូទាត់</u>**

ភាគី "ក" ត្រូវទូទាត់សងប្រាក់កម្ចី និងការប្រាក់ជាបន្តបន្ទាប់ដូចតទៅ:

<u>៩.១</u>: ប្រាក់កម្ចីត្រូវទូទាត់សងដូចខាងក្រោមៈ

៩.១.១: ទូទាត់សងរំលោះប្រាក់ដើម និងការប្រាក់កម្ចីរៀងរាល់ខែដោយយោងទៅតាមប្រការ៧ និងទាំងប្រាក់ដើម ទាំងការប្រាក់ត្រូវតែទូទាត់គ្រប់ចំនួននៅថ្ងៃសងវិញ (ភ្ជាប់តារាងទូទាត់សងប្រាក់កម្ចី) ។

**១០. <u>ការធានា</u>**

<u>១០.១</u>: ដើម្បីធានាចំពោះការបំពេញកាតព្វកិច្ចរបស់ភាគី "ក" ក្រោមកិច្ចសន្យាខ្ចីបរិភោគនេះ ភាគី "ក" និងអ្នកធានាតាមរយៈនេះសូមផ្ដល់វត្ថុបញ្ចាំជូនភាគី "ខ" និងផលប្រយោជន៍ប្រាតិភោគលើទ្រព្យសម្បត្តិទាំងនេះ(រាល់អចលនវត្ថុដីធ្លី អាគារ ចលនទ្រព្យតាំងភ្ជាប់) ដែលកាន់កាប់ដោយភាគី "ក" និងអ្នកធានាក្រោមវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ/ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុៈ

- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ..............................ចុះថ្ងៃទី..........................ចេញដោយ...............................ស្ថិតនៅ.........................(កម្មសិទ្ធិរបស់លោក..........................និងលោកស្រី.........................) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ "ក" ។

ផលប្រយោជន៍ក្នុងទ្រព្យធានាផ្តល់ក្នុងទីនេះ ត្រូវអនុលោមទៅតាមខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនទ្រព្យ និងកិច្ចសន្យាផ្សេងៗដែលជាប់ពាក់ព័ន្ធដែលត្រូវអនុវត្តតាមកាលបរិច្ឆេទដូចគ្នានឹងកិច្ចសន្យាខ្ចីបរិភោគនេះដែរ ។

អនុលោមទៅតាមខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនទ្រព្យ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុច្បាប់ដើមដែលបានបញ្ជាក់ខាងលើត្រូវប្រគល់ដោយភាគី "ក" និងអ្នកធានាជូនភាគី "ខ" នៅថ្ងៃចុះហត្ថលេខាអនុវត្តកិច្ចសន្យាខ្ចីបរិភោគនេះ ហើយនឹងត្រូវកាន់កាប់ដោយភាគី "ខ" រហូតដល់ភាគី "ក" សងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនទាំងអស់ដែលត្រូវបង់ជូនភាគី "ខ" ។

**១០.២**: លិខិតធានារបស់តតីយជនបានផ្តល់អោយដោយលោក...................................ថ្ងៃខែឆ្នាំកំណើត:.....សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.................................ចុះថ្ងៃទី.........................មានលំនៅផ្ទះលេខ:............ភូមិ..............សង្កាត់.........................ខណ្ឌ.........................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ អ្នកធានាមានកាតព្វកិច្ចទទួលខុសត្រូវទាំងស្រុងក្នុងការសងប្រាក់កម្ចីទាំងអស់ត្រឡប់មកវិញដូចអ្នកខ្ចីប្រាក់ដែរ ។

**១០.៣**: ទ្រព្យសម្បត្តិរបស់ភាគី "ក" ទាំងអស់ដែលមានបច្ចុប្បន្ន និងទ្រព្យសម្បត្តិដែលភាគី "ក" នឹងទទួលបាននៅពេលអនាគត់ ។

## ១១. ការប្រកាស និងការធានា

**កូនបំណុល** សូមធ្វើការប្រកាស និងធានាជូនភាគី "ខ" ថា:

**១១.១**: ភាគី "ក" ជាម្ចាស់អចលនវត្ថុស្របច្បាប់ និងបានចុះបញ្ជីជាម្ចាស់ទ្រព្យតែម្នាក់គត់ និងគ្មានការដាក់បញ្ចាំ ឬផលប្រយោជន៍ប្រាតិភោគដ៏ទៃទៀតលើអចលនវត្ថុនេះឡើយ(ក្រៅពីការដាក់បញ្ចាំ ឬផលប្រយោជន៍ប្រាតិភោគ លើអចលនវត្ថុធ្វើឡើងរវាងគូភាគី) ។

**១១.២**: ការចុះហត្ថលេខាប្រតិបត្តិ ការប្រគល់ និងការអនុវត្តកិច្ចសន្យាមិនបំពានលើបទប្បញ្ញត្តិច្បាប់ បទបញ្ជាក្រឹត្យ លិខិតបញ្ជា លិខិតអនុញ្ញាតផ្សេងៗទៀតដែលកំពុងមាន និងភ្ជាប់កាតព្វកិច្ចរបស់ភាគី "ក" ទ្រព្យសម្បត្តិរបស់ភាគី "ក"ឡើយ ។

**១១.៣**: គ្មានបណ្តឹង វិវាទមជ្ឈត្តវិនិច្ឆ័យ បណ្តឹងរដ្ឋបាលដែលកំពុងតែមានព្យួរទុកដែលអាចបង្កផលប៉ះពាល់មិនល្អដល់អាជីវកម្ម ស្ថានភាពហិរញ្ញវត្ថុរបស់ភាគី "ក" លទ្ធភាពរបស់ភាគី "ក" ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចសន្យានេះ ។

**១១.៤**: រាល់ការអនុញ្ញាត និងការឯកភាពរបស់រដ្ឋាភិបាល ការអនុញ្ញាត និងការឯកភាពផ្សេងៗទៀតសម្រាប់ចុះហត្ថលេខាប្រតិបត្តិ និងអនុវត្តកិច្ចសន្យានេះត្រូវបានទទួលរួចហើយ ហើយការអនុញ្ញា និងការឯកភាពទាំងនោះនៅមានប្រសិទ្ធិភាពពេញលេញ ។

**១១.៥**: រាល់ពត៌មានទាំងឡាយដែលផ្តល់ជូនភាគី "ខ" ទាក់ទងនឹងកិច្ចសន្យានេះ ជាពត៌មានពិតពេញលក្ខណ:ត្រឹមត្រូវ និងច្បាស់លាស់គ្រប់ទិដ្ឋភាពទាំងអស់ ។

១២. **<u>បញ្ញត្តិស្តីអំពីការបំពានលើកាតព្វកិច្ច</u>**: ព្រឹត្តការណ៍ជាបន្តបន្ទាប់នេះត្រូវបានចាត់ទុកថាជាការបំពានលើកាតព្វកិច្ច:

**<u>១២.១</u>**: ភាគី "ក" ខកខានមិនបង់ប្រាក់ជំពាក់ដែលមានចែងក្រោមកិច្ចសន្យាខ្ចីបរិភោគនេះនៅកាលបរិច្ឆេទដល់កំណត់ត្រូវសង ។

**<u>១២.២</u>**: ភាគី "ក" មិនបានគោរពតាម ឬប្រតិបត្តិតាមកាតព្វកិច្ច ការសន្យា ការព្រមព្រៀងណាមួយក្រោមកិច្ចសន្យាខ្ចីបរិភោគនេះ និងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនទ្រព្យ និងឯកសារពាក់ព័ន្ធ ។

**<u>១២.៣</u>**: ការសន្យា កាតព្វកិច្ច ការប្រកាស ការធានាណាមួយដែលធ្វើឡើងក្នុងទីនេះ ឬក្នុងឯកសារណាមួយដែលបានប្រគល់រួចហើយ ដែលមានជាប់ពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីបរិភោគនេះមានលក្ខណៈមិនត្រឹមត្រូវ បន្លំ រំលោភបំពានលើករណីណាមួយ ។

**<u>១២.៤</u>**: ភាគី "ក" ខកខានមិនបានបំពេញកាតព្វកិច្ចដែលបានសន្យា និងចែងក្នុងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនទ្រព្យ និងឯកសារពាក់ព័ន្ធ ។

**<u>១២.៥</u>**: ភាគី"ក"ចាប់ផ្តើមក្ស័យធនមិនអាចសងបំណុលបាន ផ្ទេរ បោះបង់ចោលនូវទ្រព្យសកម្មសំខាន់ៗរបស់ខ្លួន ។

**<u>១២.៦</u>**: នៅពេលកើតមានហេតុការណ៍ លក្ខខណ្ឌ ឬព្រឹត្តការណ៍មួយដែលអាចប្រែក្លាយព្រឹត្តការណ៍នៃការបំពានលើកាតព្វកិច្ចនៃប្រាក់កម្ចីដោយភាគី "ក" ។

**<u>១២.៧</u>**: ភាគី "ក" ខកខានមិនបានបង់ប្រាក់ប្រចាំខែជូនភាគី "ក" តាមកំណត់រយៈពេលរៀងរាល់ខែ ។

១៣. **<u>ដំណោះស្រាយ</u>**

នៅពេលកើតមានព្រឹត្តការណ៍នៃការបំពានកាតព្វកិច្ចនោះ តាមសិទ្ធិជ្រើសរើសរបស់ខ្លួន ភាគី "ខ" អាចប្រកាសអំពីការបំពានរបស់ភាគី "ក" លើកាតព្វកិច្ចក្រោមកិច្ចសន្យាខ្ចីបរិភោគនេះ ហើយភាគី "ខ" អាចប្រើដំណោះស្រាយដែលមានចែងក្នុងច្បាប់ជាធរមាន និងអាចជ្រើសរើសដូចតទៅ:

**<u>១៣.១</u>**: បញ្ឈប់ជាបណ្តោះអាសន្ន ឬលុបចោលចំនួនទឹកប្រាក់កម្ចីដែលមិនទាន់ដកយកក្នុងមួយផ្នែក ឬទាំងមូលដែលស្ថិតនៅក្រោមកិច្ចសន្យាខ្ចីបរិភោគនេះ ។

**<u>១៣.២</u>**: ស្នើសុំភាគី "ក" អោយធ្វើការទូទាត់ជាបន្ទាន់នូវប្រាក់កម្ចីទាំងអស់ ឬមួយផ្នែកព្រមទាំងទូទាត់សងការប្រាក់ត្រូតក្រោមកិច្ចសន្យាខ្ចីបរិភោគនេះគិតចាប់ពីថ្ងៃបំពានរហូតដល់ពេលដែលភាគី "ខ" បានទទួលការបង់ប្រាក់ ។

**<u>១៣.៣</u>**: ទាមទារសំណង់ចំពោះការខាត់បង់ ការខូចខាត សោហ៊ុយចំណាយដែលភាគី "ខ" បានចាយដោយសារតែការបំពានលើកាតព្វកិច្ចរបស់ភាគី "ក" ។

**<u>១៣.៤</u>**: នៅពេលដែលភាគី "ក" បានបំពានលើកិច្ចសន្យាខ្ចីបរិភោគនេះ ភាគី "ខ" អាចជូនដំណឹងពីការបំពាននេះ ។ តាមរយៈការជូនដំណឹងអំពីការខកខាននោះ ភាគី "ក" ត្រូវធ្វើការផ្ទេរនូវផលប្រយោជន៍នៃទ្រព្យសម្បត្តិ ទៅអោយភាគី "ខ" ឬទៅអោយតតីយជនសមស្របណាម្នាក់ដែលភាគី "ខ" បានជ្រើសរើស ។ យោងតាមការអនុវត្តន៍ និងវិសាលភាពនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា ភាគី "ខ" អាចធ្វើការផ្ទេរ ឬរឹមអូសយកទ្រព្យសម្បត្តិនោះ ឬធ្វើពាក្យបណ្តឹងទៅតុលាការដើម្បីស្នើសុំសាលក្រម ដើម្បីលក់ទ្រព្យសម្បត្តិដាក់បញ្ចាំក្នុងការទូទាត់សងប្រាក់ដើម ការប្រាក់ ការប្រាក់ពិន័យ និងចំណាយផ្សេងៗដោយពុំចាំបាច់មានការយល់ព្រមជា

មុនពីភាគី "ក" និងឬអ្នកជានានាឡើយ ។ តាមរយៈការជូនដំណឹងអំពីការខកខានក្នុងការបំពេញកាតព្វកិច្ច ភាគី "ក" ត្រូវធ្វើការផ្ទេរភ្លាមនូវផលប្រយោជន៍ជាកម្មសិទ្ធិដែលមាននៅក្នុងទ្រព្យសម្បត្តិ ទៅអោយភាគី "ខ" ឬតតីយជនណាម្នាក់ ដែលភាគី "ខ" បានជ្រើសរើស ហើយត្រូវចុះហត្ថលេខាលើឯកសារទាំងអស់ ដើម្បីបញ្ចប់ការផ្ទេរ ឬការចុះបញ្ជី ដោយយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**ភាគី "ក" និង/ឬអ្នកស្នង**របស់ភាគី "ក" អ្នកទទួលសិទ្ធិ ទាយាទ ឬតណទាយក មិនមានសិទ្ធិប្តឹងទាមទារយកទ្រព្យសម្បត្តិនោះបានទេ ក្រោយពីភាគី "ខ" អនុវត្តនូវដំណោះស្រាយ ដូចបានយល់ព្រមខាងលើ ។

<u>១៣.៥</u>: អនុវត្តន៍សិទ្ធិដែលមានលើទ្រព្យធានានោះតាមការអនុញ្ញាតក្រោមកិច្ចសន្យាប្រាតិភោគ និងឯកសារច្បាប់ដ៏ទៃទៀតទាំងអស់ដែលទាក់ទង ។

## ១៤. <u>សិទ្ធិក្នុងការដកប្រាក់</u>

ភាគី "ក" បានផ្តល់សិទ្ធិគ្រប់យ៉ាងអោយទៅភាគី "ខ" ក្នុងការឆែក ឬដកប្រាក់ពីគណនីធនាគាររបស់ភាគី "ក" ក្នុងគោលបំណងបំពេញនូវភាពចាំបាច់ ឬត្រូវបង់ការប្រាក់ ឬប្រាក់ដើម ដែលភាគី "ក" ត្រូវបង់អោយភាគី "ខ" ។

## ១៥. <u>ការផ្ទេរសិទ្ធិ</u>

ភាគី "ខ" អាចប្រគល់ ឬផ្ទេរសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទាំងអស់ ឬមួយផ្នែកក្រោមកិច្ចសន្យាខ្ចីបរិភោគនេះ ដោយមិនបាច់មានការយល់ព្រមពីភាគី "ក" ។ ភាគី "ក" ត្រូវចាត់វិធានការចាំបាច់ ឬវិធានការតាមការតម្រូវដែលទាក់ទងនឹងការប្រគល់ ការផ្ទេរនេះដោយយោងទៅតាមការស្នើរបស់ភាគី "ខ" ។ ភាគី "ក" មិនអាចប្រគល់សិទ្ធិ ឬផ្ទេរកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចសន្យាខ្ចីបរិភោគនេះបានឡើយ បើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភាគី "ខ" ។

## ១៦. <u>ការដោះស្រាយវិវាទ</u>

រាល់វិវាទដែលពាក់ព័ន្ធនឹងការបកស្រាយ ការអនុវត្តន៍កិច្ចសន្យាខ្ចីបរិភោគនេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចចារ ដោយផ្ទាល់រវាងភាគី "ខ" និងភាគី "ក" ឡើយភាគី "ខ"នឹងមានសិទ្ធិផ្តាច់មុខក្នុងការជ្រើសរើសវិធីដោះស្រាយតាមរយៈតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

## ១៧. <u>ប្រសិទ្ធិភាពចំណងកាតព្វកិច្ច</u>

បញ្ញត្តិនៃកិច្ចសន្យាខ្ចីបរិភោគនេះ មានចំណងកាតព្វកិច្ចលើទាយាទអ្នកតំណាងផ្ទាល់ខ្លួន អ្នកស្នងបន្ត និងអ្នកទទួលសិទ្ធិរបស់ភាគី "ខ" និងភាគី "ក" ភាគីទាំងពីរ ។

## ១៨. <u>ភាសាកំណត់</u>

កិច្ចសន្យាខ្ចីបរិភោគនេះធ្វើឡើងជាភាសាខ្មែរ និងភាសា............មានតម្លៃស្មើគ្នា ។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ភាសា ...............ត្រូវមានឧត្តមភាព ។

## ១៩. <u>ច្បាប់គ្រប់គ្រង</u>

កិច្ចសន្យាខ្ចីបរិភោគនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**<u>ឧបសម្ព័ន្ធ "ខ"</u>**

១. កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំរវាងលោក.................................. និងលោក...................

និងលោក.................................ចុះថ្ងៃទី......................................

២. ពាក្យសុំខ្ចីប្រាក់ ចុះថ្ងៃទី......................................

៣. លិខិតធានាបំណុលដោយលោក.................................ចុះថ្ងៃទី...........................

***គូភាគីបានអាន និងបានយល់ទាំងស្រុងនូវរាល់ខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យាខ្ចីបរិភោគ ក៏ដូចជាខ្លឹមសារ និងលក្ខខណ្ឌនៃឧបសម្ព័ន្ធទាំងនេះទើបសុខចិត្តធ្វើការចុះហត្ថលេខា និងផ្តិតមេដៃដោយស្ម័គ្រចិត្តរៀងៗខ្លួន ។***

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

**យើងខ្ញុំ រវាង**

ឈ្មោះ ........ កើតឆ្នាំ ........ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........ ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ........ និងឈ្មោះ ........ កើតឆ្នាំ ........ មានទីលំនៅបច្ចុប្បន្ននៅភូមិ ........ សង្កាត់ ........ ខណ្ឌ ........ រាជធានីភ្នំពេញ **ជាភាគីអ្នកខ្ចីប្រាក់** ហៅកាត់ថា **ភាគី "ក"** ។

**និង**

ឈ្មោះ ........ ភេទ ........ កើតឆ្នាំ ........ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........ ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ........ និងប្រពន្ធឈ្មោះ ........ កើតឆ្នាំ ........ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........ ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ........ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ........ ផ្លូវលេខ ........ ភូមិ ........ សង្កាត់ ........ ខណ្ឌ ........ រាជធានីភ្នំពេញ **ជាភាគីអ្នកឲ្យខ្ចីប្រាក់** ហៅកាត់ថា **ភាគី "ខ"** ។

**ភាគី "ក"** និង **ភាគី "ខ"** បានព្រមព្រៀងគ្នាក្នុងការចុះកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការខាងក្រោមនេះ :

**ប្រការ ១ :** **ភាគី "ក"** បានទទួលប្រាក់ខ្ចីបរិភោគចំនួន USD........ ជាអក្សរ (........) នៅថ្ងៃទី ........ ខែ ........ ឆ្នាំ ........ ពី**ភាគី "ក"** ដោយ**ភាគី "ក"** សន្យាបង់ការប្រាក់ឲ្យ**ភាគី "ខ"** ។

**ប្រការ ២ :** **ភាគី "ក"** ឯកភាពបង់ការប្រាក់នូវអត្រាការប្រាក់ ........% (........) ស្មើនឹងចំនួន USD........ ជាអក្សរ (........) ក្នុងមួយខែ១ ឲ្យទៅ**ភាគី "ខ"** គិតចាប់ពីថ្ងៃទី ........ ខែ ........ ឆ្នាំ ........ លើចំនួនទឹកប្រាក់ខ្ចីបរិភោគខាងលើ ដោយត្រូវបង់នៅចន្លោះថ្ងៃទី ........ ដល់ថ្ងៃទី ........ នៃខែនីមួយ១ នៅអាស័យដ្ឋានផ្ទះលេខ ........ ផ្លូវលេខ ........ ភូមិទី ........ សង្កាត់ ........ ខណ្ឌ ........ រាជធានីភ្នំពេញ ។

**ប្រការ ៣ :** ក្នុងករណី**ភាគី "ក"** មិនបានយកការប្រាក់មកបង់ឲ្យ**ភាគី "ខ"** តាមការកំណត់ដូចមានចែងក្នុងប្រការ ៣ ខាងលើទេ គឺ**ភាគី "ក"** ឯកភាពបង់ប្រាក់ពិន័យនូវអត្រា ៥% លើចំនួនការប្រាក់ដែល**ភាគី "ក"** ខកខានមិនបានបង់ឲ្យ**ភាគី "ខ"** តាមខែនីមួយ១ ។

**ប្រការ ៤ :** អំឡុងពេលនៃកិច្ចសន្យាខ្ចីបរិភោគនេះមានរយៈពេលចំនួន ១៨ខែ (ដប់ប្រាំបីខែ) ដោយគិតចាប់គិតពីថ្ងៃទី ០៩ ខែ ........ ឆ្នាំ ........ តទៅ ដោយ**ភាគី "ក"** សន្យាយកប្រាក់មកទូទាត់សងបំណុលឲ្យ**ភាគី "ខ"** វិញគ្រប់ចំនួន ទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ដោយមិនឲ្យហួសថ្ងៃទី ........ ខែ ........ ឆ្នាំ ........ ឡើយ ។

**ប្រការ ៥ :** ដើម្បីធានាអនុវត្តគ្រប់កាតព្វកិច្ចទាំងអស់របស់**ភាគី "ក"** ដូចមានចែងក្នុងកិច្ចសន្យានេះ **ភាគី "ក"** ឯកភាពដាក់សិទ្ធិកាន់កាប់ ........ មានទទឹង ........ ម៉ែត្រ និងបណ្ដោយ ........ ម៉ែត្រ ព្រមទាំង........ ម៉ែត្រ និងបណ្ដោយ ........ មានព្រំប្រទល់ខាងជើងទល់នឹង ........ ខាងត្បូងទល់នឹង ........ ខាងកើតទល់នឹង ........ និងខាងលិចទល់នឹង ........ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះលេខ

..................ចុះថ្ងៃទី ..............ខែ ..............ឆ្នាំ .............. របស់សាលាខណ្ឌពោធិ៍សែនជ័យ មានទីតាំងស្ថិតភូមិ ................. សង្កាត់ ............. ខណ្ឌ ................រាជធានីភ្នំពេញ ឱ្យទៅ**ភាគី "ខ"** ។

**ប្រការ ៦ :** ក្នុងករណី**ភាគី "ក"** មិនទាន់បានទូទាត់សងបំណុលផ្តាច់ទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឱ្យ**ភាគី "ខ"** គ្រប់ចំនួនទេ គឺ**ភាគី "ក"** មិនអាចស្នើសុំដកយកឯកសារដែលពាក់ព័ន្ធនឹងអចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ ពី**ភាគី "ខ"** បានឡើយ ។

**ប្រការ ៧ :** **ភាគី "ក"** ឯកភាពឱ្យ**ភាគី "ខ"** ចាត់វិធានការណ៍ដូចមានចែងក្នុងប្រការ ៨ ខាងក្រោម ក្នុងករណីល័ក្ខខ័ណ្ឌណាមួយកើតឡើង ដូចខាងក្រោម :

១. ការផុតអំឡុងពេលកំណត់ នៅថ្ងៃទី .......... ខែ .......... ឆ្នាំ .............. **ភាគី "ក"** មិនមានប្រាក់គ្រប់ចំនួនទូទាត់ សងបំណុលផ្តាច់ឱ្យទៅ**ភាគី "ខ"** ។

២. **ភាគី "ក"** ខកខានមិនបានបង់ការប្រាក់រយៈពេល .........ខែ ជាអក្សរ ( ........................... ) ឱ្យ**ភាគី "ខ"** ។

៣. **ភាគី "ក"** បំពានកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យានេះ ។

**ប្រការ ៨ :** ក្នុងករណីល័ក្ខខ័ណ្ឌណាមួយដូចមានចែងក្នុងប្រការ ៧ ខាងលើ កើតឡើង គឺ**ភាគី "ក"** ឯកភាពឱ្យ**ភាគី "ខ"** ចាត់វិធានការណ៍ចំពោះអចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ ដើម្បីទូទាត់សងបំណុលឱ្យ**ភាគី "ខ"** គ្រប់ចំនួនទាំងប្រាក់ដើមកម្ចី ការប្រាក់ និងប្រាក់ពិន័យ តាមជំរើសណាមួយដូចខាងក្រោម :

១. ដាក់លក់ទ្រព្យបញ្ចាំ ដោយ**ភាគី "ខ"** ជាអ្នកកំណត់តម្លៃលក់ និងជាអ្នកសម្របសម្រួលការលក់-ទិញជាមួយភាគីទិញ តាមតម្លៃទីផ្សារជាក់ស្តែង ។

២. **ភាគី "ក"** ឯកភាពប្រគល់អចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ ឱ្យ**ភាគី "ខ"** គ្រប់គ្រង កាន់កាប់ និងចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិ ដើម្បីទូទាត់ប្រាក់បំណុល ដែល**ភាគី "ក"** ជំពាក់**ភាគី "ខ"** ក្នុងករណីប្រាក់បំណុលមានចំនួនស្មើនឹងតម្លៃអចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ (តម្លៃតាមទីផ្សារជាក់ស្តែង) ។

**ប្រការ ៩ :** **ភាគី "ក"** ឯកភាពទទួលស្គាល់ថា អចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ មានតម្លៃសរុប USD............ ជាអក្សរ (...................ដុល្លារសហរដ្ឋអាមេរិក) ជាតម្លៃមូលដ្ឋានសំរាប់**ភាគី "ខ"** ប្រើប្រាស់វិធានការណ៍ដូចមានចែងក្នុងប្រការ ៨ ខាងលើ ។

**ប្រការ ១០ :** **ភាគី "ក"** ជាអ្នកទទួលខុសត្រូវចេញចំណាយលើដំណើរការនីតិវិធីលក់តាមផ្លូវតុលាការ (ប្រសិនបើមាន) និង**ភាគី "ក"** ជាអ្នកទទួលខុសត្រូវលើការចេញចំណាយទៅលើដំណើរការនៃការកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដូចមានចែងក្នុងប្រការ ៥ ខាងលើ ឱ្យទៅអ្នកទិញ ។

**ប្រការ ១១ :** ក្នុងករណី**ភាគី "ក"** មិនអនុវត្តឱ្យបានពេញលេញ និងត្រឹមត្រូវតាមកិច្ចសន្យានេះ គឺ **ភាគី "ក"** ឯកភាពឱ្យ**ភាគី "ខ"** ប្តឹងទៅតុលាការ ដើម្បីរឹបអូសទ្រព្យបញ្ចាំលក់ឡៃឡុងដើម្បីកាត់យកមកទូទាត់ប្រាក់បំណុលជំពាក់**ភាគី "ខ"** ឱ្យបានគ្រប់ចំនួន ដោយបូកទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ។ ក្នុងករណី**ភាគី "ក"** សងបំណុលឱ្យ**ភាគី "ខ"** មិនគ្រប់ចំនួន ទេ គឺ**ភាគី "ក"** ឯកភាពសងបំណុលឱ្យទៅ**ភាគី "ខ"** បន្តទៅទៀតរហូតដល់គ្រប់ចំនួន ។

**ប្រការ ១២ :** **ភាគី "ក"** និង**ភាគី "ខ"** ទទួលស្គាល់រួមគ្នាថា ការព្រមព្រៀងតាមខ្លឹមសារនៃកិច្ចសន្យានេះធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការភាន់ច្រឡំ គ្មានការឆបោក គ្មានការគម្រាមកំហែង គ្មានការកេងយកចំណេញហួសហេតុ គ្មានការរំលោភលើស្ថានភាពរបស់ភាគីណាមួយឡើយ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាខ្ចីចងការប្រាក់

កិច្ចសន្យានេះធ្វើឡើង **រវាង**:

១-ឈ្មោះ.................................ភេទ............អាយុ............ឆ្នាំ ជនជាតិ............សញ្ជាតិ............ មានលំនៅផ្ទះលេខ: .........ភូមិ..........................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ.......................... ខេត្ត/ក្រុង..........................ជាអ្នកអោយប្រាក់ខ្ចីតទៅហៅកាត់ថា **ភាគី"ក"**។

**ជាមួយនឹង**

១-ឈ្មោះ.................................ភេទ............អាយុ............ឆ្នាំ ជនជាតិ............សញ្ជាតិ............ មានលំនៅផ្ទះលេខ: .........ភូមិ..........................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ.......................... ខេត្ត/ក្រុង..........................ជាអ្នកខ្ចីចងការប្រាក់តទៅហៅកាត់ថា **ភាគី"ខ"**។

***ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌដូចខាងក្រោម៖***

**ប្រការ១** : ភាគី"ក"យល់ព្រមអោយប្រាក់ចំនួន........................................................................ ទៅភាគី"ខ" ខ្ចីដោយគិតការប្រាក់ក្នុងអាត្រា......................................ក្នុងមួយខែ ក្នុងរយៈពេល ..........................ដោយគិតចាប់ពីថ្ងៃផ្តិតមេដៃ និងចុះហត្ថលេខាលើកិច្ចសន្យានេះ។

**ប្រការ២** : **របៀបបង់ប្រាក់** :

២.១ ប្រាក់ដើម : ភាគី"ខ" ត្រូវសងប្រាក់ដើមចំនួន..............................................ជូន ភាគី"ក" វិញទៅតាមពេលដូចមានកំណត់ក្នុងប្រការ១ ខាងលើ។

២.២ ការប្រាក់ : ភាគី"ខ" ត្រូវបង់ប្រាក់ចំនួន..................................................អោយបានទៀង ទាត់ដូចដែលបានព្រមព្រៀងជូនភាគី"ក" នៅរៀងរាល់ថ្ងៃទី................នៃខែនីមួយៗ។

**ប្រការ៣** : **សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី"ខ"**

- ភាគី"ខ" យល់ព្រមដាក់បញ្ចាំនូវដី ឬផ្ទះ.................................................................................. ........................................................................................................................ ដើម្បីជាការធានាលើបំណុលជូនភាគី"ក"។

-ភាគី "ខ" ត្រូវបង់ការប្រាក់ជូនភាគី "ក" តាមការកំណត់ ដូចមានចែងក្នុងប្រការ២ខាងលើអោយបានទៀងទាត់។ ប្រសិនបើមានការយឺតយ៉ាវក្នុងការបង់ការប្រាក់ ឬនិងបង់ប្រាក់ដើមមកអោយ ភាគី "ក" នោះ ភាគី"ខ" យល់ព្រមអោយភាគី"ក"លក់នូវរបស់បញ្ចាំដើម្បីទូទាត់បំណុលរបស់ខ្លួន។

## II.<u>អង្គហេតុដែលលើកឡើងដោយដើមបណ្តឹងតប</u>

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

............................................................................................ ។

## III.<u>របៀបដាក់ឥស្តុតាង</u>

១-ពាក្យបណ្តឹងរបស់ឈ្មោះ..........................ចុះថ្ងៃទី ................................. ។

២-លិខិតលេខ:...............................ចុះថ្ងៃទី....................................របស់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់ ។

៣-លិខិតបញ្ជាក់លេខ: ..........................ចុះថ្ងៃទី.........................របស់សាលាឃុំ.................... ។

៤-លិខិតលេខ: ......................... ចុះថ្ងៃទី.................................របស់ការិយាល័យរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ។

ធ្វើនៅថ្ងៃទី.......ខែ ..........ឆ្នាំ ................

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាខ្ចីមានការប្រាក់

លេខអតិថិជន :

លេខកិច្ចសន្យា :

ធ្វើនៅថ្ងៃទី 07 ខែ សីហា ឆ្នាំ 2008

កិច្ចសន្យានេះធ្វើឡើងរវាង :

ភាគីឱ្យខ្ចីប្រាក់ :
សមាគមមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ច សាខាស្ទឹងមានជ័យ តំណាងពេញច្បាប់ដោយ ☒ លោក ☐ អ្នកស្រី

នាទីជា សាខាស្ទឹងមានជ័យ តទៅនេះហៅកាត់ថាភាគី "ក" ។

ភាគីសុំខ្ចីប្រាក់:

☒ រូបវន្តបុគ្គល ☐ នីតិបុគ្គល ចុះបញ្ជីនៅ
លេខ តំណាងដោយ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត
☒ អត្តសញ្ញាណប័ណ្ណ ☒ សៀវភៅគ្រួសារ ☐ សៀវភៅស្នាក់នៅលេខ
ចុះថ្ងៃទី / ចេញដោយ

និងឈ្មោះ ណាង ចន្ទី ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ ខ្មែរ ☐ អត្តសញ្ញាណប័ណ្ណ
☒ សៀវភៅគ្រួសារ ☐ សៀវភៅស្នាក់នៅលេខ / ចុះថ្ងៃទី /
ចេញដោយ ស្នងការនគរបាល ឧត្តមសេនីយ៍ត្រី សួន ណាងលី

អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះលេខ ផ្លូវលេខ ក្រុមទី ភូមិ
ឃុំ-សង្កាត់ ១ ស្រុក-ខណ្ឌ ខេត្ត-ក្រុង ភ្នំពេញ តទៅហៅថាភាគី "ខ" ។

យោងតាម ការស្នើសុំខ្ចីប្រាក់របស់ភាគី "ខ" គោលការណ៍ឥណទាន និងលក្ខខណ្ឌនៃការឱ្យខ្ចីប្រាក់ ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ហើយភាគី "ខ" ក៏យល់ព្រមទទួល និងសន្យាសងមកភាគី "ក" វិញនូវប្រាក់ខ្ចី តាមចំនួន និងរាល់លក្ខខណ្ឌ ដែលបានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការ ១ : កម្មវត្ថុនៃការខ្ចីប្រាក់

ភាគី "ខ" សន្យាថាប្រើប្រាស់ប្រាក់កំចីដែលបានទទួលចំនួន: ____________ (ជាអក្សរ: ____________ ) គិតចាប់ពីថ្ងៃបានទទួលប្រាក់ជា រូបិយប័ណ្ណ USD សំរាប់រយៈពេល ____ ខែ (ជាអក្សរ: ____________ ) ពីថ្ងៃផ្ទេរភាគរយក្នុងមួយខែទៅតាមគំរោងជំនួញ ដែល ឬគិតចាប់ប្រាក់ចូលគណនីរបស់ភាគី "ខ" ក្នុងអត្រាការប្រាក់ ______ ពីថ្ងៃផ្ទេរភាគរយក្នុងមួយខែទៅតាមគំរោងជំនួញ ដែល

ដាក់ស្នើមក ____________

## ប្រការ ២ : បែបបទនៃការខ្ចីប្រាក់

ភាគី "ក" អនុញ្ញាតអោយភាគី "ខ" ធ្វើការបើកប្រាក់ខ្ចីជាវគ្គ ទៅតាមរូបមន្តខ្ចីប្រាក់ដែលមានបញ្ជាក់ នៅក្នុងតារាងនៃវគ្គកម្ចី ដែល ភ្ជាប់ទៅនឹងកិច្ចសន្យាខ្ចីប្រាក់នេះ ។ នៅក្នុងវគ្គនីមួយៗ ភាគី "ខ" អាចដកប្រាក់ជាដំណាក់ៗទៅតាមតំរូវការរបស់ ភាគី "ខ" ។

## ប្រការ ៣ : របៀបរបបនៃការបង់ការប្រាក់

ការប្រាក់ដែលភាគី "ខ" ត្រូវបង់ជូនភាគី "ក" នឹងត្រូវគិតតែទៅលើចំនួនទឹកប្រាក់ដែលមានក្នុងវគ្គ ដែលភាគី "ក" អនុញ្ញាតអោ បើក ហើយដែលភាគី "ខ" បានបើកវគ្គនោះរួចហើយ ។

## ប្រការ ៤ : លទ្ធភាពធ្វើការបដិសេធក្នុងការដកប្រាក់

ក្នុងករណីដែល ភាគី "ក" យល់ឃើញថា ភាគី "ខ" ស្ថិតនៅក្នុងស្ថានភាពលំបាកខាងសេដ្ឋកិច្ចនៅពេលបច្ចុប្បន្ន ឬនៅពេលអនាគត ឬ មានលទ្ធភាពសងប្រាក់ ឬក៏ភាគី "ខ" អាក់ខានក្នុងការបង់ការប្រាក់ និង/ឬ សងរំលោះនៅវគ្គមុនៗ ភាគី "ក" មានសិទ្ធិធ្វើការបដិសេ ទៅ ភាគី "ខ" ក្នុងការសុំបើកវគ្គបន្ថែម តាមរយៈពាក្យស្នើសុំបើកវគ្គរបស់ភាគី "ខ" ។

## ប្រការ ៥ : របៀបរបបនៃការសងបំណុល

ការសងប្រាក់នឹងអនុវត្តតាមតារាងកាលវិភាគសងប្រាក់ ដោយបង់ប្រាក់ផ្ទាល់ ឬកាត់ចេញពីគណនីបញ្ញើសំចៃរបស់ភាគី "ខ" ។ ចំពោ ទីកន្លែងបង់ប្រាក់ ភាគី "ខ" ត្រូវមកបង់ដល់ការិយាល័យសាខារបស់សមាគមមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចដែលភាគី "ខ" បានបើកគណនី។

## ប្រការ ៦ : ការធានាបំណុល

ដើម្បីធានានូវបំណុលដែលបានខ្ចី ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាជ្រើសរើសរបៀបនៃកាធានាដូចខាងក្រោម :

ក. ចលនទ្រព្យ ឬអចលនទ្រព្យ របស់ឈ្មោះ ____________ លិខិតកម្មសិទ្ធិ ____________ លេខ ____________ ______ ចេញដោយ ____________ ដែលមាន បញ្ជាក់ក្នុងកិច្ចសន្យាបញ្ចាំចលនទ្រព្យ ឬកិច្ចសន្យាដាក់ធានាអចលនទ្រព្យលេខ ____________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ 2008 បានបញ្ជាក់ដោយ ____________ ____________ ។